ពន្លឺប្រាជ្ញា

# សទ្ទានុក្រមពាក្យផ្ទុយ

សាស្ត្រាចារ្យ នូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៥

ពន្លឺប្រាជ្ញា

# សទ្ទានុក្រមពាក្យផ្ទុយ

សាស្ត្រាចារ្យ ទូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៥

# សទ្ទានុក្រមពាក្យផ្ទុយ


រៀបរៀង : លោក **ទូច-គីមស្រ៊ាង** បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

ជំនួយការ : លោក **អ៊ុន-សុភា** បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **លីម-ថេង** សោភណោ

: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវង្ស**

: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អឿ-សាវ៉ន**

: លោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀង

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះមហា **វ៉ែន-វបុល** : លោក **អៀង-ពិសី**

: កញ្ញា **ឆៃ-សារ៉ែម** : កញ្ញា **ចាន់-នីតា**

: កញ្ញា **ធិញ-ធីណា** : លោក **តោត-ច័ន្ទវបុល**

: លោក **វ៉ាន់-ផល្លី** : លោក **ប៊ុត-សុផល**

: លោក **សុខ-ធម្មតាសី** : លោក **ហ៊ុន-ស៊ីនី**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន** រោងពុម្ព JSRC Printing House

ISBN-9 789996 370588


រក្សាសិទ្ធិគ្រប់យ៉ាង ©



បោះពុម្ពលើកទី១ : ៤កើត ខែចេត្រ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

: ត្រូវនឹងថ្ងៃចន្ទ ទី២៣ ខែមីនា គ.ស.២០១៥

ឧបត្ថម្ភបោះពុម្ព : **សប្បុរសជន**

អាសយដ្ឋានចែកចាយ : បណ្ណាល័យ សកលវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ...



“**ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់**”

# អារម្ភកថា

សៀវភៅ សទ្ទានុក្រមពាក្យផ្ទុយ នេះដែលព្រះតេជព្រះគុណ សម្តេច ទ្រង់ ឯកឧត្តម ឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ប្រិយមិត្តកំពុងតែអាន ខ្ញុំបានប្រើពេលវេលាយ៉ាងយូរក្នុងការរៀបរៀងសៀវភៅនេះឡើង ដោយគោលបំណង បំពេញទៅតាមសំណូមពរលោកគ្រូ អ្នកគ្រូ និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដើម្បីយល់ដឹងពីគំនិតល្អៗជាច្រើននៃ សទ្ទានុក្រមពាក្យផ្ទុយ ដែលមនុស្សទូទៅមិន ទាន់បានយល់ដឹងច្បាស់លាស់ទៅលើការប្រើពាក្យពេចន៍មានន័យផ្ទុយគ្នាឱ្យបាន ត្រឹមត្រូវតាមក្បួនខ្នាតអក្សរសាស្ត្រខ្មែរយើងនៅឡើយ។

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយតាំងពីអតីតកាល មករៀបរៀង ជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យ បទពិសោធ ទស្សនៈបុរាណ ទស្សនៈថ្មីៗ ដើម្បីចូលរួមចំណែកអភិរក្សនិងអភិវឌ្ឍ វិស័យភាសាខ្មែរយើង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមែកធាង សំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ ជា អត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សា មេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំរង់ចាំទទួលយកកំហុសឆ្គងខ្លឹមសារអក្ខរាវិរុទ្ធដោយ សុច្ឆន្ទៈមនសិការសោមនស្សគំនិតកែលម្អពីសំណាក់លោកអ្នកសិក្សាទាំងឡាយ។

រាជធានីភ្នំពេញ ៤កើត ខែចេត្រ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃចន្ទ ទី២៣ ខែមីនា គ.ស.២០១៥

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាន**

# កតញ្ញូកតវេទិតាកថា

កូនសូមក្រាបថ្វាយបង្គំលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ គោរពជូនចំពោះលោកឪពុក **ទ្រី-យ៉េន** និងអ្នកម្តាយ **អ៊ុំ-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃជីវិតកូន។

កូនសូមគោរពសម្តែងកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេ ដែលបានផ្តល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះរូបកូនចងចាំអស់មួយជីវិតហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្តោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើពេលវេលាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមគោរពសច្ចាប្រណិធានប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងរហូត។

រាជធានីភ្នំពេញ ៤កើត ខែចេត្រ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃចន្ទ ទី២៣ ខែមីនា គ.ស.២០១៥

សាស្ត្រាចារ្យ **ឌួច-គីមស្រ៊ាង**

**ឧទ្ទិសកថា**

សូមឧទ្ទិសស្នាដៃនេះគោរពថ្វាយ ប្រគេន ជូនចំពោះ

❖ បុព្វបុរសខ្មែរស្នេហាជាតិដែលបានធ្វើពលិកម្មគ្រប់យ៉ាងការពារជាតិមាតុភូមិ

❖ អ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

❖ សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១នៃគណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្តដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

❖ បុព្វការីជនរបស់ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ច។

រាជធានីភ្នំពេញ ៤កើត ខែចេត្រ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃចន្ទ ទី២៣ ខែមីនា គ.ស.២០១៥

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាង**

នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការចារចម្លងនាន
ដែលបានលះបង់សេចក្តីសុខផ្ទាល់ខ្លួនគ្រប់យ៉ាងដើម្បីអត្ថប្រយោជន៍បណ្តុះ
ពូជពន្លឺបញ្ញាបារមីផ្សព្វផ្សាយវប្បធម៌អក្សរសាស្ត្រខ្មែរយើងដល់សង្គមជាត
និងដើម្បីដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

- ❖ មូលនិធិអៀង
- ❖ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា
- ❖ CAM-PAINT ថ្នាំពណ៌ជាត
- ❖ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន
- ❖ សាលារៀនវ៉េស្ទឡាញន៍ និង សាលារៀនណាត្សឡាញន៍
- ❖ មហាឧបាសិកា សុខ-អ៊ឹម និងបុត្រ ឆ្វ-ឆៃគៀង
- ❖ ឧបាសក ដាំ-ក្មុយ និងឧបាសិកា សុខ-ពៅ
- ❖ ឧបាសក អៀង-អឿន និងឧបាសិកា អៀង-សាតឹម
- ❖ ឯកឧត្តម តេង-សាវង្ស និងលោកជំទាវ ស៊ាង-តឹម
- ❖ ឯកឧត្តម ម៉ម-សំ និងលោកជំទាវ អ៊ិត-បុប្ផាផល្គុណា
- ❖ ឯកឧត្តម អ៊ឿ-សាវ៉ន និងលោកជំទាវ ពៅ-សាភឿន
- ❖ ឯកឧត្តម ដួង-ហេង និងលោកជំទាវ ហេង-ទាន់
- ❖ ឯកឧត្តម ប៉ែន-វចិត្រ និងលោកជំទាវ ដេន-សុភ័ក្ត្រនារី
- ❖ ឯកឧត្តម តាង-ហៀង និងលោកជំទាវ លី-តឹមមួយ
- ❖ ឯកឧត្តម ចាន់-សារ៉េត និងលោកជំទាវ ស៊ឹម-ថារី
- ❖ ឯកឧត្តម ពេជ-សាភឿន និងលោកជំទាវ ឈឹម-ស៊ីថន
- ❖ ឯកឧត្តម ម៉ម-ឈាង និងលោកជំទាវ ឯម-មុំ

❖ ឯកឧត្តម លី-វណ្ណានី និងលោកជំទាវ ប្រាក់-ចិន្តា

❖ ឯកឧត្តម ស៊ិន-ខ័ណ្ឌី និងលោកជំទាវ ហែន-ស្រីខ្មែន

❖ ឯកឧត្តម គីម-រស្មី និងលោកជំទាវ ម៉ែន-ចាន់ណារី

❖ ឯកឧត្តម ហុង-វណុល និងលោកជំទាវ គួយ-លីនណា

❖ ឯកឧត្តម ណាង-សុជីវី និងលោកជំទាវ ហ៊ាង-ឆវី

❖ ឯកឧត្តម ហង្ស-ចិន្តា និងលោកជំទាវ ណាង-ណាថនល័ក្ខណ៍

❖ លោក សោម-សម្បត្តិ និងលោកស្រី អ៊ុក-ចន្ថា

❖ លោក ចាន់-សេរី និងលោកស្រី តាំង-មនោ

❖ លោក ហេង-យាង និងលោកស្រី លី-មុយខ្លេង

❖ លោក គីវ-សុខា និងលោកស្រី កៀង-សម័យ

❖ លោក អៀង-ណារិន និងលោកស្រី ប្រាក់-សេដ្ឋាវី

❖ លោក ពីវ-វ៉ាន់ឌី និងលោកស្រី ហ៊ាង-សុជាតា

❖ លោក អេង-យូលីម និងលោកស្រី ទន់-ហ្គិចហ្លួយ

❖ លោក អេង-ហ៊ី និងលោកស្រី លឹម-ខេង

❖ លោក គុយ-វ៉ាត និងលោកស្រី ទុយ-តីន

❖ លោក អ៊ួង-គីមសេង និងលោកស្រី ជា-លីណា

❖ លោក យាង-ច័ន្ទរិទ្ធា និងលោកស្រី លី-ហាក់ហៀង

❖ លោក យៀង-សុគន្ធា និងលោកស្រី ស្វូ-សុផាន់ណាវី

❖ លោក ថាវ-វណ្ណា និងលោកស្រី ម៉ី-សុខឌី

❖ លោក ឆុត-វ៉ានី និងលោកស្រី អ៊ុន-សោភា

❖ លោក ឆុត-វុទ្ធី និងលោកស្រី កែន-ប៊ុណ្ណា

❖ លោក ឆួន-សុខា និងលោកស្រី អ៊ូច-វណ្ណាថា

❖ លោក គង់-សត្ថារិន និងលោកស្រី ឌិត្យ-តារា

❖ លោក យិន-សារិទ្ធ និងលោកស្រី ខឿន-សុគន្ធា

❖ លោក សួទ-ឆាយ និងលោកស្រី ប៊ី-សុគី

❖ លោក ច្រឹក-សុខនឹម និងលោកស្រី ហៀង-ឆវី

❖ លោក ឈរី-ចាន់ខឿន និងលោកស្រី ផូ-ដាលីស

❖ លោក ឆួន-ហ៊ីន និងលោកស្រី ឈឹម-ចន្ទ៍កែវ

❖ លោក ចាន់-ឌីតា និងលោកស្រី ជឹម-ស្រីមនោ

❖ លោក ស្វ៉ាត-គស្ថា និងលោកស្រី ឈឹម-ឡាលីន

❖ លោក គឹម-ទីរៈ និងលោកស្រី គូ-ជីនជីន

❖ លោក ដេត-សារិន និងលោកស្រី មាស-សុគន្ធាវី

❖ លោក ហ៊ីង-បូរ៉ា និងលោកស្រី អួម-សោភា

❖ លោក ឡុង-ឌិត្យ និងលោកស្រី ពេជ្រ-ណារី

❖ លោក គឹម-ប៊ុន្នី និងលោកស្រី សុភ-ស្រី

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្តមភរិយា **ម៉ែន-សេងយ៉េង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានឃោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេសខ្ញុំ សូមគោរពសម្តែងការកោតសរសើរនិងការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សប្បុរសជន** ដែលមានសន្តានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាបំពេញបញ្ញាបារមីបោះពុម្ពសៀវភៅ សទ្ទានុក្រមពាក្យផ្ទុយ ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីផលប្រយោជន៍នៃគុណតម្លៃវប្បធម៌ ភាសា អក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការ ***សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ***។

សូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ សប្បុរសជន លោកអ្នកអានដែលបានជួយលើកស្ទួយគុណតម្លៃស្នាដៃរៀបរៀងសៀវភៅរបស់ខ្ញុំ សូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។

រាជធានីភ្នំពេញ ៤កើត ខែចេត្រ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

ត្រូវនឹងថ្ងៃចន្ទ ទី២៣ ខែមីនា គ.ស.២០១៥

សាស្ត្រាចារ្យ **ឡូច-គីមស្រ៊ាង**

## អក្សរសង្ខេប

### ប្រើក្នុងសទ្ទានុក្រមពាក្យផ្ទុយនេះ

| | | |
|---|---|---|
| *កិ.* | : | កិរិយាសព្ទ |
| *កិ.វិ.* | : | កិរិយាវិសេសនៈ ឬ កិរិយាវិសេសន៍ |
| *គ.ស.* | : | គ្រិស្តសករាជ |
| *គុ.* | : | គុណសព្ទ |
| *ចិ.* | : | ចិន (ភាសាចិន) |
| *ន.* | : | នាមសព្ទ |
| *និ.* | : | និបាតសព្ទ |
| *បា.* | : | បាលី |
| *បា.ក្ល.* | : | បាលីក្លាយ |
| *បា.សំ.* | : | បាលីនិងសំស្ក្រឹតលាយគ្នា |
| *បា.សំ.ក្ល.* | : | បាលីនិងសំស្ក្រឹតក្លាយ |
| *ព.ពុ.* | : | ពាក្យវិន័យពុទ្ធសាសនា |
| *ព.វ.* | : | ពាក្យសម្រាប់ប្រើក្នុងវេយ្យាករណ៍ |
| *ព.វិ.ពុ.* | : | ពាក្យវិន័យពុទ្ធសាសនា |
| *ព.ស.* | : | ពុទ្ធសករាជ |
| *ព.អ.* | : | ពាក្យសម្រាប់ប្រើក្នុងព្រះអភិធម្ម |
| *រ.ស.* | : | រាជសព្ទ |
| *ស.ស.* | : | សមណសព្ទ (ប្រើជា សង្ឃសព្ទ ក៏មាន) |
| *សំ.* | : | សំស្ក្រឹត |

| | | |
|---|---|---|
| *សំ.ក្ល.* | : | សំស្រ្កឹតក្លាយ |
| *អា.និ.* | : | អាយតនិបាត |
| *ឧ.* | : | ឧទានសព្ទ |

# សទ្ទានុក្រមពាក្យផ្ទុយ

📖 **កតញ្ញុតា ពាក្យផ្ទុយ អកតញ្ញុតា**

**កតញ្ញុតា** *ន.* (បា.) ភាពជាអ្នកដឹងឧបការគុណដែលអ្នកដទៃបានធ្វើដល់ខ្លួន :

❖ បុត្រធីតាត្រូវមានកតញ្ញុតាចំពោះមាតាបិតា។

**អកតញ្ញុតា** *ន.* (បា.) ភាពជាអ្នកមិនដឹងឧបការគុណដែលអ្នកដទៃបានធ្វើចំពោះខ្លួន។

📖 **កតញ្ញូ ពាក្យផ្ទុយ អកតញ្ញូ**

**កតញ្ញូ** *ន.* (បា.) អ្នកដឹងឧបការគុណដែលអ្នកដទៃបានធ្វើហើយដល់ខ្លួន គឺអ្នកដែលមិនភ្លេចគុណគេ, អ្នកដែលមិនរមិលគុណគេ :

❖ ស្ត្រីកតញ្ញូ

❖ បុរសកតញ្ញូ។

**អកតញ្ញូ** *ន.* (បា.) អ្នកមិនដឹងឧបការគុណដែលអ្នកដទៃបានធ្វើចំពោះខ្លួន :

❖ មនុស្សអកតញ្ញូ។

📖 **កតវេទិនី ពាក្យផ្ទុយ អកតវេទិនី**

**កតវេទិនី** *ន.* (បា.) ស្ត្រីអ្នកដែលបានតបឧបការគុណ, ស្ត្រីអ្នកដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមានគុណ។

**អកតវេទិនី** *ន.* (បា.) ស្ត្រីអ្នកដែលមិនតបឧបការគុណគេ, ស្ត្រីអ្នកដែលមិនគិតនឹងតបឧបការគុណគេ។

📖 **កតវេទី ពាក្យផ្ទុយ អកតវេទី**

**កតវេទី** *ន.* (បា.) អ្នកដែលបានតបឧបការគុណ, អ្នកដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមានគុណ។

**អកតវេទី** *ន.* (បា.) អ្នកដែលមិនតបឧបការគុណគេ, អ្នកមិនគិតនឹងតបឧបការគុណគេ។

📖 **កត្តុវាចក ពាក្យផ្ទុយ កម្មវាចក**

**កត្តុវាចក** *ន.* (បា.) កិរិយាសព្ទរបស់អ្នកធ្វើ។

**កម្មវាចក** *ន.* (បា.) កិរិយាសព្ទរបស់អំពើដែលគេត្រូវធ្វើ។

📖 **កប្បិយ ពាក្យផ្ទុយ អកប្បិយ**

**កប្បិយ** *គុ.* (បា.) ដែលគួរ, ដែលត្រូវទំនង, ដែលសមដល់ការ។

**អកប្បិយ** *គុ.* (បា.) ដែលមិនគួរ, ដែលមិនត្រូវទំនង, ដែលមិនសមដល់ការ។

📖 **ករណីយ ពាក្យផ្ទុយ អករណីយ**

**ករណីយ** *គុ.* (បា.) ដែលគួរធ្វើ, ដែលគប្បីធ្វើ, ដែលត្រូវធ្វើ។

**អករណីយ** *គុ.* (បា.) ដែលមិនគួរធ្វើ, ដែលមិនគប្បីធ្វើ, ដែលមិនត្រូវធ្វើ។

📖 **ករណីយកិច្ច**  **ពាក្យផ្ទុយ**  **អករណីយកិច្ច**

**ករណីយកិច្ច** *ន.* (បា.) កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ។

**អករណីយកិច្ច** *ន.* (បា.) កិច្ចដែលមិនគួរធ្វើ; កិច្ចដែលសមណៈមិនត្រូវធ្វើដោយដាច់ខាត។

📖 **កល្យាណកម្ម**  **ពាក្យផ្ទុយ**  **លាមកកម្ម**

**កល្យាណកម្ម** *ន.* (បា.) អំពើល្អ, កុសលកម្ម។

**លាមកកម្ម** *ន.* (បា.) អំពើអាក្រក់, អកុសលកម្ម។

📖 **កល្យាណមិត្ត**  **ពាក្យផ្ទុយ**  **បាបមិត្ត**

**កល្យាណមិត្ត** *ន.* (បា.) មិត្តល្អ, មិត្តត្រឹមត្រូវដែលបុគ្គលគួរសេពគប់គួររាប់រកយកជាគ្នា។

**បាបមិត្ត** *ន.* (បា.) មិត្តអាក្រក់, មិត្តដែលនាំឱ្យខូចខាតប្រយោជន៍, មិត្តដែលនាំឱ្យមានសេចក្ដីវិនាសផ្សេងៗ។

📖 **កាច**  **ពាក្យផ្ទុយ**  **ស្លូត**

**កាច** *គុ.* ដែលទីទៃពីស្លូត, ដែលមានសន្ដានចិត្តប្រកបដោយកំហឹង :

❖ មនុស្សកាច។

**ស្លូត** *គុ.* ដែលទីទៃពីកាច, ដែលមិនកាច, ដែលឥតកាច :

❖ មនុស្សស្លូត។

📖 **កាល** **ពាក្យផ្ទុយ** **អកាល**

**កាល** *ន.* (បា.សំ.) គ្រា, ពេល, សម័យ :

❖ កាលពីឆ្នាំមុន។

**អកាល** *គុ.* ឬ *ន.* (បា.សំ.) កាលមិនគួរ, កាលខុសប្រក្រតី; ដែលខុសកាល, ដែលពុំជួកាល :

❖ វេលានេះជាអកាល។

📖 **កាលវិបត្តិ** **ពាក្យផ្ទុយ** **កាលសម្បត្តិ**

**កាលវិបត្តិ** *ន.* (បា.) ការប្រែប្រួលនៃកាល, ការខូចវេលា, ដំណើរខុសកាល។

**កាលសម្បត្តិ** *ន.* (បា.) ការសមប្រកបដោយកាល, ការត្រូវទំនងតាមវេលា, ដំណើរដែលត្រូវតាមកាលសម័យ។

📖 **កាឡបក្ខ** **ពាក្យផ្ទុយ** **សុក្កបក្ខ**

**កាឡបក្ខ** *ន.* (បា.) ចំណែកខាងខ្មៅ, ប៉ែកខាងងងឹត, ប៉ែកខាងរនោច។

**សុក្កបក្ខ** *ន.* (បា.) ចំណែកខាងស, ប៉ែកខាងភ្លឺ, ប៉ែកខាងខ្នើត។

📖 **កិរិយវាទ** **ពាក្យផ្ទុយ** **អកិរិយវាទ**

**កិរិយវាទ** *ន.* (បា.) អ្នកពោលថា រីកម្ម គឺបុគ្គលធ្វើហើយឈ្មោះថា បុគ្គលធ្វើ,

អ្នកមានលទ្ធិជាគ្រឿងពោលថា កម្ម ឈ្មោះថា បុគ្គលធ្វើ។

**អកិរិយវាទ** *ន.* (បា.) ការពោលពាក្យថាបុណ្យបាបដែលធ្វើមិនមែនហៅថា ធ្វើទេ គឺថាធ្វើបុណ្យធ្វើបាបមិនមែនបានបុណ្យបានបាបទេ, សម្ដីបដិសេធបុណ្យបាបថាធ្វើទៅឥតអំពើ; អ្នកមិនជឿបុណ្យបាប។

📖 **កិរិយវាទិនី ពាក្យផ្ទុយ អកិរិយវាទិនី**

**កិរិយវាទិនី** *ន.* (បា.) ស្ត្រីអ្នកមិនប្រកាន់និយាយបដិសេធបុណ្យបាបថាធ្វើទៅឥតអំពើ, ស្ត្រីអ្នកប្រកាន់ជឿបុណ្យបាប។

**អកិរិយវាទិនី** *ន.* (បា.) ស្ត្រីអ្នកប្រកាន់និយាយបដិសេធបុណ្យបាបថាធ្វើទៅឥតអំពើ, ស្ត្រីអ្នកប្រកាន់មិនជឿបុណ្យបាប។

📖 **កិរិយវាទី ពាក្យផ្ទុយ អកិរិយវាទី**

**កិរិយវាទី** *ន.* (បា.) អ្នកពោលថា រឹកម្ម គឺបុគ្គលធ្វើហើយឈ្មោះថា គឺ បុគ្គលធ្វើ, អ្នកមានលទ្ធិជាគ្រឿង ពោលថា កម្ម ឈ្មោះថា គឺ បុគ្គលធ្វើ។

**អកិរិយវាទី** *ន.* (បា.) អ្នកប្រកាន់និយាយបដិសេធបុណ្យបាបថាធ្វើទៅឥតអំពើ, អ្នកប្រកាន់មិនជឿបុណ្យបាប។

📖 **កុសល ពាក្យផ្ទុយ អកុសល**

**កុសល** *គុ.* (បា.) ដែលល្អប្រពៃ, ដែលជាបុណ្យ។

**អកុសល** *គុ.* (បា.) ដែលអាក្រក់, ដែលមិនល្អ; ដែលមិនឈ្លាស។

📖 **កុសលកម្ម ពាក្យផ្ទុយ អកុសលកម្ម**

**កុសលកម្ម** *ន.* (បា.) កម្មល្អ។

**អកុសលកម្ម** *ន.* (បា.) កម្មអាក្រក់។

📖 **កុសលកម្មបថ ពាក្យផ្ទុយ អកុសលកម្មបថ**

**កុសលកម្មបថ** *ន.* (បា.) គន្លងនៃអំពើល្អ។

**អកុសលកម្មបថ** *ន.* (បា.) គន្លងនៃអំពើអាក្រក់។

📖 **កុសលកិរិយា ពាក្យផ្ទុយ អកុសលកិរិយា**

**កុសលកិរិយា** *ន.* (បា.) កិរិយាល្អ។

**អកុសលកិរិយា** *ន.* (បា.) កិរិយាអាក្រក់។

📖 **កុសលចរិយា ពាក្យផ្ទុយ អកុសលចរិយា**

**កុសលចរិយា** *ន.* (បា.) ចរិយាល្អ។

**អកុសលចរិយា** *ន.* (បា.) ចរិយាអាក្រក់។

📖 **កុសលចិត្ត ពាក្យផ្ទុយ អកុសលចិត្ត**

**កុសលចិត្ត** *ន.* (បា.) ចិត្តជាកុសល, ចិត្តបុណ្យ។

**អកុសលចិត្ត** *ន.* (បា.) ចិត្តជាអកុសល, ចិត្តបាប។

📖 **កុសលចេតនា ពាក្យផ្ទុយ អកុសលចេតនា**

**កុសលចេតនា** *ន.* (បា.) ការតាំងចិត្តជាបុណ្យ, គំនិតបុណ្យ; គំនិតល្អ។

**អកុសលចេតនា** *ន.* (បា.) ការតាំងចិត្តជាបាប, គំនិតបាប; គំនិតអាក្រក់។

📖 **កុសលចេតសិក ពាក្យផ្ទុយ អកុសលចេតសិក**

**កុសលចេតសិក** *ន.* (បា.) ចេតសិកជាកុសល គឺអារម្មណ៍ដែលកើតរលត់ព្រមជាមួយនឹងចិត្តជាកុសល។

**អកុសលចេតសិក** *ន.* (បា.) ចេតសិកជាអកុសល គឺអារម្មណ៍ដែលកើតរលត់ព្រមជាមួយនឹងចិត្តជាអកុសល។

📖 **កុសលធម៌ ពាក្យផ្ទុយ អកុសលធម៌**

**កុសលធម៌** *ន.* (សំ.) ធម៌ជាកុសល។

**អកុសលធម៌** *ន.* (សំ.) ធម៌ជាអកុសល។

📖 **កុសលធាតុ ពាក្យផ្ទុយ អកុសលធាតុ**

**កុសលធាតុ** *ន.* (បា.) ធាតុជាកុសល គឺនុយបុណ្យ, ចំណីបុណ្យ។

**អកុសលធាតុ** *ន.* (បា.) ធាតុជាអកុសល គឺនុយបាប, ចំណីបាប។

📖 **កុសលមូល ពាក្យផ្ទុយ អកុសលមូល**

**កុសលមូល** *ន.* (បា.) ឫសគល់នៃកុសល, ទីតាំងនៃកុសល។

**អកុសលមូល** *ន.* (បា.) ឫសគល់នៃអកុសល, ទីតាំងនៃអកុសល។

📖 **កុសលលាភ** **ពាក្យផ្ទុយ** **អកុសលលាភ**

**កុសលលាភ** *ន.* (បា.) ការបានបុណ្យ។

**អកុសលលាភ** *ន.* (បា.) ការបានបាប។

📖 **កុសលវិតក្ក** **ពាក្យផ្ទុយ** **អកុសលវិតក្ក**

**កុសលវិតក្ក** *ន.* (បា.) ការត្រិះរិះទៅរកអំពើល្អ, តម្រិះល្អ។

**អកុសលវិតក្ក** *ន.* (បា.) ការត្រិះរិះទៅរកអំពើអាក្រក់, តម្រិះអាក្រក់។

📖 **កុសលវិបាក** **ពាក្យផ្ទុយ** **អកុសលវិបាក**

**កុសលវិបាក** *ន.* (បា.) ស្នាមគំនូសចិត្តជាកុសល, គំនូសបុណ្យ; ផលបុណ្យ។

**អកុសលវិបាក** *ន.* (បា.) ស្នាមគំនូសចិត្តជាអកុសល, គំនូសបាប; ផលបាប។

📖 **កើត** **ពាក្យផ្ទុយ** **រោច**

**កើត** *ន.* ឈ្មោះចំណែកថ្ងៃខាងខ្នើត គឺតាំងពីថ្ងៃទី១ទៅដល់ថ្ងៃទី១៥។

**រោច** *ន.* ថ្ងៃខាងរនោចនៃខែចន្ទគតិតាំងពីថ្ងៃទី១ដល់ថ្ងៃទី១៤ឬ១៥ គឺថ្ងៃដែលមានពន្លឺព្រះចន្ទថយចុះដូចគេចាប់រោចចេញ។

📖 **ក្តួច** **ពាក្យផ្ទុយ** **ក្រៅ**

**ក្តួច** *កា.និ.* កំលុង, រវាងមានលក្ខខណ្ឌ :

❖ ក្នុងស្រុក។

**ក្រៅ** *និ.* ទីទៃពីខាងក្នុង :

❖ ក្រៅរបង។

📖 **ក្រាស់** **ពាក្យផ្ទុយ** **ស្តើង**

**ក្រាស់** *គុ.* ទីទៃពីស្តើង, ដែលមានកម្រាស់ :

❖ ក្តារក្រាស់

❖ សំពត់ក្រាស់។

**ស្តើង** *គុ.* ដែលមានកម្រាស់តិច, តិចកម្រាស់ :

❖ ក្តារស្តើង

❖ សំពត់ស្តើង។

📖 **ក្រិស** **ពាក្យផ្ទុយ** **ដំឡោក**

**ក្រិស** *គុ.* តូច, តូចច្រមិច គឺដែលរៀវក្រិនមិនធំតាមកំណត់កាលដែលត្រូវធំ :

❖ មនុស្សក្រិស។

**ដំឡោក** *គុ.* ដែលឆាប់ធំមុនកាលកំណត់ :

❖ ក្មេងដំឡោក។

📖 **ក្សួណៈ** **ពាក្យផ្ទុយ** **អក្សួណៈ**

**ក្សណៈ** *ន.* (**សំ.ភ្ល.**) ពេល, ស្របក់, រំពេច។

**អក្សណៈ** *ន.* (**សំ.ភ្ល.**) ស្របក់ដែលមិនមែនជាឱកាស, កាលដែលមិនមែនជាឱកាស, វេលាដែលមិនមែនជាឱកាស, វេលាដែលឃ្លាងចាកប្រយោជន៍, វេលាដែលមិនសមប្រកប; វេលាមិនល្អ; ពេលប្រទះលើគ្រោះកាច។

📖 **ខណៈ** **ពាក្យផ្ទុយ** **អក្ខណៈ**

**ខណៈ** *ន.* (**បា.ភ្ល.**) ស្របក់, រំពេច :

- ខណៈនោះ
- មួយខណៈ។

**អក្ខណៈ** *ន.* ឬ *គុ.* (**បា.ភ្ល.**) ស្របក់ដែលមិនមែនជាឱកាស, កាលដែលមិនមែនជាឱកាស, វេលាដែលមិនមែនជាឱកាស, វេលាដែលឃ្លាងចាកប្រយោជន៍, វេលាដែលមិនសមប្រកប; វេលាមិនល្អ; ពេលប្រទះលើគ្រោះកាច។

📖 **ខន្តី** **ពាក្យផ្ទុយ** **អក្ខន្តី**

**ខន្តី** *ន.* (**បា.**) អំណត់អត់ឱន, សេចក្តីអត់ធន់, សេចក្តីអត់ទ្រាំនូវកំហឹងនិងសេចក្តីអត់ទ្រាំនូវទុក្ខកង្វល់ជាដើម។

**អក្ខន្តី** *ន.* (**បា.**) ការមិនអត់ទ្រាំ, ដំណើរអត់ធន់ពុំបាន, ដំណើរទប់កំហឹងពុំឈ្នះ, ដំណើរអត់ខឹងពុំបាន។

📖 **ខាត** **ពាក្យផ្ទុយ** **ចំណេញ**

**ខាត** *កិ.* ឬ *កិ.វិ.* ថយពីចំនួនដើម, មិនពេញ, មិនចំណេញ :

❖ រកស៊ីធ្វើការខាត។

**ចំណេញ** *ន.* កម្រៃដែលចូលច្រើនជាងចំនួនដើម, សេចក្ដីចម្រើន :

❖ ក្នុងឆ្នាំនេះពួកឈ្មួញមានចំណេញគ្រាន់បើ។

📖 **ខុស** **ពាក្យផ្ទុយ** **ត្រូវ**

**ខុស** *កិ.វិ.* ឬ *គុ.* ទីទៃពីត្រូវ គឺដែលមិនត្រូវ, ដែលកន្លង :

❖ សេចក្ដីខុស។

**ត្រូវ** *កិ.វិ.* ឬ *គុ.* ទីទៃពីខុស គឺត្រង់, ទីទៃពីខុស គឺចំ :

❖ សេចក្ដីត្រូវ។

📖 **ខូច** **ពាក្យផ្ទុយ** **ជា**

**ខូច** *គុ.* ដែលមានកិរិយាអាក្រក់, ដែលមានពុតត្បុត។

**ជា** *គុ.* ស្រួល; ល្អ; សុខ; សប្បាយ; រួចពីឈឺ, ងើបពីឈឺ។

📖 **ខើច** **ពាក្យផ្ទុយ** **ស្រុខ**

**ខើច** *គុ.* ដែលឥតសម្រុង :

❖ សំពត់ខើច។

**ស្រួច** *គុ.* ស្តួយ, ដែលមានសម្រុង :

❖ សំពត់ស្រួង។

📖 **ខ្ចី** **ពាក្យផ្ទុយ** **ចាស់, ទុំ**

**ខ្ចី** *គុ.* ដែលមិនទាន់ចាស់, ដែលមិនទាន់ទុំ :

❖ ចេកខ្ចី

❖ ស្វាយខ្ចី។

**ចាស់** *គុ.* ទីទៃពីក្មេង, ទីទៃពីថ្មី, ទីទៃពីខ្ចី :

❖ មនុស្សចាស់

❖ ផ្លែឈើចាស់។

**ទុំ** *គុ.* ទីទៃពីខ្ចីពីចាស់ គឺដែលដល់កំណត់ជិតជ្រុះពីមែក, ដែលដល់កំណត់ជិតជ្រុះពីទង :

❖ ផ្លែឈើទុំ

❖ ស្លឹកឈើទុំ។

📖 **ខ្ជិល** **ពាក្យផ្ទុយ** **ឧស្សាហ៍**

**ខ្ជិល** *គុ.* ដែលមិនចូលចិត្តធ្វើការ, ដែលធុញទ្រាន់ស្អប់ការងារ។

**ឧស្សាហ៍** *គុ.* (**បា.ស្ក.**) ដែលមានព្យាយាម, ដែលជាអ្នកឧហាត, ដែលសង្វាត,

ដែលខំប្រឹង។

📖 **ខ្នើត** **ពាក្យផ្ទុយ** **រនោច**

**ខ្នើត** *ន.* ពន្លឺដែលកើតតាមលំដាប់ថ្ងៃ គឺចំណែកខែខាងដើមដែលមានពន្លឺព្រះចន្ទមកដល់ថ្ងៃពេញបូណ៌មី គឺតាំងពីថ្ងៃ១កើតមកដល់ថ្ងៃ១៥កើត; ថ្ងៃតពីនេះទៅហៅថា រនោច។

**រនោច** *ន.* ពន្លឺព្រះចន្ទដែលថយចុះដូចគេចាប់បោចរោចបន្តិចម្តងៗ, កាឡបក្ស គឺចំណែកខាងខ្មៅ (ខាងងងឹត) ជាបក្សទី២នៃខែខាងចន្ទគតិរាប់ពីថ្ងៃ១រោចទៅដល់ថ្ងៃ១៤ឬ១៥រោច :

- រនោចខែមិគសិរមាន១៤ថ្ងៃ
- រនោចខែបុស្សមាន១៥ថ្ងៃ។

📖 **ខ្ពស់** **ពាក្យផ្ទុយ** **ទាប**

**ខ្ពស់** *គុ.* ដែលមានជំហរបញ្ឈរវែងច្រើនឡើងលើ។

**ទាប** *គុ.* ទីទៃពីខ្ពស់ គឺតិចកម្ពស់, តិចជំហរ, ដែលឥតកម្ពស់, ឥតជំហរ។

📖 **ខ្មៅ** **ពាក្យផ្ទុយ** **ស**

**ខ្មៅ** *គុ.* ដែលមានពណ៌ងងឹត, ដែលមានពណ៌យ៉ាងធ្យូង។

**ស** *គុ.* ដែលមានសម្បុរដូចសំឡីកប្បាស :

❖ ពណ៌ស

❖ សំពត់ស។

🕮 **ខ្លាច** **ពាក្យផ្ទុយ** **ហ៊ាន**

**ខ្លាច** *កិ.* ដែលមិនហ៊ាន, ដែលមិនអាច :

❖ ខ្លាចខ្លា។

**ហ៊ាន** *កិ.* ដែលមិនខ្លាច, ដែលអាច :

❖ ហ៊ានទៅម្នាក់ឯងទាំងយប់ស្ងាត់។

🕮 **ខ្លី** **ពាក្យផ្ទុយ** **វែង**

**ខ្លី** *គុ.* ដែលតិចប្រវែង :

❖ ខ្សែខ្លី

❖ សេចក្ដីខ្លី។

**វែង** *គុ.* ទីទៃពីខ្លីគឺមានប្រវែង, មានចំនួនឆ្ងាយ :

❖ ខ្សែវែង

❖ សេចក្ដីវែង។

🕮 **ខ្លាំង** **ពាក្យផ្ទុយ** **ខ្សោយ**

**ខ្លាំង** *គុ.* ដែលមានកម្លាំងច្រើន។

**ខ្សោយ** *គុ.* ដែលមានកម្លាំងតិច។

📖 **ខ្វះ** **ពាក្យផ្ទុយ** **គ្រប់**

**ខ្វះ** *កិ.* ឬ *គុ.* ដែលមិនគ្រប់តាមខ្នាតកម្រិត :

❖ ខ្វះតែ២ទៀតនឹងគ្រប់ជា១០។

**គ្រប់** *គុ.* ពេញត្រឹម :

❖ របស់នេះគ្រប់ចំនួនគ្មានខ្វះ។

📖 **ខ្សែលាម** **ពាក្យផ្ទុយ** **ខ្សែស្រលៀង**

**ខ្សែលាម** *ន.* ខ្សែវែងមានតែក្រវិលឥតស្រលៀងសម្រាប់ចងតពីខ្សែបង្គត់មកបន្លាយឱ្យគោដើរស៊ីស្មៅក្នុងទីវាល។

**ខ្សែស្រលៀង** *ន.* ខ្សែមានស្រលៀង។

📖 **គតសញ្ញា** **ពាក្យផ្ទុយ** **អាគតសញ្ញា**

**គតសញ្ញា** *ន.* (បា.) គ្រឿងសម្គាល់មួយបែបមានសណ្ឋានដូច្នេះ ">" មានន័យថា "ទៅជា ឬ កើតទៅជា" សម្រាប់ប្រើក្នុងការពន្យល់ប្រភពពាក្យជាសមាសនាមជាដើមដែលកាត់បទញែកចេញឱ្យដាច់ដោយឡែកពីគ្នា ហើយរួមបញ្ចូលគ្នាទៅវិញដូចជា :

➥ ជល + អាសយ > ជលាសយ។

**អាគតសញ្ញា** *ន.* (ឞា.) សញ្ញាប្រាប់សេចក្ដីថាមកពីមានរូបសណ្ឋានជាធ្នូ (<) នេះ, សម្រាប់ប្រើប្រាប់សេចក្ដីឱ្យដឹងថា សព្ទនេះមានប្រភពមកពីសព្ទនោះដូចជា :

➷ ឧស្សនាការ < ឧស្សន + អាការ (ឧស្សនាការ មកពី ឧស្សន និង អាការ) ជាដើម, ជាគូគ្នានឹង គតសញ្ញា (>) នេះដែលត្រូវប្រើជា ឧស្សន + អាការ > ឧស្សនាការ (ឧស្សន និង អាការ ទៅជា ឧស្សនាការ)។

📖 **គរុ** **ពាក្យផ្ទុយ** **លហុ**

**គរុ** *គុ.* (ឞា.) ធ្ងន់, យូរ។

**លហុ** *គុ.* (ឞា.) ឆាប់, ភ្លាម, រហ័ស, រប៉ិចរប៉ុ, រាយរង, ស្រាល, ...។

📖 **គរុកាបត្តិ** **ពាក្យផ្ទុយ** **លហុកាបត្តិ**

**គរុកាបត្តិ** *ន.* (ឞា.) អាបត្តិធ្ងន់ គឺអាបត្តិ២កងតាំងពី បារាជិក ចុះទៅដល់ សង្ឃាទិសេស (ព.វិ.ពុ.)។

**លហុកាបត្តិ** *ន.* (ឞា.) អាបត្តិស្រាល គឺអាបត្តិ៥កងតាំងពី ថុល្លច្ច័យ ចុះទៅដល់ ទុព្ភាសិត (ព.វិ.ពុ.)។

📖 **គរុភណ្ឌ** **ពាក្យផ្ទុយ** **លហុភណ្ឌ**

**គរុភណ្ឌ** *ន.* (ឞា.) ទ្រព្យ២៥ឈ្មោះជារបស់សង្ឃ (ព.ពុ.វិ.)។

**លហុកណ្ឌ** *ន.* (បា.) បរិក្ខាររាយរង, របស់រាយរង; ក្នុងវិន័យពុទ្ធសាសនា សំដៅរបស់រាយរងមានបាត្រនិងចីវរជាដើម។

📖 **គុណ** **ពាក្យផ្ទុយ** **អគុណ**

**គុណ** *ន.* សេចក្ដីចម្រើន; ថ្នាក់, ជាន់; លក្ខណៈ; ចំណែក; សេចក្ដីល្អ; សភាព; បែបបទ, ...។

**អគុណ** *ន.* (បា.សំ.) សភាពមិនមែនជាគុណ (ទោស)។

📖 **គុណកថា** **ពាក្យផ្ទុយ** **អគុណកថា**

**គុណកថា** *ន.* សម្ដីដែលជាគុណ។

**អគុណកថា** *ន.* សម្ដីដែលជាទោស។

📖 **គុណទាន** **ពាក្យផ្ទុយ** **អគុណទាន**

**គុណទាន** *ន.* សម្ដីដែលជាគុណ។

**អគុណទាន** *ន.* សម្ដីដែលជាទោស។

📖 **គុណភាព** **ពាក្យផ្ទុយ** **អគុណភាព**

**គុណភាព** *ន.* ភាវៈជាគុណ, ដំណើរជាគុណ។

**អគុណភាព** *ន.* ភាវៈជាទោស, ដំណើរជាទោស។

📖 **គោចរ** **ពាក្យផ្ទុយ** **អគោចរ**

**គោចរ** *ន.* (បា.សំ.) វិស័យ, ដំណើរនៃឥន្ទ្រិយគឺ រូប, សំឡេង, ក្លិន, រស, សម្ផស្ស។ ដំណើរឃាត្រាទៅរកអាហារចំណី, ទីដែលមានអាហារចំណី, ទីដែលសមណៈគួរត្រាច់ចរទៅបានតាមពុទ្ធានុញ្ញាត។

**អគោចរ** *ន.* (បា.សំ.) ទីដែលមិនគួរទៅ; ទីដែលបព្វជិតពុំគួរទៅ :

- ❖ លំនៅពេស្យា
- ❖ លំនៅស្ត្រីមេម៉ាយ
- ❖ លំនៅក្រមុំចាស់
- ❖ លំនៅភិក្ខុនី
- ❖ លំនៅបណ្ឌក
- ❖ ទីប្រជុំផឹកសុរាឬរោងលក់សុរា។

☆ ទាំង៦កន្លែងនេះជា អគោចរ, បព្វជិតពុទ្ធសាសនិកពុំគួរទៅឡើយ។

📖 **គោចរដ្ឋាន ពាក្យផ្ទុយ អគោចរដ្ឋាន**

**គោចរដ្ឋាន** *ន.* (បា.) ឋានជាគោចរ, ដោយបរិយាយ, តាមតែទីណាៗក៏ដោយដែលយល់ថាគួរត្រាច់ចរទៅក៏សុទ្ធតែជាគោចរដ្ឋានទាំងអស់។

**អគោចរដ្ឋាន** *ន.* (បា.) ឋានជាអគោចរ, ដោយបរិយាយ, តាមតែទីណាៗក៏ដោយដែលយល់ថាពុំគួរត្រាច់ចរទៅក៏សុទ្ធតែជាអគោចរដ្ឋានទាំងអស់។

📖 **គំនូស** **ពាក្យផ្ទុយ** **ឃ្នូស**

**គំនូស** *ន.* ស្នាមគូស :

❖ ធ្វើតាមគំនូសស្រាប់។

**ឃ្នូស** *ន.* ប្រដាប់សម្រាប់គូស :

❖ បន្ទាត់ជាឃ្នូសគូសឱ្យមានស្នាមជាខ្សែត្រង់។

📖 **គ្មាន** **ពាក្យផ្ទុយ** **មាន**

**គ្មាន** *ន.* ពាក្យបដិសេធប្រាប់សេចក្ដីថា មិនមាន, ឥត។

**មាន** *កិ.* បាន, កប, ប្រកបដោយ, កើត, បរិបូរដោយ, គង់នៅ, ឋិតនៅ។

📖 **គ្មានកូន** **ពាក្យផ្ទុយ** **មានកូន**

**គ្មានកូន** *កិ.* មិនបានកូន។

**មានកូន** *កិ.* បានកូន។

📖 **គ្មានកំណើត** **ពាក្យផ្ទុយ** **មានកំណើត**

**គ្មានកំណើត** *គុ.* ដែលធ្វើអ្វីៗចេះតែខូចប្រយោជន៍, មិនមានសំណាង :

❖ មនុស្សគ្មានកំណើត។

**មានកំណើត** *គុ.* ដែលធ្វើអ្វីៗចេះតែកបកើតប្រយោជន៍, មានសំណាង :

❖ មនុស្សមានកំណើត។

📖 **គ្មានខ្លាស ពាក្យផ្ទុយ មានខ្លាស**

**គ្មានខ្លាស** *គុ.* បរិបូរដោយសេចក្ដីមិនខ្មាស :

❖ មនុស្សគ្មានខ្មាស។

**មានខ្លាស** *គុ.* បរិបូរដោយសេចក្ដីខ្មាស :

❖ មនុស្សមានខ្មាស។

📖 **គ្មានគំនិត ពាក្យផ្ទុយ មានគំនិត**

**គ្មានគំនិត** *គុ.* ដែលគ្មានការគិតច្រើន, គ្មានមារយាទ។

**មានគំនិត** *គុ.* ដែលមានការគិតច្រើន, មានមារយាទ។

📖 **គ្មានចិត្ត ពាក្យផ្ទុយ មានចិត្ត**

**គ្មានចិត្ត** *គុ.* ដែលគ្មានសេចក្ដីប្រឹងប្រែង, ដែលច្រអូស, ដែលទម្រន់, ដែលមើលបំណាំ។

**មានចិត្ត** *គុ.* ដែលបរិបូរដោយសេចក្ដីប្រឹងប្រែង, ដែលមិនច្រអូស, ដែលមិនទម្រន់, ដែលមិនមើលបំណាំ។

📖 **គ្មានចិត្តគ្មានថ្លើម ពាក្យផ្ទុយ មានចិត្តមានថ្លើម**

**គ្មានចិត្តគ្មានថ្លើម** *គុ.* ដែលគ្មានសេចក្ដីប្រឹងប្រែង, ដែលច្រអូស, ដែលទម្រន់, ដែលមើលបំណាំ។

**មានចិត្តមានថ្លើម** *គុ.* ដែលបរិបូរដោយសេចក្ដីប្រឹងប្រែង, ដែលមិនច្រអូស, ដែលមិនទម្រន់, ដែលមិនមើលបំណាំ។

📖 **គ្មានចំណេះ ពាក្យផ្ទុយ មានចំណេះ**

**គ្មានចំណេះ** *គុ.* គ្មានការចេះដឹង, គ្មានវិជ្ជា :

❖ មនុស្សគ្មានចំណេះ។

**មានចំណេះ** *គុ.* បរិបូរដោយការចេះដឹង, មានវិជ្ជា :

❖ មនុស្សមានចំណេះ។

📖 **គ្មានច្បាប់ ពាក្យផ្ទុយ មានច្បាប់**

**គ្មានច្បាប់** *គុ.* ដែលមិនកាន់ត្រឹមត្រូវតាមច្បាប់, ដែលមិនប្រកាន់តាមច្បាប់, ដែលមិនសុភាពរាបសា, ដែលមិនចេះគួរសមឆ្គង។

**មានច្បាប់** *គុ.* ដែលកាន់ត្រឹមត្រូវតាមច្បាប់, ដែលប្រកាន់តែតាមច្បាប់, ដែលមានសុភាពរាបសាចេះគួរចេះសមមិនឆ្គង។

📖 **គ្មានជីវិត ពាក្យផ្ទុយ មានជីវិត**

**គ្មានជីវិត** *គិ.* ឥតជីវិតនៅ, គ្មានជីវិតរស់នៅ។

**មានជីវិត** *កិ.* គង់ជីវិតនៅ, រស់នៅ។

📖 **គ្មានតម្រិះ ពាក្យផ្ទុយ មានតម្រិះ**

**គ្មានតម្រិះ** *កិ.* មានតែខាងការត្រិះរិះខុស, ត្រិះរិះអាក្រក់។

**មានតម្រិះ** *កិ.* ឬ *គុ.* ដែលចេះត្រិះរិះត្រូវ; និយាយឱ្យពេញថាមានតម្រិះត្រូវ, មានតម្រិះល្អ។

📖 **គ្មានត្រកូល ពាក្យផ្ទុយ មានត្រកូល**

**គ្មានត្រកូល** *គុ.* ដែលមិនកើតក្នុងត្រកូលខ្ពស់, ដែលមិនកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

**មានត្រកូល** *គុ.* ដែលកើតក្នុងត្រកូលខ្ពស់, ដែលកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

📖 **គ្មានទ្រព្យ ពាក្យផ្ទុយ មានទ្រព្យ**

**គ្មានទ្រព្យ** *គុ.* ខ្សត់ទ្រព្យ, ទ័ល, ដែលមិនសូវមានទ្រព្យសម្បត្តិ។

**មានទ្រព្យ** *គុ.* ដែលបរិបូរដោយទ្រព្យសម្បត្តិ។

📖 **គ្មានធម៌សប្បុរស ពាក្យផ្ទុយ មានធម៌សប្បុរស**

**គ្មានធម៌សប្បុរស** *គុ.* ដែលមិនប្រព្រឹត្តដោយមេត្តាករុណា, ដែលមិនប្រកាន់សុចរិតដោយមេត្តាករុណា, ដែលមិនមានចិត្តប្រកបដោយមេត្តាករុណា។

**មានធម៌សប្បុរស** *គុ.* ដែលប្រព្រឹត្តដោយមេត្តាករុណា, ដែលប្រកាន់សុចរិតដោយមេត្តាករុណា, ដែលមានចិត្តប្រកបដោយមេត្តាករុណា។

📖 **គ្មានបុណ្យ ពាក្យផ្ទុយ មានបុណ្យ**

**គ្មានបុណ្យ** *កិ.* គ្មានភព្វ, មិនមានសំណាងខ្ពស់, មិនមានយសសក្តិ។

**មានបុណ្យ** *កិ.* មានភព្វ, មានសំណាងខ្ពស់, មានយសសក្តិ។

📖 **គ្មានដៅ ពាក្យផ្ទុយ មានដៅ**

**គ្មានដៅ** *គុ.* ដែលមិនកើតក្នុងត្រកូលខ្ពស់, ដែលមិនកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

**មានដៅ** *គុ.* ដែលកើតក្នុងត្រកូលខ្ពស់, ដែលកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

📖 **គ្មានពូជ ពាក្យផ្ទុយ មានពូជ**

**គ្មានពូជ** *គុ.* ដែលមិនកើតក្នុងត្រកូលខ្ពស់, ដែលមិនកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

**មានពូជ** *គុ.* ដែលកើតក្នុងត្រកូលខ្ពស់, ដែលកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

📖 **គ្មានព្រេង ពាក្យផ្ទុយ មានព្រេង**

**គ្មានព្រេង** *កិ.* គ្មានអំពើកសាងមកពីព្រេងនាយ។

**មានព្រេង** *កិ.* មានអំពើកសាងមកពីព្រេងនាយ។

📖 **គ្មានភព្វ ពាក្យផ្ទុយ មានភព្វ**

**គ្មានភព្វ** *កិ.* គ្មានសំណាងគួរដល់សេចក្តីសុខចម្រើន, គ្មានសំណាងពុំគួរឱ្យអ្នកធំសង្គ្រោះបាន :

❖ មនុស្សគ្មានភព្វ។

**មានភព្វ** *កិ.* មានសំណាងគួរដល់សេចក្ដីសុខចម្រើន, មានសំណាងគួរឱ្យអ្នកធំសង្គ្រោះបាន ៖

❖ មនុស្សមានភព្វ។

🕮 **គ្មានមារយាទ ពាក្យផ្ទុយ មានមារយាទ**

**គ្មានមារយាទ** *គុ.* ដែលគ្មានមារយាទល្អ, ដែលគ្មានឫកពានឹងធឹង, ដែលមិនស្លូតបូត។

**មានមារយាទ** *គុ.* ដែលមានមារយាទល្អ, ដែលមានឫកពានឹងធឹង, ដែលស្លូតបូត។

🕮 **គ្មានសម្បត្តិ ពាក្យផ្ទុយ មានសម្បត្តិ**

**គ្មានសម្បត្តិ** *គុ.* ខ្សត់សម្បត្តិ, ទ័លសម្បត្តិ, ដែលមិនសូវមានទ្រព្យសម្បត្តិ។

**មានសម្បត្តិ** *គុ.* ដែលបរិបូរដោយទ្រព្យសម្បត្តិ។

🕮 **គ្មានសំណាង ពាក្យផ្ទុយ មានសំណាង**

**គ្មានសំណាង** *កិ.* គ្មានអំពើកសាងមកពីព្រេងនាយ។

**មានសំណាង** *កិ.* មានអំពើកសាងមកពីព្រេងនាយ។

🕮 **គ្មានអម្បូរ ពាក្យផ្ទុយ មានអម្បូរ**

**គ្មានអម្បូរ** *គុ.* ដែលមិនកើតក្នុងត្រកូលខ្ពស់, ដែលមិនកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

**មានអម្បូរ** *គុ.* ដែលកើតក្នុងត្រកូលខ្ពស់, ដែលកើតក្នុងត្រកូលមានកេរ្តិ៍ឈ្មោះ។

📖 **គ្មានអំពើ** **ពាក្យផ្ទុយ** **មានអំពើ**

**គ្មានអំពើ** *កិ.* ឬ *គុ.* គ្មានប្រយោជន៍; ដែលគ្មានការធ្វើ។

**មានអំពើ** *កិ.* ឬ *គុ.* មានប្រយោជន៍; ដែលមានការធ្វើ។

📖 **គ្រហស្ថ** **ពាក្យផ្ទុយ** **បព្វជិត**

**គ្រហស្ថ** *ន.* (សំ.ភ្ល.) អ្នកមានផ្ទះ, អ្នកគ្រប់គ្រងផ្ទះ គឺអ្នកមានគ្រួសារ។

**បព្វជិត** *ន.* (បា.) អ្នកបួស។

📖 **ឃោស** **ពាក្យផ្ទុយ** **អឃោស**

**ឃោស** *ន.* (បា.) សូរសំឡេងគឹកកង, ឈ្មោះព្យញ្ជនៈដែលមានសំឡេងគឹកកងមាន២១តួគឺ គឃង, ជឈញ, ឌឍណ, ទធន, ពភម, យរលវហឡ; និងស្រៈពេញតួទាំងអស់ក៏រាប់បញ្ចូលក្នុងពួកអក្សរឃោសដែរ។

**អឃោស** *គុ.* (បា.) ដែលមិនគឹកកង, ដែលមានសូរសព្ទមិនកងរំពង។

*ន.* អក្សរដែលមានសំឡេងមិនគឹកកង, មាន១១តួគឺ កខ, ចឆ, ដឋ, តថ, បផ; ស, បើរាប់ ឝ, ឞ តាមសំស្ក្រឹតផ្សំផងជា១៣តួ (ព.វ.)។

📖 **ងងឹត ពាក្យផ្ទុយ ភ្លឺ**

**ងងឹត** *គុ.* ទីទៃពីភ្លឺ, ដែលឥតមានពន្លឺ :

❖ ខែងងឹត។

**ភ្លឺ** *កិ.* បញ្ចេញពន្លឺ, ឱ្យពន្លឺ; យល់ច្បាស់ :

❖ ខែភ្លឺ។

📖 **ចងបត់ចន្ទាស ពាក្យផ្ទុយ ចងសម្លាប់មុខ**

**ចងបត់ចន្ទាស** *កិ.* ក្បួចចំណងមួយបែបផ្ទុយពីចងសម្លាប់មុខ គឺទាញកន្ទុយខ្សែចំណងម្ខាងមិនឱ្យផុតស្រលះពីរង្វង់ចំណង។

**ចងសម្លាប់មុខ** *កិ.* ក្បួចចំណងមួយបែបផ្ទុយពីចងបត់ចន្ទាស គឺទាញកន្ទុយខ្សែចំណងម្ខាងឱ្យផុតស្រលះពីរង្វង់ចំណង។

📖 **ចង្អៀត ពាក្យផ្ទុយ រលុង**

**ចង្អៀត** *កិ.* ឬ *គុ.* ទីទៃពីទូលាយ :

❖ ផ្ទះចង្អៀត

❖ ចង្អៀតចិត្ត។

**រលុង** *គុ.* ដែលមិនចង្អៀត, ដែលមិនក្ដំ :

❖ ដងចបរលុង

❖ ផ្លែអម្ពិលទុំរលុងសំបក។

📖 **ចតុក្កោណ ពាក្យផ្ទុយ ត្រយង្ស**

**ចតុក្កោណ** *គុ.* ដែលមានជ្រុង៤។

**ត្រយង្ស** *គុ.* ដែលមានជ្រុង៣។

📖 **ចន្ទគត ពាក្យផ្ទុយ សុរិយគត**

**ចន្ទគត** *ន.* (បា.) ដំណើរព្រះចន្ទ :

❖ ខែចន្ទគតិ។

**សុរិយគត** *ន.* (បា.) ដំណើរព្រះអាទិត្យ :

❖ ខែសុរិយគតិ។

📖 **ចម្អាប ពាក្យផ្ទុយ បង្អែម**

**ចម្អាប** *ន.* អាហារដែលមានរសទីទៃពីផ្អែម គឺដែលមានឱជារសដោយលាយអ្អាប (ធ្វើឱ្យដោយត្រីនិងសាច់ជាដើម)។

**បង្អែម** *ន.* ចំណីផ្អែម។

📖 **ចាក ពាក្យផ្ទុយ ពី, អំពី**

**ចាក** *អ.និ.* ពាក្យប្រាប់ដំណើរចៀសស្រលះ, វៀរលែងស្រលះ, លែងប្រព្រឹត្ត, លែងធ្វើវិញទៀត, ចេញទៅហើយមិនមកវិញទេ, ចេញទៅហើយ

មិនមានបំណងថានឹងបានមកទៀត :

❖ វៀរចាកទុច្ចរិត។

**ពី** ***និ.; អា.និ.*** អំពី; ខាង, ឯ :

❖ សម្ដីចេញពីមាត់។

**អំពី** ***អា.និ.*** ពី; ឯ, ខាង  :

❖ ភ័យអំពីមរណៈ។

📖 **ចុត** **ពាក្យផ្ទុយ** **បដិសន្ធិ**

**ចុត** ***ន.*** (**បា.**) ដំណើរដែលឃ្លាតចាកជីវិត គឺសេចក្ដីស្លាប់។

**បដិសន្ធិ** ***ន.*** (**បា.**) តំណកំណើតសត្វ :

❖ ចាប់បដិសន្ធិក្នុងផ្ទៃមាតា។

📖 **ចូល** **ពាក្យផ្ទុយ** **ចេញ**

**ចូល** ***កិ.*** ទីទៃពីចេញ គឺទៅពីខាងក្រៅទៅកាន់ខាងក្នុង :

❖ ចូលក្នុងបន្ទប់។

**ចេញ** ***កិ.*** ឃ្លាតពីទីមួយទៅកាន់ទីមួយ :

❖ ចេញពីផ្ទះទៅសាលារៀន។

📖 **ចេស្ដា** **ពាក្យផ្ទុយ** **អចេស្ដា**

**ចេស្ដា** *ន.* (សំ.) សេចក្ដីខ្មីឃ្មាត, សេចក្ដីសង្វាត, សេចក្ដីប្រឹងប្រែង; ដំណើរតាំងចិត្តប្រុងនឹងធ្វើ; ដំណើរកម្រើកអវយវៈតូចធំមានលើដៃជើង វាសដៃជើងឬងាកបែរជាដើម។

**អចេស្ដា** *ន.* (សំ.) ដំណើរឥតចេស្ដា គឺដំណើរទន់ខ្សោយ, ដំណើរអស់កម្លាំង, ដំណើរអស់ការប្រឹងប្រែង; ដំណើរកម្រើកអវយវៈមិនកើត។

📖 **ចៃដន់ ឬ ចៃដន្យ ពាក្យផ្ទុយ អចៃដន្យ ឬ អចៃតន្យ**

**ចៃដន់ ឬ ចៃដន្យ** *កិ.* ឬ *ន.* (សំ. **ចៃតន្យ** *ន.* "អាត្ម័ន, អាត្មា, ព្រលឹង, ចិត្ត; ទេវតាដែលជាអ្នកនាំបណ្ដាលចិត្ត, ទេវតាដែលជាអ្នកបញ្ឆេលចិត្ត..."។

☞ បណ្ដាលឱ្យគិត, បណ្ដាលឱ្យនឹកភ្នកឃើញ; ដំណើរដែលបណ្ដាលឱ្យកើតមានឡើងហាក់ដូចជាមានទេវតានាំបណ្ដាល :

❖ ការណ៍ហ្នឹងវាជាចៃដន្យ។

**អចៃដន្យ ឬ អចៃតន្យ** *ន.* (សំ. **អចៃតន្យ**) ដំណើរមិនបណ្ដាលឱ្យគិតឃើញ, ការបាំងគំនិត, ការនាំឱ្យបាំងគំនិត :

❖ ដំណើរនុះជាអចៃដន្យ។

📖 **ចំណាញ់ ពាក្យផ្ទុយ ជម្លះ**

**ចំណាញ់** *ន.* ការចាញ់ :

❖ ចំណាញ់កលរបស់គេនាំឱ្យអាប់កិត្តិយស។

**ជម្នះ** ***ន.*** ការឈ្នះ, សេចក្តីឈ្នះ, ដំណើរដែលឈ្នះ :

❖ ចាំមើលរឿងនេះជម្នះនឹងបានទៅខាងណា?

📖 **ចំអាម** **ពាក្យផ្ទុយ** **ទោម**

**ចំអាម** ***ន.*** រង្វាស់វែងប្រវែងពីត្រឹមចុងមេដៃទៅចុងម្រាមកណ្តាលញែកតឹងពីគ្នា (ប្រវែង១២ធ្នាប់)។

**ទោម** ***ន.*** រង្វាស់វែងប្រវែងពីត្រឹមចុងមេដៃទៅចុងចង្អុលដៃដែលញែកឱ្យតឹងកន្លែកពីគ្នា (ប្រវែង១ទោម)។

📖 **ចាំ** **ពាក្យផ្ទុយ** **ភ្លេច**

**ចាំ** ***កិ.*** នឹកឃើញ, មិនភ្លេច, កត់ជាប់នៅក្នុងស្មារតី, កត់ជាប់ក្នុងការនឹកឃើញមិនភ្លេចភ្លាំង :

❖ ចាំមេរៀន។

**ភ្លេច** ***កិ.*** ចាំមិនបាន, នឹកមិនឃើញ :

❖ ភ្លេចអក្សរ។

📖 **ចេះ** **ពាក្យផ្ទុយ** **ល្ងង់**

**ចេះ** ***កិ.*** ដឹងជាក់, យល់ជាក់ :

❖ ចេះអក្សរ។

**ល្ងង់** ***កិ.*** មិនចេះ, មិនយល់ :

❖ ខ្ញុំល្ងង់គិតមិនលេច។

📖 **ច្រើន ពាក្យផ្ទុយ តិច**

**ច្រើន** ***គុ.*** ដែលចំនួនមិនតិច, ដែលក្រាស់ក្រែល, តាំងពីចំនួនពីរឡើងទៅ។

**តិច** ***គុ.*** ទីទៃពីច្រើន គឺដែលមានចំនួនថយចុះទុកជាបរិបូណ៌ពុំបាន។

📖 **ឆាប់ ពាក្យផ្ទុយ យឺត, យូរ**

**ឆាប់** ***កិ.១.*** ដែលប្រញាប់, ដែលរួសរាន់, ដែលរៃៗ :

❖ ដើរឆាប់

❖ ទៅឆាប់ៗ។

**យឺត** ***កិ.១.*** ឬ ***គុ.*** ដែលមិនរហ័ស, ដែលមិនរួសរាន់ :

❖ ធ្វើការយឺត

❖ ដំណើរយឺត។

**យូរ** ***កិ.១.*** ឬ ***គុ.*** ដែលមិនឆាប់, ដែលយឺត, ដែលអង្វែង :

❖ កាលយូរ

❖ ប្រើបានយូរ។

📖 **ឆ្អែង** **ពាក្យផ្ទុយ** **ស្ទាត់**

**ឆ្អែង** *គុ.* ដែលមិនកប (ច្រើននិយាយតែក្នុងការនេសាទ) :

❖ ថ្ងៃនេះឆ្អែងណាស់រកត្រីមិនបានសោះ។

**ស្ទាត់** *គុ.* ដែលចេះតែសមប្រកបនឹងការស្វែង, ដែលចេះតែជួបប្រទះលាភ, ដែលចេះតែងាយប្រទះ, ដែលងាយបាន :

❖ មនុស្សស្ទាក់លាភ។

📖 **ជ័យ** **ពាក្យផ្ទុយ** **បរាជ័យ**

**ជ័យ** *ន.* (បា.ភ្ន.) ជម្នះ, ការឈ្នះ :

❖ មានជ័យ

❖ ហៅយកជ័យ។

**បរាជ័យ** *ន.* (បា.សំ.ភ្ន.) ការចាញ់គេ, ដំណើរចាញ់គេ។

📖 **ជលបថ** **ពាក្យផ្ទុយ** **ថលបថ**

**ជលបថ** *ន.* (បា.) ផ្លូវទឹក, ជើងទឹក។

**ថលបថ** *ន.* (បា.) ផ្លូវគោក, ជើងគោក។

📖 **ជលយាត្រា** **ពាក្យផ្ទុយ** **ថលយាត្រា**

**ជលយាត្រា** *ន.* (បា.សំ.) ការដើរតាមផ្លូវទឹក, ដំណើរខាងផ្លូវទឹក, ដំណើរ

ជើងទឹក។

**ថលយាត្រា** *ន.* (បា.សំ.) ការដើរផ្លូវគោក, ដំណើរផ្លូវគោក, ដំណើរជើងគោក; ការចិញ្ចឹមជីវិតដោយបរផ្លូវគោក។

📖 **ជលយាន ពាក្យផ្ទុយ ថលយាន**

**ជលយាន** *ន.* (បា.) យានជំនិះខាងផ្លូវទឹក, គ្រឿងដឹកនាំទៅមកខាងជើងទឹក។

**ថលយាន** *ន.* (បា.) យានសម្រាប់ផ្លូវគោក (មានរទេះជាដើម)។

📖 **ជាតលិង្គ ពាក្យផ្ទុយ សម្មុតលិង្គ**

**ជាតលិង្គ** *ន.* (បា.) លិង្គតាមជាតិគឺ ប្រុស, ស្រី, ឈ្មោល, ញី, ខ្ទើយ ដែលមានភេទស្រេចស្រាប់ពីកំណើតមកហើយ។

**សម្មុតលិង្គ** *ន.* (បា.) លិង្គដោយសន្មតិសម្រាប់ប្រើក្នុងតន្តិភាសាទាំងពួងមានភាសាសំស្រ្កឹតនិងភាសាបាលីជាដើម; សំស្រ្កឹតនិងបាលីកំណត់យកការន្តគឺស្រៈជាទីបំផុតនៃនាមសព្ទជាគោលឱ្យដឹងថា ជាបុំលិង្គ, ជាឥត្ថីលិង្គ, ជានបុំសកលិង្គ ដូចជា ទារ (ទារោ) "ប្រពន្ធ", មាតុគ្រាម ឬ មាតុគ្គាម (មាតុគ្គាមោ) "ស្ត្រី" នេះតាមរូបសេចក្ដីគួរតែជាឥត្ថីលិង្គ, ប៉ុន្តែរូបសព្ទជាអការន្ត-បុំលិង្គ ក៏ត្រលប់ជាបុំលិង្គទៅវិញ; បញ្ញា, សាលា ដែលពុំមែនជាប្រុសជាស្រីសោះទេ, តាមរូបសព្ទជា អាការន្ត-ឥត្ថីលិង្គ ក៏ត្រលប់ជាឥត្ថីលិង្គទៅវិញ; លិង្គយ៉ាង

នេះហៅថា សម្មតលិង្គ គឺលិង្គមានឈ្មោះដោយសន្មតិ (ព.វ.)។ ភាសាខ្មែរយើងគ្មានសម្មតិលិង្គនេះទេ។

📖 **ជានបទ** **ពាក្យផ្ទុយ** **នគរជន**

**ជានបទ** *គុ.* ឬ *ន.* (បា.សំ.) ដែលនៅក្នុងជនបទ, អ្នកជនបទ។

**នគរជន** *ន.* (បា.សំ.) ជនអ្នកនៅក្នុងក្រុង (អ្នកក្រុង)។ ប្រើឱ្យត្រឹមត្រូវតាមបែបបាលីជា នគរជន។

📖 **ជាមាតា** **ពាក្យផ្ទុយ** **សុណិសា ឬ សុណ្ហា**

**ជាមាតា** *ន.* កូនប្រសាប្រុស។

**សុណិសា** ឬ **សុណ្ហា** *ន.* (បា.) កូនប្រសាស្រី។

📖 **ជោរ** **ពាក្យផ្ទុយ** **នាច**

**ជោរ** *កិ.* ពោរឡើង :

- ❖ ទឹកជោរ។

**នាច** *កិ.* ស្រក, ថយចុះហើយនិងមានជោរឡើងវិញ (ទឹក) :

- ❖ ទឹកនាច។

📖 **ជំនោរ** **ពាក្យផ្ទុយ** **ឈំនាច**

**ជំនោរ** *ន.* ការដែលជោរ; ដំណើរដែលជោរ។ ឈ្មោះខ្យល់នាំទឹកឱ្យជោរ :

❖ ត្រូវជំនោរ

❖ ធ្លាក់ជំនោរ។

**លំនាច** *ន.* ការនាចនៃទឹក :

❖ លំនាចសមុទ្រ។

📖 **ជ្រៅ ពាក្យផ្ទុយ រាក់**

**ជ្រៅ** *គុ.* ទីទៃពីរាក់ គឺដែលមានជម្រៅ :

❖ ទឹកជ្រៅ

❖ អណ្ដូងជ្រៅ។

**រាក់** *គុ.* ទីទៃពីជ្រៅ គឺដែលមានជម្រៅតិច :

❖ ទឹករាក់

❖ រណ្ដៅរាក់។

📖 **ញាតិ, សាច់ញាតិ ពាក្យផ្ទុយ អញ្ញាតកជន, អ្នកដទៃ**

**ញាតិ** *ន.* (បា.) អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតាឬខាងបិតា; ដែលហៅថាញាតិ៧សន្ដានឬញាតិ៧ជួរនោះ តាមន័យក្នុងគម្ពីរពុទ្ធសាសនាលោកឱ្យរាប់ថ្នាក់ខាងលើ៣ជាន់ :

❖ ថ្នាក់មាតាបិតា១

❖ ថ្នាក់ជីដូនជីតា១

❖ ថ្នាក់យាយទួតតាទួត១

☞ ថ្នាក់ខាងក្រោមខ្លួន៣ជាន់ទៀត :

❖ ថ្នាក់កូន១

❖ ថ្នាក់ចៅ១

❖ ថ្នាក់ចៅទួត១

☞ រួមជា៦ថ្នាក់, ជា៧ថ្នាក់នឹងខ្លួនយើង; មនុស្សទាំងប៉ុណ្ណោះហៅថា ញាត៧សន្តាន។

**សាច់ញាត** *ន.* អ្នកដែលជាប់ជាញាតិនឹងគ្នា, អ្នកដែលជាប់ជាក្រសែញាតិ។

**អញ្ញាតកជន** *ន.* (បា.) ជនដែលមិនមែនជាញាតិ; អ្នកដទៃ, អ្នកកន្តៀត។

**អ្នកកន្តៀត** *ន.* ជនឯទៀតក្រៅពីញាតិ គឺជនដែលមិនមែនជាសាច់ញាតិ។

📖 **ញាតខទាន** **ពាក្យផ្ទុយ** **ញាតសាមគ្គី**

**ញាតខទាន** *ន.* (បា.) សេចក្តីទាស់ទែងនៃញាតិ, ជម្លោះនៃពួកញាតិ។

**ញាតសាមគ្គី** *ន.* (បា.) សេចក្តីព្រមព្រៀងរបស់ញាតិ។

📖 **ញាប់** **ពាក្យផ្ទុយ** **រង្វើល**

**ញាប់** *កិ.វិ.* ឬ *គុ.* បន្ទាន់ៗ ញឹកៗ, រន្ទាន់ :

❖ ដើរញាប់ជើង

❖ និយាយញាប់។

**រង្វើល** *កិ.១* ឬ *គុ.* ដែលមិនញឹក, ដែលមិនញាប់ គឺល្បោះៗ, ច្បោលៗ, មួយៗ :

❖ ស្ទូងរង្វើលៗ

❖ និយាយរង្វើលៗ។

📖 **ញ៉ាម** **ពាក្យផ្ទុយ** **ទ្រាន់**

**ញ៉ាម** *កិ.* ជាប់ចិត្ត, ញៀនចិត្ត :

❖ ធ្លាប់បានស៊ីឆ្ងាញ់ម្ដងហើយវាចេះតែញ៉ាមតទៅទៀត។

**ទ្រាន់** *កិ.* ធុញណាយនឹងអាហារចំណីដដែលៗមិនចង់បរិភោគឬដោយធ្វើអ្វីៗហួសកម្លាំងនាំឱ្យមានចិត្តមិនចង់ធ្វើតទៅទៀត :

❖ កុំស្លម្ជូរដដែលៗខ្ញុំទ្រាន់ណាស់ទទួលទានមិនកើតទេ។

📖 **ញី** **ពាក្យផ្ទុយ** **ឈ្មោល**

**ញី** *គុ.* ដែលមានភេទជាស្រី; ប្រើចំពោះតែសត្វតិរច្ឆាននិងដើមឈើខ្លះ :

❖ គោញី

❖ ត្នោតញី។

**ឈ្មោល** *គុ.* ដែលមានភេទជាប្រុស; ដែលនិយាយតែពីសត្វតិរច្ឆាននិងដើម

ឈើខ្លះ :

❖ គោឈ្មោល

❖ ត្នោតឈ្មោល។

📖 **ដាក់បាត្រ** **ពាក្យផ្ទុយ** **រាប់បាត្រ**

**ដាក់បាត្រ** ***កិ.*** ប្រមូលអាហារឱ្យជាដុំដាក់ក្នុងបាត្រ គឺចង្ហាន់ដាក់ក្នុងបាត្រ។

**រាប់បាត្រ** ***កិ.*** ដាក់បាយក្នុងបាត្រដូចគេរាប់ គឺដួសបាយនឹងវែកដាក់ក្នុងបាត្រភិក្ខុសង្ឃដែលដាក់រៀបដង្ហែគ្នា, ដោយគ្មេរបាយឱ្យល្មមគ្រប់គ្រាន់តាមចំនួនបាត្រ។

📖 **ដុំ** **ពាក្យផ្ទុយ** **រាយ**

**ដុំ** ***ន.*** កំណាត់, បំណែក, កង់; ភាគដែលជាប់មូលគ្នា, ដែលរួមគ្នា :

❖ ដុំឥដ្ឋ

❖ ស្ករ១ដុំ។

**រាយ** ***កិ.*** ដាក់អ្វីៗពីសពាសមិនមូលគ្នា, ដាក់អ្វីៗពីសពាសឥតសណ្ដាប់ធ្នាប់ :

❖ រាយអីវ៉ាន់ពេញផ្ទះ

❖ ក្មេងរាយសំរាមកញ្ចៀំមុខផ្ទះ។

📖 **តចសារជាតិ** **ពាក្យផ្ទុយ** **អន្ទោសារជាតិ**

**គចសារជាត** *ន.* (ធរ.) ជាតិឈើដែលមានសំបកជាខ្លឹមឬមានខ្លឹមនៅត្រង់សំបក ដូចយ៉ាង ឫស្សី, ត្នោត, ដូង ជាដើម។

**អន្តោសារជាត** *ន.* (ធរ.) ឈើដែលមានខ្លឹមខាងក្នុង (ឈើខ្លឹម)។

📖 **តាជី** **ពាក្យផ្ទុយ** **ដូនជី**

**តាជី** *ន.* បុរសដែលកោរសក់ស្លៀកដណ្ដប់សំពត់សឬសំពត់លឿងកាន់សីល ១០តែមិនមែនបួសជាសាមណេរទេ។ សូម្បីបុរសជាចាស់ព្រឹទ្ធាចារ្យឯទៀតក្រៅពីនោះពាក្យបុរាណក៏ហៅដោយគោរពថា តាជី បានដែរ។

**ដូនជី** *ន.* យាយជី គឺឧបាសិកាដែលកោរសក់ស្លៀកដណ្ដប់សំពត់សឬសំពត់លឿងកាន់សីល១០ជានិច្ច (ច្រើនតែស្ត្រីចាស់ៗ, តែទោះបីស្ត្រីនៅក្មេងក៏ដោយបើប្រព្រឹត្តកាន់វត្តប្រតិបត្តិដូច្នេះក៏ហៅ ដូនជី ដែរ)។

📖 **តាវកាលិក** **ពាក្យផ្ទុយ** **យាវកាលិក**

**តាវកាលិក** *ន.* (ធរ.) វត្ថុដែលប្រព្រឹត្តទៅបានតែក្នុងកាលប៉ុណ្ណោះ, របស់ដែលកើតឡើង, របស់ដែលប្រើប្រាស់បានក្នុងកាលដ៏ខ្លី, របស់ដែលប្រើប្រាស់បានក្នុងកាលមានកម្រិត; របស់ខ្ចីគេ។

**យាវកាលិក** *គុ.* ឬ *ន.* (ធរ.) ដែលគួរប្រកបការបានតែត្រឹមពីព្រឹកទល់នឹងថ្ងៃត្រង់; ភោជនដែលពួកបព្វជិតឬឧបាសកអ្នកសមាទានឧបោសថសីល

ត្រូវបរិភោគបានតែត្រឹមពីព្រឹកទៅទល់នឹងថ្ងៃត្រង់ (ព.វិ.ពុ.)។

📖 **តឹង** **ពាក្យផ្ទុយ** **ធូរ**

**តឹង** *គុ.* ដែលចង្អៀត, ដែលណែន, ដែលសន្ធឹងរឹងត្រង់, ដែលទីទៃពីធូរ។

**ធូរ** *គុ.* ទីទៃពីតឹង គឺងាយ, ទូលាយ។

📖 **តុករង្វាន់** **ពាក្យផ្ទុយ** **រង្វាន់ចាំបាច់, រង្វាន់ប្រចាំឆ្នាំ**

**តុករង្វាន់** *ន.* រង្វាន់ដែលរាជការឬឯកជនប្រគល់ជាពិសេសដល់ជនដែលមានគុណវុឌ្ឍិគួរគេពេញចិត្តចង់ឱ្យ, ពុំមែនជារង្វាន់ចាំបាច់ដោយខានពុំបានទេ :

❖ សិស្ស១០នាក់បានទទួលតុករង្វាន់អំពីក្រសួងអប់រំជាតិ។

**រង្វាន់ចាំបាច់** *ន.* រង្វាន់ដែលរាជការឬឯកជនប្រគល់ជាពិសេសដល់ជនដែលគ្មានគុណវុឌ្ឍិគួរគេពេញចិត្តចង់ឱ្យ។

**រង្វាន់ប្រចាំឆ្នាំ** *ន.* រង្វាន់ដែលរាជការឬឯកជនប្រគល់ជាពិសេសដល់ជនដែលគ្មានគុណវុឌ្ឍិគួរគេពេញចិត្តចង់ឱ្យ, ពុំមែនជាតុករង្វាន់។

📖 **ត្រង់** **ពាក្យផ្ទុយ** **វៀច**

**ត្រង់** *គុ.* ទីទៃពីវៀច។ ដែលឃ្លាតចាកពីទី១ទៅកាន់ទី១ឥតងាកឥតបែរទៅខាងណាទាល់តែដល់ទៅទីនោះ, ដែលមានចុងមានគល់រត់ល្បត់ដូចវាយបន្ទាត់ :

❖ ផ្លូវត្រង់

❖ ចិត្តត្រង់។

**វៀច** *គុ.* ទីទៃពីត្រង់ គឺដែលមានរំពត់, មានរបត់, កោង, រមួល :

❖ ផ្លូវវៀច

❖ ចិត្តវៀច។

📖 **ត្រីកោណ** **ពាក្យផ្ទុយ** **ពហុកោណ**

**ត្រីកោណ** *គុ.* ដែលមានជ្រុង៣។

**ពហុកោណ** *គុ.* ដែលមានជ្រុងច្រើន។

📖 **ថេរវាទ** **ពាក្យផ្ទុយ** **អាចរិយវាទ**

**ថេរវាទ** *ន.* (បា.) ពាក្យរបស់ព្រះថេរៈ, ពាក្យដែលព្រះថេរៈនិយាយ។

**អាចរិយវាទ** *ន.* (បា.) ពាក្យរបស់អាចារ្យ, ពាក្យដែលអាចារ្យនិយាយ។

📖 **ថេរវាទី** **ពាក្យផ្ទុយ** **អាចរិយវាទី**

**ថេរវាទី** *ន.* (បា.) អ្នកដែលនិយាយតាមព្រះថេរៈ; ពួកថេរវាទ។

**អាចរិយវាទី** *ន.* (បា.) អ្នកដែលច្រើនតែពោលអាងពាក្យសម្ដីរបស់គ្រូ។

📖 **ថោក** **ពាក្យផ្ទុយ** **ថ្លៃ**

**ថោក** *គុ.* (បា.) ដែលមានតម្លៃតិច :

❖ ស្រូវថោក

❖ មនុស្សឫកថោក។

ថ្លៃ *កិ.វិ.* ឬ *គុ.* ដែលមានតម្លៃ :

❖ លក់ថ្លៃណាស់។

📖 **ឧក្ខិណនិកាយ ពាក្យផ្ទុយ ឧត្តរនិកាយ**

**ឧក្ខិណនិកាយ** *ន.* (បា.) ពួកខាងត្បូង គឺពួកពុទ្ធសាសនិកជនប៉ែកខាងត្បូង មានអ្នកលង្កាទ្វីប, ភូមា, មនជាដើមរៀងមកដល់កម្ពុជរដ្ឋយើងនេះដែល ពួកឧត្តរនិកាយកំណត់ហៅ ដើម្បីឱ្យដាច់ពួកដោយឡែកពីគ្នាក្នុងកាលដែល កើតអធិករណ៍ជាធំតបន្ទាប់អំពីកាលនៃទុតិយសង្គាយនាមក។

**ឧត្តរនិកាយ** *ន.* (បា.សំ.) ពួកខាងជើង គឺពួកពុទ្ធសាសនិកខាងលទ្ធិមហាយាន។

📖 **ឧក្ខិណាពត៌ ពាក្យផ្ទុយ ឧត្តរាពត៌**

**ឧក្ខិណាពត៌** *ន.* (បា. និង សំ.) ដំណើរដែលដើរវិលជាទក្សិណក្នុងឱកាស នៃកិច្ចការណាមួយមានការមង្គលជាដើម។

**ឧត្តរាពត៌** *ន.* (បា. និង សំ.) ដំណើរវិលទៅខាងឆ្វេងដើរជាឧត្តរាពត៌ដើរ វិលទៅខាងឆ្វេងជុំវិញទីណាមួយ។

📖 **ឧក្ខិណាវដ្ត ពាក្យផ្ទុយ ឧត្តរាវដ្ត**

**ឧក្ខិណាវដ្ត** *ន.* (បា.) ដំណើរដែលដើរវិលជាទក្សិណក្នុងឱកាសនៃកិច្ចការ

ណាមួយមានការមង្គលជាដើម។

**ឧត្តរាវដ្ត** *ន.* (បា.) ដំណើរវិលទៅខាងឆ្វេងដើរជាឧត្តរាវដ្តដើរវិលទៅខាងឆ្វេងជុំវិញទីណាមួយ។

**📖 ទឡ្ហមិត្ត ពាក្យផ្ទុយ សិថិលមិត្ត**

**ទឡ្ហមិត្ត** *ន.* (បា.) មិត្តខ្ជាប់ខ្ជួន គឺអ្នកដែលរាប់អានគ្នាដោយទុកចិត្ត។

**សិថិលមិត្ត** *ន.* (បា.) មិត្តដែលរាប់អានគ្នាបន្តិចបន្តួច។

**📖 ទឡ្ហមិត្រ ពាក្យផ្ទុយ សិថិលមិត្រ**

**ទឡ្ហមិត្រ** *ន.* (បា. និង សំ.) មិត្រខ្ជាប់ខ្ជួន គឺអ្នកដែលរាប់អានគ្នាដោយទុកចិត្ត។

**សិថិលមិត្រ** *ន.* (បា. និង សំ.) មិត្រដែលរាប់អានគ្នាបន្តិចបន្តួច។

**📖 ទាយក ពាក្យផ្ទុយ បដិគ្គាហក**

**ទាយក** *ន.* (បា.សំ.) បុរសអ្នកឱ្យទាន។

**បដិគ្គាហក** *ន.* (បា.) អ្នកទទួលយកទាន (ស្ទូម)។

**📖 ទាយិកា ពាក្យផ្ទុយ បដិគ្គាហិកា**

**ទាយិកា** *ន.* (បា.សំ.) ស្ត្រីអ្នកឱ្យទាន។

**បដិគ្គាហិកា** *ន.* (បា.) ស្ត្រីអ្នកទទួលយកទាន (ស្ទូម)។

**📖 ទារុណ ពាក្យផ្ទុយ អទារុណ**

**ទារុណ** *គុ.* (បា.សំ.) កាច, កាចអាក្រក់, អាក្រក់។

**អទារុណ** *គុ.* (បា.សំ.) ដែលមិនកាច (ស្លូត)។

📖 **ទារុណកម្ម** **ពាក្យផ្ទុយ** **អទារុណកម្ម**

**ទារុណកម្ម** *ន.* (បា.) អំពើកាច, អំពើអាក្រក់, អំពើសាហាវយង់ឃ្នង។

**អទារុណកម្ម** *ន.* (បា.) អំពើស្លូត; អំពើល្អ។

📖 **ទារុណភាព** **ពាក្យផ្ទុយ** **អទារុណភាព**

**ទារុណភាព** *ន.* (បា.សំ.ក្ល.) ភាវៈជាអ្នកកាច, ភាពជាអ្នកកាច; ភាវៈអាក្រក់, ដំណើរអាក្រក់, ការឃោរឃៅ។

**អទារុណភាព** *ន.* (បា.សំ.ក្ល.) ភាវៈស្លូត។

📖 **ទាល** **ពាក្យផ្ទុយ** **ស្រួច**

**ទាល** *គុ.* ទីទៃពីស្រួច, ដែលមានចុងគ្រមែល :

❖ ចុងកាំបិតទាល

❖ មុខពូថៅទាល។

**ស្រួច** *គុ.* ដែលកើតដោយសម្រួច; ដែលរៀវតូចខាងចុង; ដែលមានមុខតូចរៀវមុត :

❖ កំពូលស្រួច

❖ ស្រួចដូចម្ជុល។

📖 **ទិដ្ឋិវិបត្តិ** **ពាក្យផ្ទុយ** **ទិដ្ឋិសម្បត្តិ**

**ទិដ្ឋិវិបត្តិ** *ន.* (បា.) ការខូចដំណើរយល់ឃើញ គឺការភ្លាត់គំនិតយល់ឆ្វេងខុសពីផ្លូវត្រូវ, ការភ្លាត់គំនិតយល់ខុសពីផ្លូវធម៌វិន័យ។

**ទិដ្ឋិសម្បត្តិ** *ន.* (បា.) ការបរិបូណ៌ដោយដំណើរយល់ឃើញគឺការបរិបូណ៌ដោយដំណើរយល់ឃើញត្រូវតាមច្បាប់ឬតាមធម៌វិន័យ។

📖 **ទិនិកជន** **ពាក្យផ្ទុយ** **មាសិកជន**

**ទិនិកជន** *ន.* (សំ.) មនុស្សអ្នកស៊ីឈ្នួលថ្ងៃ គឺអ្នកធ្វើការយកឈ្នួលតាមកំណត់ថ្ងៃដែលបានធ្វើការ។

**មាសិកជន** *ន.* (បា.សំ.) មនុស្សអ្នកធ្វើការយកឈ្នួលខែ, អ្នកស៊ីឈ្នួលខែ; អ្នកស៊ីប្រាក់ខែ។

📖 **ទិនិកា** **ពាក្យផ្ទុយ** **មាសិកា**

**ទិនិកា** *ន.* (សំ.) ថ្លៃឈ្នួលដែលអ្នកជួលឱ្យដល់អ្នកស៊ីឈ្នួលតាមកំណត់ថ្ងៃដែលបានធ្វើការ (ឈ្នួលថ្ងៃ, ប្រាក់ប្រចាំថ្ងៃ)។

**មាសិកា** *ន.* (សំ.) ថ្លៃឈ្នួលខែ; ប្រាក់ខែ។

📖 **ទិវសភាគ** **ពាក្យផ្ទុយ** **រត្តិភាគ**

**ទិវសភាគ** *ន.* (បា.) ចំណែកនៃថ្ងៃ គឺពេញមួយថ្ងៃតាំងពីព្រឹកទាល់ល្ងាច។

**រត្តិភាគ** *ន.* (បា.) ចំណែកនៃរាត្រី គឺពេលយប់ទាំងមូល, វេលាពេញមួយយប់។

📖 **ទិវាករ** **ពាក្យផ្ទុយ** **និសាករ**

**ទិវាករ** *ន.* (បា.សំ.) អ្នកធ្វើនូវថ្ងៃ (ព្រះអាទិត្យ)។

**និសាករ** *ន.* (បា.) អ្នកធ្វើនូវយប់ (ព្រះចន្ទ)។

📖 **ទិវាចរ** **ពាក្យផ្ទុយ** **និសាចរ**

**ទិវាចរ** *គុ.* ឬ *ន.* (បា.សំ.) ដែលចរតែក្នុងវេលាថ្ងៃ, ដែលចេញរកស៊ីតែក្នុងវេលាថ្ងៃ; សត្វដែលចេញរកស៊ីតែក្នុងវេលាថ្ងៃវេលាយប់ឈប់ដេក :

- សេក
- លលក។

**និសាចរ** *ន.* (បា.) អ្នកត្រាច់ទៅមកក្នុងវេលាយប់។ ព្រាយអាកាស, បិសាចដើរយប់, ...។

*គុ.* ដែលត្រាច់ទៅមក, រកស៊ីក្នុងវេលាយប់ :

- មៀម
- ខ្លែងស្រាក។

📖 **ទីឃៈ** **ពាក្យផ្ទុយ** **រស្សៈ**

**ទីឃៈ** *គុ.* (**បា.សំ.**) វែង, អង្វែង, ដែលស្ថិតនៅបានយូរ។

*ន.* ស្រៈមានសំឡេងវែង, សម្រាប់ប្រើខាងភាសាបាលីមាន៥តួ គឺ អា, ឦ, ឩ, ឯ, ឱ; សម្រាប់ប្រើខាងភាសាសំស្រ្កឹតមាន៩តួ គឺ អា, ឦ, ឩ, ឬ, ឮ, ឯ, ឰ, ឱ, ឳ; សម្រាប់ប្រើខាងភាសាខ្មែរមាន១៣តួ គឺ អា, អី, អឺ, អូ, អួ, អើ, អឿ, អៀ, អេ, អែ, អៃ, អោ, អៅ; ស្រៈទាំងប៉ុណ្ណោះហៅថា ស្រៈទីឃៈ ឬ ទីឃសរៈ។

**រស្សៈ** *គុ.* (**បា.សំ.**) ដែលខ្លី; ដែលមានរូបរាងខ្លី; ដែលតឿ; ដែលទាបកន្ទិល, ដែលកន្ទុញ។

*ន.* ស្រៈមានសំឡេងខ្លី; សម្រាប់ប្រើក្នុងភាសាបាលីមាន៣តួ គឺ អ, ឥ, ឧ; ខាងភាសាសំស្រ្កឹតមាន៦តួ គឺ អ, ឥ, ឧ, ឫ, ឭ, អះ; ខាងភាសាខ្មែរមាន៤តួគឺ អិ, អឹ, អុ, អះ (សម្រាប់ភាសាខ្មែរ, ស្រៈ អ នេះមិនទៀង គឺចួនកាលជា រស្សៈ ចួនកាលជា ទីឃៈ តាមសូរសំឡេងជា អៈខ្លី និង អវែង, ដូចជា : ប៉ប្រក, ប៉ប្រង, ទទ្រម, ពពក, ពភល *អ.ថ.* ប៉ះប្រក, ប៉ះប្រង, ទះទ្រម, ពះពក, ពះភល; ប៉ះ, ទះ, ពះ ជា រស្សៈ; ប្រក, ប្រង, ទ្រម, ពក, ភល ជា ទីឃៈ ឬជា គរុ; ស្រៈទាំងប៉ុណ្ណោះហៅថា ស្រៈរស្សៈ ឬ រស្សសរៈ។

**📖 ទីឃកាល ពាក្យផ្ទុយ រស្សកាល**

**ទីឃកាល** *ន.* (បា.) កាលវែង, កាលអង្វែង។

**រស្សកាល** *ន.* (បា.) កាលខ្លី, កាលពុំយូរ។

📖 **ទីឃជាត ពាក្យផ្ទុយ រស្សជាត**

**ទីឃជាត** *ន.* (បា.) សត្វមានដងខ្លួនវែង (ពស់); ពួកសត្វគោកក្ដីទឹកក្ដី ដែលមានដងខ្លួនវែងឥតជើង ជាសត្វលូនទាំងប៉ុន្មានហៅដោយរួបរួមថា ទីឃជាត ដូចគ្នា។

**រស្សជាត** *ន.* (បា.) សត្វដែលមានខ្លួនខ្លី, សត្វដែលមានរូបត្រមុលហៅថា រស្សកជាត ឬ រស្សកសត្ត, រស្សកសត្វ ក៏បាន)។

📖 **ទីឃទស្សិនី ពាក្យផ្ទុយ រស្សទស្សិនី**

**ទីឃទស្សិនី** *គុ.* ឬ *ន.* (បា.) ស្ត្រីអ្នកឃើញហេតុវែង, ស្ត្រីអ្នកឃើញកាលវែង គឺស្ត្រីអ្នកដែលមានញាណដ៏វិសេសអាចឃើញហេតុ, ឃើញដំណើរដែល នឹងមានក្នុងអនាគត។

**រស្សទស្សិនី** *ន.* (បា.) ស្ត្រីអ្នកឃើញកាលខ្លី, ស្ត្រីអ្នកឃើញហេតុខ្លី គឺស្ត្រី អ្នកដែលមានគំនិតយល់ខ្លីៗមិនស្គាល់ការគួរនិងពុំគួរ មិនស្គាល់ហេតុល្អ អាក្រក់វែងឆ្ងាយ។

📖 **ទីឃទស្សី ពាក្យផ្ទុយ រស្សទស្សី**

**ទីឃទស្សី** *គុ.* ឬ *ន.* (បា.) អ្នកឃើញហេតុវែង, អ្នកឃើញកាលវែង គឺអ្នកដែលមានញាណដ៏វិសេសអាចឃើញហេតុ, អ្នកដែលមានញាណដ៏វិសេសឃើញដំណើរដែលនឹងមានក្នុងអនាគត។

**រស្សទស្សី** *ន.* (បា.) អ្នកឃើញកាលខ្លី, អ្នកឃើញហេតុខ្លី គឺអ្នកដែលមានគំនិតយល់ខ្លីៗមិនស្គាល់ការគួរនិងពុំគួរ មិនស្គាល់ហេតុល្អអាក្រក់វែងឆ្ងាយ។

📖 **ទីឃសព្ទ** **ពាក្យផ្ទុយ** **រស្សសព្ទ**

**ទីឃសព្ទ** *ន.* (បា. និង សំ.) សំឡេងវែង, សូរព្ទវែង។

**រស្សសព្ទ** *ន.* (បា. និង សំ.) សំឡេងខ្លី, សូរព្ទខ្លី។

📖 **ទីឃសរ** **ពាក្យផ្ទុយ** **រស្សសរ**

**ទីឃសរ** *ន.* (បា.) ស្រៈមានសំឡេងវែង។

**រស្សសរ** *ន.* (បា.) ស្រៈមានសំឡេងខ្លី។

📖 **ទីឃាវុធ** **ពាក្យផ្ទុយ** **រស្សាវុធ**

**ទីឃាវុធ** *ន.* (បា.) អាវុធវែង, អាវុធមានផ្លែវែង (ដាវ)។

**រស្សាវុធ** *ន.* (បា.) អាវុធខ្លី, ដូចយ៉ាងដំបងខ្លីជាដើម។

📖 **ទឹកស្រក** **ពាក្យផ្ទុយ** **ទឹកឡើង**

**ទឹកស្រក** *ន.* ទឹកថយចុះទាប, ទឹកថយចុះរាក់។

**ទឹកឡើង** *ន.* ទឹកជន់ឡើងខ្ពស់, ទឹកជន់ឡើងជ្រៅ។

📖 **ទុក្ខ** **ពាក្យផ្ទុយ** **សុខ**

**ទុក្ខ** *ន.* (បា.) សេចក្ដីព្រួយ, សេចក្ដីលំបាក (កាយនិងចិត្ត) :

❖ កើតទុក្ខ

❖ មានទុក្ខ។

**សុខ** *ន.* (បា.) សេចក្ដីសប្បាយ; ដំណើរងាយ; ដំណើរស្រួល; ដំណើរស្រណុក; សេចក្ដីសម្រាន្ត :

❖ មានសុខ

❖ បានសុខ។

📖 **ទុគ្គត** **ពាក្យផ្ទុយ** **សុគត**

**ទុគ្គត** *ន.* (បា.) ដំណើរទៅអាក្រក់; ផ្លូវជាទីទៅកាន់កំណើតអាក្រក់, កំណើតអាក្រក់; បានខាងកំណើតក្នុងអបាយភូមិ៤ គឺ នរក, ប្រេត, អសុរកាយ, តិរច្ឆាន។

**សុគត** *ន.* (បា.) ដំណើរទៅល្អ, ការទៅដោយល្អ (ចំពោះការស្លាប់កើត); ការប្រព្រឹត្តត្រូវផ្លូវ, ការត្រូវគន្លងធម៌; គន្លងយុត្តិធម៌, លំអានយុត្តិធម៌។

📖 **ទុគ្គតគាមិនី** **ពាក្យផ្ទុយ** **សុគតគាមិនី**

**ទុគ្គតគាមិនី** *ន.* (បា.) ស្ត្រីអ្នកដែលទៅកាន់ទុគ្គតិ, ស្ត្រីអ្នកដែលបម្រុងនឹង

ទៅកាន់ទុគ្គតិឬអកុសលធម៌ដែលនាំសត្វទៅកាន់ទុគ្គតិ។

**សុគតគាមិនី** *ន.* (បា.) ស្ត្រីអ្នកដែលទៅកាន់សុគតិ, ស្ត្រីអ្នកដែលបម្រុងនឹងទៅកាន់សុគតិឬកុសលធម៌ដែលនាំសត្វទៅកាន់សុគតិ។

📖 **ទុគ្គតគាមី ពាក្យផ្ទុយ សុគតគាមី**

**ទុគ្គតគាមី** *ន.* (បា.) អ្នកដែលទៅកាន់ទុគ្គតិ, អ្នកដែលបម្រុងនឹងទៅកាន់ទុគ្គតិឬអកុសលធម៌ដែលនាំសត្វទៅកាន់ទុគ្គតិ។

**សុគតគាមី** *ន.* (បា.) អ្នកដែលទៅកាន់សុគតិ, អ្នកដែលបម្រុងនឹងទៅកាន់សុគតិឬកុសលធម៌ដែលនាំសត្វទៅកាន់សុគតិ។

📖 **ទុគ្គតភព ពាក្យផ្ទុយ សុគតភព**

**ទុគ្គតភព** *ន.* (បា.សំ.) ទីកន្លែងកើតរបស់សត្វលោកដែលមានគតិអាក្រក់ គឺអបាយភូមិ៤ :

❖ អំពើអាក្រក់តែងនាំសត្វឱ្យទៅកើតក្នុងទុគ្គតិភព។

**សុគតភព** *ន.* (បា.សំ.) ឋានសួគ៌, ស្រុកសួគ៌។

📖 **ទុច្ចរិត ពាក្យផ្ទុយ សុចរិត**

**ទុច្ចរិត** *ន.* (បា.) ដំណើរប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត :

❖ ទុច្ចរិតជាអំពើដែលបណ្ឌិតត្រូវតែចៀសវាង។

**សុចរិត** *ន.* (**បា.សំ.**) ការប្រព្រឹត្តល្អ :

❖ កាន់សុចរិត។

📖 **ទុច្ឆន្ទ** **ពាក្យផ្ទុយ** **សុច្ឆន្ទ**

**ទុច្ឆន្ទ** *ន.* (**បា.**) ឆន្ទៈអាក្រក់, បំណងអាក្រក់, គំនិតអាក្រក់ :

❖ មនុស្សមានទុច្ឆន្ទ។

**សុច្ឆន្ទ** *ន.* (**បា.សំ.**) ឆន្ទៈល្អ, បំណងប្រពៃ; បំណងត្រឹមត្រង់, បំណងត្រឹមត្រូវ គឺបំណងដែលត្រឹមត្រង់តាមគតិធម៌ និងគតិច្បាប់អាចញុំាងសេចក្ដីសុខចម្រើនឱ្យកើតមាន :

❖ សុច្ឆន្ទរបស់វីរបុរស។

📖 **ទុច្ឆន្ទៈ** **ពាក្យផ្ទុយ** **សុច្ឆន្ទៈ**

**ទុច្ឆន្ទៈ** *ន.* (**បា.ភ្ល.**) ឆន្ទៈអាក្រក់, បំណងអាក្រក់, គំនិតអាក្រក់ :

❖ មនុស្សមានទុច្ឆន្ទៈ។

**សុច្ឆន្ទៈ** *ន.* (**បា.សំ.ភ្ល.**) ឆន្ទៈល្អ, បំណងប្រពៃ; បំណងត្រឹមត្រង់, បំណងត្រឹមត្រូវ គឺបំណងដែលត្រឹមត្រង់តាមគតិធម៌និងគតិច្បាប់ញុំាងសេចក្ដីសុខចម្រើនឱ្យកើតមាន :

❖ សុច្ឆន្ទៈរបស់វីរបុរស។

📖 **ទុទ្ទិដ្ឋិ** **ពាក្យផ្ទុយ** **សុទិដ្ឋិ**

**ទុទ្ទិដ្ឋិ** *ន.* (បា.) ទិដ្ឋិអាក្រក់, ការយល់ឃើញខុសចាកសេចក្ដីពិត, សេចក្ដីយល់ឃើញខុសឃ្លាងពីគន្លងធម៌ (មិច្ឆាទិដ្ឋិ)។

**សុទិដ្ឋិ** *ន.* (បា.) ទិដ្ឋិល្អ, ការយល់ឃើញត្រូវតាមសេចក្ដីពិត, សេចក្ដីយល់ឃើញត្រូវតាមគន្លងធម៌ (សម្មាទិដ្ឋិ)។

📖 **ទុទ្ទិដ្ឋិនិយម** **ពាក្យផ្ទុយ** **សុទិដ្ឋិនិយម**

**ទុទ្ទិដ្ឋិនិយម** *ន.* (បា.) និយមចំពោះទុទ្ទិដ្ឋិ, សេចក្ដីចូលចិត្តក្នុងទ្រឹស្ដីថាអាក្រក់, សេចក្ដីប្រកាន់ខ្ជាប់ក្នុងទ្រឹស្ដីថាលំបាក, ការយល់ឃើញថារបស់អ្វីទាំងអស់ក្នុងលោកសុទ្ធតែមិនល្អ, សុទ្ធតែប្រកបដោយទុក្ខលំបាក :

- មនុស្សប្រកាន់ទុទ្ទិដ្ឋិនិយម។

**សុទិដ្ឋិនិយម** *ន.* (បា.) ការនិយមចំពោះសុទិដ្ឋិ, ការនិយមដោយទិដ្ឋិត្រូវ; ការចូលចិត្តឬការយល់ឃើញថារបស់អ្វីក្នុងលោកសុទ្ធតែល្អ, សុទ្ធតែប្រសើរសុខស្រួល :

- បុគ្គលប្រកបដោយសុទិដ្ឋិនិយម។

📖 **ទុប្ផល** **ពាក្យផ្ទុយ** **សុផល**

**ទុប្ផល** *ន.* (បា.) ផលមិនល្អ, ផ្លែមិនល្អ។

**សុផល** *ន.* (បា.សំ.) ផលល្អ, ផ្លែល្អ។

📖 **ទុព្វចៈ　　　　ពាក្យផ្ទុយ　　　　សុពចៈ**

**ទុព្វចៈ** *គុ.* (បា.ភ្ល.) ដែលស្ដីប្រដៅដោយកម្រ, ដែលពិបាកស្ដីប្រដៅ; ដែលមិនងាយយកពាក្យ :

❖ មនុស្សទុព្វចៈ។

**សុពចៈ** *គុ.* (បា.ភ្ល.) ដែលស្ដីប្រដៅងាយ, ដែលស្រណុកស្ដីប្រដៅ; ដែលងាយយកពាក្យ :

❖ មនុស្សសុពចៈ។

📖 **ទុព្វចជាតកៈ　　　　ពាក្យផ្ទុយ　　　　សុពចជាតកៈ**

**ទុព្វចជាតកៈ** *ន.* (បា.ភ្ល.) អ្នកដែលគេពិបាកស្ដីប្រដៅ។

**សុពចជាតកៈ** *ន.* (បា.ភ្ល.) អ្នកដែលគេងាយស្ដីប្រដៅ។

📖 **ទុព្វចជាតកា　　　　ពាក្យផ្ទុយ　　　　សុពចជាតកា**

**ទុព្វចជាតកា** *ន.* (បា.) ស្ត្រីអ្នកដែលគេពិបាកស្ដីប្រដៅ។

**សុពចជាតកា** *ន.* (បា.) ស្ត្រីអ្នកដែលគេងាយស្ដីប្រដៅ។

📖 **ទុព្វចមិត្ត　　　　ពាក្យផ្ទុយ　　　　សុពចមិត្ត**

**ទុព្វចមិត្ត** *ន.* (បា.) មិត្តដែលស្ដីថាឱ្យទៅមិនស្ដាប់ពាក្យ, មិត្តមិនងាយស្ដី

ប្រដៅ។

**សុពចមិត្ត** *ន.* (បា.) មិត្តដែលស្ដីថាឱ្យទៅស្ដាប់ពាក្យ, មិត្តងាយស្ដីប្រដៅ។

📖 **ទុព្វចមិត្រ** **ពាក្យផ្ទុយ** **សុពចមិត្រ**

**ទុព្វចមិត្រ** *ន.* (សំ.) មិត្រដែលស្ដីថាឱ្យទៅមិនស្ដាប់ពាក្យ, មិត្រមិនងាយស្ដីប្រដៅ។

**សុពចមិត្រ** *ន.* (សំ.) មិត្រដែលស្ដីថាឱ្យទៅស្ដាប់ពាក្យ, មិត្រងាយស្ដីប្រដៅ។

📖 **ទុព្វិជ្ជា** **ពាក្យផ្ទុយ** **សុខជ្ជា**

**ទុព្វិជ្ជា** *ន.* (បា.) វិជ្ជាអាក្រក់ គឺវិជ្ជាដែលញ៉ាំងអ្នកចេះឱ្យហិនហោច, ឱ្យវិនាសទាំងឱ្យមានវិប្បដិសារៈនឹកតូចចិត្តស្ដាយក្រោយទៀតផង, ជាវិជ្ជារាប់បញ្ចូលក្នុងអកុសលកម្មពុំគួរមនុស្សត្រូវការរៀនឡើយ។

**សុខជ្ជា** *ន.* (បា.) វិជ្ជាល្អ, ចំណេះដែលយោងអាត្មាឱ្យបានទ្រព្យធនបុណ្យសក្ដិសុខចម្រើន។

📖 **ទុព្ភាសិត** **ពាក្យផ្ទុយ** **សុភាសិត**

**ទុព្ភាសិត** *ន.* (បា.) សម្ដីអាក្រក់, ពាក្យគំរោះគំរើយ។

**សុភាសិត** *ន.* (បា.) ពាក្យពីរោះ, ពាក្យត្រូវ, ឱវាទត្រឹមត្រូវ។

📖 **ទុព្ភិក្ខ** **ពាក្យផ្ទុយ** **សុភិក្ខ**

**ទុព្ភិក្ខ** *ន.* (បា.) ដំណើរក្របាយ, ដំណើរអត់បាយ, ដំណើរអត់ឃ្លាន :

❖ ស្រុកកើតទុព្ភិក្ខ។

**សុភិក្ខ** *ន.* (បា.) ដែលមានបាយងាយ គឺដែលសម្បូណ៌ភោជនាហារ :

❖ ស្រុកមានសុភិក្ខ។

📖 **ទុព្ភិក្ខកាល ពាក្យផ្ទុយ សុភិក្ខកាល**

**ទុព្ភិក្ខកាល** *ន.* (បា.) គ្រាក្របាយ, គ្រាអត់បាយ, គ្រាអំណត់។

**សុភិក្ខកាល** *ន.* (បា.) កាលសម្បូណ៌ភោជនាហារ, គ្រាសម្បូណ៌ស្រូវអង្ករ។

📖 **ទុព្ភិក្ខសម័យ ពាក្យផ្ទុយ សុភិក្ខសម័យ**

**ទុព្ភិក្ខសម័យ** *ន.* (បា.ក្ល.) គ្រាក្របាយ, គ្រាអត់បាយ, គ្រាអំណត់។

**សុភិក្ខសម័យ** *ន.* (បា.ក្ល.) សម័យសម្បូណ៌ភោជនាហារ, គ្រាសម្បូណ៌ស្រូវអង្ករ។

📖 **ទុរាគមន៍ ពាក្យផ្ទុយ ស្វាគមន៍**

**ទុរាគមន៍** *ន.* (បា.សំ.ក្ល.) ការមកដល់មិនស្រួល, ដំណើរមកដល់ប្រកបដោយទុក្ខលំបាក។

**ស្វាគមន៍** *ន.* (បា.សំ.ក្ល.) ដំណើរមកដល់ដោយប្រពៃ, ការមកដល់ដែលធ្វើឱ្យកើតសេចក្ដីរីករាយសប្បាយ។

📖 **ទុជ៌ន** **ពាក្យផ្ទុយ** **សុជន**

**ទុជ៌ន** *ន.* (សំ.) ជនអាក្រក់, ជនចិត្តអាក្រក់, មនុស្សចិត្តអាក្រក់។

**សុជន** *ន.* (បា.សំ.) ជនល្អ, មនុស្សអ្នកប្រព្រឹត្តល្អ, មនុស្សចិត្តល្អ។

📖 **ទុរ្ភិក្ស** **ពាក្យផ្ទុយ** **សុភិក្ស**

**ទុរ្ភិក្ស** *ន.* (សំ.) ដំណើរក្របាយ, ដំណើរអត់បាយ, ដំណើរអត់ឃ្លាន :

❖ ស្រុកកើតទុរ្ភិក្ស។

**សុភិក្ស** *គុ.* (សំ.) ដែលមានបាយងាយ គឺដែលសម្បូណ៌ភោជនាហារ :

❖ ស្រុកមានសុភិក្ស។

📖 **ទុវ៌ិទ្យា** **ពាក្យផ្ទុយ** **សុខទ្យា**

**ទុវ៌ិទ្យា** *ន.* (សំ.) វិទ្យាអាក្រក់ គឺវិទ្យាដែលញ៉ាំងអ្នកចេះឱ្យហិនហោចទាំងឱ្យមានវិប្បដិសារៈនឹកតូចចិត្តស្ដាយក្រោយទៀតផង។

**សុខទ្យា** *ន.* (សំ.) វិទ្យាល្អ, ចំណេះដែលយោងអាត្មាឱ្យបានទ្រព្យធនបុណ្យសក្តិសុខចម្រើន។

📖 **ទុល្លភ** **ពាក្យផ្ទុយ** **សុលភ**

**ទុល្លភ** *គុ.* (បា.សំ.) ដែលកម្របាន, ដែលកម្ររកបាន, ដែលក្រប្រទះ។

**សុលភ** *គុ.* (បា.សំ.) ដែលបានដោយងាយ, ដែលងាយបាន។

📖 **ទុល្លភទ្រព្យ ពាក្យផ្ទុយ សុលភទ្រព្យ**

**ទុល្លភទ្រព្យ** *ន.* (បា.សំ. និង សំ.ក្លូ.) ទ្រព្យដែលរកបានដោយកម្រ។

**សុលភទ្រព្យ** *ន.* (បា.សំ. និង សំ.ក្លូ.) ទ្រព្យដែលរកបានដោយងាយ។

📖 **ទុល្លភធន ពាក្យផ្ទុយ សុលភធន**

**ទុល្លភធន** *ន.* (បា.សំ.) ទ្រព្យដែលរកបានដោយកម្រ។

**សុលភធន** *ន.* (បា.សំ.) ទ្រព្យដែលរកបានដោយងាយ។

📖 **ទុល្លភភណ្ឌ ពាក្យផ្ទុយ សុលភភណ្ឌ**

**ទុល្លភភណ្ឌ** *ន.* (បា.) របស់ដែលកម្របាន, អីវ៉ាន់ដែលកម្របាន។

**សុលភភណ្ឌ** *ន.* (បា.) របស់ដែលងាយបាន, អីវ៉ាន់ដែលងាយបាន។

📖 **ទុល្លភវត្ថុ ពាក្យផ្ទុយ សុលភវត្ថុ**

**ទុល្លភវត្ថុ** *ន.* (បា.) វត្ថុដែលរកបានដោយកម្រ, វត្ថុដែលក្ររកបាន។

**សុលភវត្ថុ** *ន.* (បា.) វត្ថុដែលរកបានដោយងាយ, អ្វីៗដែលបានដោយងាយ។

📖 **ទុល្លភសម្បត្តិ ពាក្យផ្ទុយ សុលភសម្បត្តិ**

**ទុល្លភសម្បត្តិ** *ន.* (បា.សំ.) សម្បត្តិដែលមិនងាយបាន។

**សុលភសម្បត្តិ** *ន.* (បា.សំ.) សម្បត្តិដែលងាយបាន។

📖 **ទោមនស្ស ពាក្យផ្ទុយ សោមនស្ស**

**ទោមនស្ស** *ន.* (បា.) សេចក្ដីតូចចិត្ត, សេចក្ដីអាក់អន់ចិត្ត :

❖ មានទោមនស្ស។

**សោមនស្ស** *ន.* (បា.) សេចក្ដីសប្បាយចិត្ត, សេចក្ដីរីករាយសប្បាយ; អំណរ :

❖ មានសោមនស្ស។

📖 **ទោមនស្សវេទនា ពាក្យផ្ទុយ សោមនស្សវេទនា**

**ទោមនស្សវេទនា** *ន.* (បា.) ដំណើរទទួលអារម្មណ៍ជាទោមនស្ស។

**សោមនស្សវេទនា** *ន.* (បា.) ដំណើរទទួលអារម្មណ៍ជាសោមនស្ស។

📖 **ទោល ពាក្យផ្ទុយ បន្ទារ**

**ទោល** *ន.* កម្រាស់បញ្ឈរ គឺកម្រាស់ដែលទីទៃពីបន្ទារ។

**បន្ទារ** *ន.* ប៉ែកទទឹងបន្ទះក្ដារ, ប៉ែកទទឹងបន្ទះឈើ, ប៉ែកទទឹងបន្ទះអ្វីៗ :

❖ បន្ទារពីរតឹកទោលពីរហ៊ុនកន្លះ។

📖 **ទៅ ពាក្យផ្ទុយ មក**

**ទៅ** *កិ.* ឃ្លាតចាកទីដោយដើរ, ឃ្លាតចាកទីដោយយានជំនិះ :

❖ ទៅសាលារៀន។

**មក** *កិ.* ឃ្លាតពីទីខាងនាយមកកាន់ទីខាងអាយ, ឃ្លាតពីទីនោះចូលដល់ទីនេះ, វិលត្រលប់វិញ :

❖ មកពីផ្សារ។

📖 **ធម្មកម្ម** **ពាក្យផ្ទុយ** **អធម្មកម្ម**

**ធម្មកម្ម** *ន.* (បា.) អំពើដែលប្រកបដោយធម៌, កិច្ចការដែលប្រកបដោយធម៌, កិច្ចការដែលត្រូវតាមធម៌។

**អធម្មកម្ម** *ន.* (បា.) កម្មអាក្រក់, អំពើពុំប្រសើរ។

📖 **ធរមាន** **ពាក្យផ្ទុយ** **អធរមាន**

**ធរមាន** *ន.* (បា.) ដែលកំពុងទ្រទ្រង់នៅ, ដែលមានជីវិតរស់នៅ :

❖ កាលព្រះសម្មាសម្ពុទ្ធទ្រង់ធរមាននៅឡើយ។

**អធរមាន** *គុ.* (បា.) ដែលកំពុងតែគ្មាន, ដែលឥតមានសោះឡើយ។

📖 **ធាត់** **ពាក្យផ្ទុយ** **ស្គម**

**ធាត់** *គុ.* ទីទៃពីស្គម គឺមានសាច់ច្រើន :

❖ មនុស្សធាត់។

**ស្គម** *គុ.* ដែលចុះសាច់, តិចសាច់ :

❖ ស្គមកំព្រឹង។

📖 **ធ្ងន់** **ពាក្យផ្ទុយ** **ស្រាល**

**ធ្ងន់** *គុ.* ទីទៃពីស្រាល គឺមានទម្ងន់ :

❖ អង្ករមួយបាវនេះធ្ងន់ណាស់ខ្ញុំលីមិនរួចទេ។

**ស្រាល** *គុ.* ដែលមានទម្ងន់តិច, ដែលតិចទម្ងន់, ដែលឥតទម្ងន់ :

❖ របស់ស្រាល

❖ ទោសស្រាល។

📖 **នត្ថិភាព ពាក្យផ្ទុយ អត្ថិភាព**

**នត្ថិភាព** *ន.* (**បា.ភ្ន.**) ភាវៈគ្មាន, ភាពនៃអ្វីៗដែលមិនមាន, ការឥតមាន :

❖ ពីដើមគាត់គ្រាន់រួចខ្លួន ប៉ុន្តែឥឡូវនេះគាត់ធ្លាក់ចុះក្នុងនត្ថិភាពសាបរលាបណាស់ទៅហើយ។

**អត្ថិភាព** *ន.* (**បា.ភ្ន.**) ភាវៈមាន, ភាពនៃអ្វីៗដែលមាន, ការមាន :

❖ កាលពីដើមគាត់ធ្លាក់ចុះក្នុងនត្ថិភាព ប៉ុន្តែឥឡូវនេះគាត់បានចូលក្នុងអត្ថិភាពហើយ។

📖 **នាយ ពាក្យផ្ទុយ អាយ**

**នាយ** *សព្ទ.* ខាងម្ខាងទីទៃពីខាងអាយ, ឯណោះ :

❖ ខាងនាយ

❖ ខ្ញុំនៅឯនាយ។

**អាយ** *សព្ទ.* ដែលទីទៃពីពាក្យថានាយឬខាងនាយគឺខាងនេះ, ខាងឯណេះ :

❖ ត្រើយអាយ

❖ ស្រុកអាយ។

🕮 **និច្ច** **ពាក្យផ្ទុយ** **អនិច្ច**

**និច្ច** *កិ.វិ.* ឬ *គុ.* (បា.) ទៀង, ពិត, មែន; រឿយៗ, មិនដែលដាច់។

**អនិច្ច** *គុ.* (បា.) ដែលមិនទៀង, ដែលមិនឋិតថេរ, ដែលពុំប្រាកដ; ដែលតែងតែប្រែប្រួលតាមធម្មតា។

🕮 **និច្ចកាល** **ពាក្យផ្ទុយ** **អនិច្ចកាល**

**និច្ចកាល** *កិ.វិ.* (បា.) រាល់កាល, រាល់វេលា។

**អនិច្ចកាល** *កិ.វិ.* (បា.) កាលមិនទៀង; មិនមែនរាល់កាល។

🕮 **និត្យ** **ពាក្យផ្ទុយ** **អនិត្យ**

**និត្យ** *កិ.វិ.* (សំ.) ទៀង, ពិត, មែន, រឿយៗ, មិនដែលដាច់។

**អនិត្យ** *គុ.* (សំ.) ដែលមិនទៀង, ដែលមិនឋិតថេរ, ដែលពុំប្រាកដ; ដែលតែងតែប្រែប្រួលតាមធម្មតា។

🕮 **និន្ទា** **ពាក្យផ្ទុយ** **បសំសា**

**និន្ទា** *ន.* (បា.សំ.) ដំណើរតិះដៀល, ការរិះគន់, ដំណៀល។

**បសំសា** *ន.* (បា.) សេចក្ដីសរសើរ, ពាក្យសរសើរ។

📖 **និប្បរិយាយ** **ពាក្យផ្ទុយ** **បរិយាយ**

**និប្បរិយាយ** *ន.* (បា.) សេចក្តីអធិប្បាយដោយត្រង់មិនវៀងវៃ, សេចក្តីពន្យល់ត្រឹមត្រូវគ្រប់គ្រាន់។

**បរិយាយ** *ន.* (បា.) សេចក្តីអធិប្បាយវៀងវៃ, ការអធិប្បាយសម្រួលសេចក្តី :

❖ ពោលដោយបរិយាយ។

📖 **និយម** **ពាក្យផ្ទុយ** **អនិយម**

**និយម** *ន.* (បា.សំ.) សេចក្តីកំណត់, សេចក្តីធម្មតា, ធម្មជាតិ។

**អនិយម** *ន.* (បា.សំ.) ការមិននិយម, សេចក្តីមិនទៀង។

📖 **និរគុណ** **ពាក្យផ្ទុយ** **សគុណ**

**និរគុណ** *គុ.* (សំ.ភ្ល.) ដែលឥតគុណ, ដែលឥតប្រយោជន៍ :

❖ មនុស្សនិរគុណ

❖ របស់និរគុណ។

**សគុណ** *គុ.* (បា.) ដែលប្រកបដោយគុណ, ដែលមានគុណ, ដែលមានបំណាច់ :

❖ របស់សគុណ

❖ មនុស្សសគុណ។

📖 **និស្សយមុត្តក** **ពាក្យផ្ទុយ** **អនិស្សយមុត្តក**

**និស្សយមុត្តក** *ន.* (បា.) ភិក្ខុដែលមានវស្សាតាំងពី៥ឡើងទៅហើយចេះវិន័យមានសេចក្តីអៀនខ្មាសគ្រប់គ្រាន់ អាចផុតចាកនិស្ស័យរបស់ឧបជ្ឈាយ៍ឬអាចារ្យបានគឺអាចនៅតាមទំនើងខ្លួនបាន (ព.វិ.ពុ.)។

**អនិស្សយមុត្តក** *ន.* (បា.) អ្នកដែលមិនទាន់រួចផុតអំពីនិស្ស័យ គឺអ្នកដែលនៅក្នុងបន្ទុកឬក្នុងអំណាចគេទូន្មានប្រៀនប្រដៅស្តីថា :

❖ បុត្រប្រុសស្រីដែលនៅក្នុងបន្ទុកមាតាបិតាជាអនិស្សយមុត្តក

❖ ភិក្ខុខ្ចីវស្សាឬភិក្ខុចាស់សូម្បីបួសបាន៦០វស្សាហើយបើល្ងង់ខ្លៅពុំស្គាល់កិច្ចខុសត្រូវក្នុងវិន័យទេជាអនិស្សយមុត្តក។

📖 **និស្សយមុត្តិកា ពាក្យផ្ទុយ អនិស្សយមុត្តិកា**

**និស្សយមុត្តិកា** *ន.* (បា.) ភិក្ខុនីដែលមានវស្សាតាំងពី៥ឡើងទៅហើយចេះវិន័យមានសេចក្តីអៀនខ្មាសគ្រប់គ្រាន់ អាចផុតចាកនិស្ស័យរបស់ឧបជ្ឈាយ៍ឬអាចារ្យបានគឺអាចនៅតាមទំនើងខ្លួនបាន (ព.វិ.ពុ.)។

**អនិស្សយមុត្តិកា** *ន.* (បា.) ស្ត្រីអ្នកដែលមិនទាន់រួចផុតអំពីនិស្ស័យ គឺស្ត្រីអ្នកដែលនៅក្នុងបន្ទុកឬក្នុងអំណាចគេទូន្មានប្រៀនប្រដៅស្តីថា :

❖ បុត្រប្រុសស្រីដែលនៅក្នុងបន្ទុកមាតាបិតាជាអនិស្សយមុត្តិកា

❖ ភិក្ខុនីខ្ចីវស្សាឬភិក្ខុនីចាស់សូម្បីបួសបាន៦០វស្សាហើយបើល្ងង់ខ្លៅពុំស្គាល់កិច្ចខុសត្រូវក្នុងវិន័យទេជាអនិស្សយមុត្តិកា។

📖 **នីហរ័ណ ពាក្យផ្ទុយ អាហរ័ណ**

**នីហរ័ណ** *ន.* (**បា.ក្ល.**) ជំនួញនាំចេញ, ជំនួញខាងដឹកនាំទំនិញចេញពីប្រទេសរបស់ខ្លួនទៅលក់ឯប្រទេសក្រៅ, មុខរបរពាណិជ្ជកម្មខាងដឹកនាំវត្ថុផ្សេងៗទៅលក់ឯបរទេស :

❖ ខ្ញុំប្រកបមុខរបរខាងនីហរ័ណ។

**អាហរ័ណ** *ន.* (**បា.ក្ល.**) មុខរបរខាងទទួលទំនិញ, មុខរបរខាងទទួលផលិតផលផ្សេងៗពីប្រទេសក្រៅនាំចូលមកក្នុងប្រទេស :

❖ ប្រកបមុខរបរខាងអាហរ័ណ។

📖 **នេះ ពាក្យផ្ទុយ នោះ**

**នេះ** *សព្វ.* ពាក្យសម្រាប់បង្ហាញ, ពាក្យសម្រាប់ចង្អុលអ្វីៗដែលនៅខាងខ្លួនឱ្យឃើញជាក់ច្បាស់ :

❖ សំបុត្រនេះ

❖ សេចក្ដីនេះ។

**នោះ** *គុ.ស.* ពាក្យសម្រាប់បង្ហាញ, ពាក្យសម្រាប់ចង្អុលអ្វីៗដែលនៅឆ្ងាយ

តែប្រាកដ; ជាពាក្យមានសូរសំឡេងស្មើនឹង នុះ ប៉ុន្តែទាបជាង នុ៎ះ, ដូចជា :

❖ សេចក្ដីនោះ

❖ ផ្ទះនោះជាដើម។

📖 **បង្រួញ, អង្កួញ ពាក្យផ្ទុយ សណ្ដូក**

**បង្រួញ** *កិ.* ធ្វើឱ្យរួញ, ធ្វើឱ្យខ្លីទៅវិញ :

❖ បង្រួញសេចក្ដីឱ្យខ្លី។

**អង្កួញ** *កិ.* បង្រួញជើងចូល, បង្រួញដៃចូល :

❖ អង្កុញជើង។

**សណ្ដូក** *កិ.* លាតលាត្រង់ស្ដូក :

❖ សណ្ដូកជើង។

📖 **បច្ចុគ្គមនៈ ពាក្យផ្ទុយ អនុគ្គមនៈ**

**បច្ចុគ្គមនៈ** *ន.* (បា.ភ្ល.) ការក្រោកទទួល។

**អនុគ្គមនៈ** *ន.* (បា.ភ្ល.) ការក្រោកជូន, ការតាមជូនដំណើរ :

❖ ធ្វើអនុគ្គមនៈ។

📖 **បច្ចុគ្គមន៍ ពាក្យផ្ទុយ អនុគ្គមន៍**

**បច្ចុគ្គមន៍** *ន.* (បា.ភ្ល.) ការក្រោកទទួល។

**អនុគ្គមន៍** *ន.* (បា.ភ្ជ.) ការក្រោកជូន, ការតាមជូនដំណើរ :

❖ ធ្វើអនុគ្គមន៍។

📖 **បច្ចុគ្គមនាការ ពាក្យផ្ទុយ អនុគ្គមនាការ**

**បច្ចុគ្គមនាការ** *ន.* (បា.) អាការៈនៃការក្រោកទទួល។

**អនុគ្គមនាការ** *ន.* (បា.) អាការៈនៃការក្រោកជូន :

❖ ធ្វើអនុគ្គមនាការ។

📖 **បច្ឆាចារ្យ ពាក្យផ្ទុយ បុព្វាចារ្យ**

**បច្ឆាចារ្យ** *ន.* (បា. និង **សំ.ភ្ជ.**) អាចារ្យក្រោយ, គ្រូខាងក្រោយ :

❖ គ្រូបង្រៀនជាបច្ឆាចារ្យនៃបុត្រធីតាទាំងឡាយ។

**បុព្វាចារ្យ** *ន.* (បា. និង **សំ.ភ្ជ.**) អាចារ្យមុន, គ្រូដើម គឺមាតាបិតា។ មាតាបិតាបានជាហៅថាបុព្វាចារ្យ ព្រោះជាគ្រូបង្ហាត់បង្រៀនកូនឱ្យចេះនិយាយស្ដីនិងសណ្ដាប់ធ្នាប់របៀបរបប ព្រមទាំងកិច្ចការទាំងពួងផងជាមុនជាងគ្រូទាំងអស់ដែលកូនត្រូវរៀនចំណេះវិជ្ជាផ្សេងៗ។

📖 **បច្ឆាភត្ត ពាក្យផ្ទុយ បុរេភត្ត**

**បច្ឆាភត្ត** *ន.* (បា.) វេលាខាងក្រោយភត្តគឺវេលាដែលបរិភោគភោជនាហារថ្ងៃត្រង់រួចហើយតាំងពីរសៀលទៅ :

❖ វេលាបច្ឆាភត្ត

❖ សម្រាកកាយក្នុងបច្ឆាភត្ត។

**បុរេភត្ត** *ន.* (បា.) វេលាមុនភត្ត គឺពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 **បច្ឆាភត្តកាល ពាក្យផ្ទុយ បុរេភត្តកាល**

**បច្ឆាភត្តកាល** *ន.* (បា.) វេលាខាងក្រោយភត្ត គឺវេលាដែលបរិភោគភោជនាហារថ្ងៃត្រង់រួចហើយតាំងពីរសៀលទៅ :

❖ វេលាបច្ឆាភត្តកាល

❖ សម្រាកកាយក្នុងបច្ឆាភត្តកាល។

**បុរេភត្តកាល** *ន.* (បា.) វេលាមុនភត្ត គឺពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 **បច្ឆាភត្តកិច្ច ពាក្យផ្ទុយ បុរេភត្តកិច្ច**

**បច្ឆាភត្តកិច្ច** *ន.* (បា.) ពេលខាងក្រោយនៃភត្តកិច្ច, វេលាខាងក្រោយបន្ទាប់ពីពេលបាយថ្ងៃត្រង់។

**បុរេភត្តកិច្ច** *ន.* (បា.) ពេលមុននៃភត្តកិច្ច, ពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 **បច្ឆិមភាគ ពាក្យផ្ទុយ បុព្វភាគ**

**បច្ឆិមភាគ** *ន.* (បា.) ភាគខាងចុង។

**បុព្វភាគ** *ន.* (បា.) ចំណែកខាងដើម, ប៉ែកខាងដើម។

📖 **បញ្ញត្ត ពាក្យផ្ទុយ អនុញ្ញាត**

**បញ្ញត្ត** *កិ.* ឬ *គុ.* (បា.) ហាមប្រាមហើយ; តែងតាំងហើយ, តាំងទុកហើយ, រៀបចំហើយ; ដែលគេហាមប្រាមហើយ :

❖ រាជការបញ្ញត្តមិនឱ្យប្រជាជនលេងល្បែងភ្នាល់ផ្សេងៗ។

**អនុញ្ញាត** *កិ.* (បា.) យល់ព្រម, បើកឱកាសឱ្យ; បានយល់ព្រមហើយ :

❖ រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ។

📖 **បញ្ញត្តិ ពាក្យផ្ទុយ អនុញ្ញាត**

**បញ្ញត្តិ** *ន.* (បា.) សេចក្ដីហាមប្រាម, បម្រាម, សេចក្ដីដែលគេតែងតាំង, សេចក្ដីដែលគេរៀបចំ; ពាក្យដែលគេកំណត់ហៅ :

❖ មានបញ្ញត្តិ

❖ ធ្វើខុសនឹងបញ្ញត្តិ។

**អនុញ្ញាត** *កិ.* (បា.) យល់ព្រម, បើកឱកាសឱ្យ; បានយល់ព្រមហើយ :

❖ រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ។

📖 **បដិលោម ពាក្យផ្ទុយ អនុលោម**

**បដិលោម** *គុ.* ឬ *ន.* (បា.) ដែលច្រាសឡើងវិញ; ដំណើរច្រាសមកវិញ, ដំណើរទទឹងទាស់ :

❖ រំពឹងជាអនុលោមនិងបដិលោម។

**អនុលោម** *កិ.* (បា.) តាមរោមគឺបណ្ដោយ; បណ្ដោយតាម, យល់ព្រមតាម, មិនទទឹងទាស់, មិនយល់ទាស់ :

❖ អនុលោមរកគ្នា។

📖 **បណ្ឌិត ពាក្យផ្ទុយ ពាល**

**បណ្ឌិត** *ន.* (បា.) ជនអ្នកមានប្រាជ្ញាឈ្មោះបណ្ឌា, ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិត១០ប្រការដោយពិស្ដារ, កាន់សុចរិត៤០ប្រការដោយខ្ជាប់ខ្ជួនហ្មត់ចត់ជានិច្ច; អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌ (ព.ពុ.)។

**ពាល** *គុ.* (បា.សំ.) ទន់; ដែលនៅក្មេង; ល្ងង់, ខ្លៅ, មិនឈ្លាស; កាច, សាហាវ; អាក្រក់។

📖 **បណ្ឌិតមានិនី ពាក្យផ្ទុយ ពាលមានិនី**

**បណ្ឌិតមានិនី** *ន.* (បា.) ស្ត្រីអ្នកមានមានះថាខ្លួនជាបណ្ឌិត; មានអត្ថន័យថា ស្ត្រីអ្នកមានចំណេះវិជ្ជាប្រកាន់ថា គ្មានអ្នកណាមានចំណេះស្មើនឹងខ្លួន (ស្ត្រីអ្នកនេះស្គាប់ចំណេះត្រឹមតែប៉ុណ្ណឹង); ស្ត្រីអ្នកមានចំណេះព្រួលៗប្រកាន់ថា ឥតមានអ្នកណាចេះជាងខ្លួន (ស្ត្រីអ្នកនេះអស់មានផ្លូវចេះតទៅទៀត គឺមានតែរេចរិលចំណេះនោះទៅវិញ)។

**ពាលមានិនី** *ន.* (ធ.) ស្ត្រីអ្នកដឹងខ្លួន, ស្ត្រីអ្នកសម្គាល់ខ្លួនថាជាពាលឬថាល្ងង់ គឺបុគ្គលណាពាលល្ងង់ក៏ភ្ញាក់ខ្លួនថា ខ្លួនល្ងង់ពិតមែន, បុគ្គលនោះអាចនឹងប្រែគំនិតខំប្រឹងរៀន ខំប្រឹងស្ដាប់ ក៏ត្រលប់ជាស្ត្រីអ្នកចេះដឹងស្គាល់ខុសត្រូវបានពុំខាន។

📖 **បណ្ឌិតមានី ពាក្យផ្ទុយ ពាលមានី**

**បណ្ឌិតមានី** *ន.* (ធ.) អ្នកមានមានះថាខ្លួនជាបណ្ឌិត; មានអត្ថន័យថា អ្នកមានចំណេះវិជ្ជាប្រកាន់ថា គ្មានអ្នកណាមានចំណេះស្មើនឹងខ្លួន (អ្នកនេះស្ដាប់ចំណេះត្រឹមតែប៉ុណ្ណឹង); អ្នកមានចំណេះព្រួលៗប្រកាន់ថា ឥតមានអ្នកណាចេះជាងខ្លួន (អ្នកនេះអស់មានផ្លូវចេះតទៅទៀត គឺមានតែរេចរិលចំណេះនោះទៅវិញ)។

**ពាលមានី** *ន.* (ធ.) អ្នកដឹងខ្លួន, អ្នកសម្គាល់ខ្លួនថាជាពាលឬថាល្ងង់គឺបុគ្គលណាពាលល្ងង់ក៏ភ្ញាក់ខ្លួនថាខ្លួនល្ងង់ពិតមែន, បុគ្គលនោះអាចនឹងប្រែគំនិតខំប្រឹងរៀន ខំប្រឹងស្ដាប់ ក៏ត្រលប់ជាអ្នកចេះដឹងស្គាល់ខុសត្រូវបានពុំខាន។

📖 **បន្តឹង ពាក្យផ្ទុយ បន្ធូរ**

**បន្តឹង** *កិ.* ធ្វើឱ្យតឹង, ទាញឱ្យតឹង, តឿនតឹងរ៉ឹងរឿយៗ :

- ❖ សុំកុំបន្តឹងខ្លាំងពេក។

**បន្ធូរ** ***កិ.*** ធ្វើឱ្យធូរគឺធ្វើមិនឱ្យតឹងមិនឱ្យចង្អៀតពេក ៖

❖ បន្ធូរខ្សែក្រវាត់។

📖 **បន្ទាប់ ពាក្យផ្ទុយ មុន**

**បន្ទាប់** ***កិ.វិ.*** ឬ ***គុ.*** ដែលផ្ទាប់ជិតគ្នា, ដែលរងលំដាប់ពីគ្នា, ដែលឋិតនៅក្បែរគ្នា។

**មុន** ***កិ.វិ.*** ឬ ***គុ.*** ដែលកើត, ផ្ដើម, ស្ថិតនៅជាដំបូង, ស្ថិតនៅជាដើមគេ។

📖 **បមាទ ពាក្យផ្ទុយ អប្បមាទ**

**បមាទ** ***ន.*** (**បា.**) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្ដីប្រហែស, ការធ្វេសប្រហែស។

**អប្បមាទ** ***ន.*** (**បា.**) សេចក្ដីមិនធ្វេស, សេចក្ដីមិនប្រហែស, សេចក្ដីមិនធ្វេសប្រហែស; ការមិនធ្វេសស្មារតី; ការប្រុងប្រយត្នជានិច្ច, ការប្រុងមិនឱ្យភ្លាំងភ្លាត់; ការប្រយត្នមិនធ្វើអំពើអាក្រក់។

📖 **បរលោក ពាក្យផ្ទុយ ឥធលោក**

**បរលោក** ***ន.*** (**បា.**) លោកឯមុខ ៖

❖ ធ្វើមរណកាលទៅកាន់លោកឯខាងមុខ។

**ឥធលោក** ***ន.*** (**បា.**) លោកនេះ, ដលោក ៖

❖ ប្រយោជន៍ក្នុងឥធលោកនិងបរលោក។

📖 **បរលោកត្តភាព ពាក្យផ្ទុយ ឥធលោកត្តភាព**

**បរលោកត្តភាព** *ន.* (បា.ភ្ល.) ជាតិខាងមុខ។

**ឥធលោកត្តភាព** *ន.* (បា.ភ្ល.) អត្តភាពក្នុងលោកនេះ គឺជាតិនេះ។

📖 **បរលោកសុខ ពាក្យផ្ទុយ ឥធលោកសុខ**

**បរលោកសុខ** *ន.* (បា.) សុខសម្រាប់ជាតិខាងមុខ។

**ឥធលោកសុខ** *ន.* (បា.) សុខក្នុងលោកនេះ គឺសុខសម្រាប់ជាតិនេះ។

📖 **បរត្ថបទ ពាក្យផ្ទុយ អត្តនោបទ**

**បរស្សបទ** *ន.* (បា.) បទដើម្បីអ្នកដទៃ។

**អត្តនោបទ** *ន.* (បា.) បទដើម្បីខ្លួន។

📖 **បរាធីន ពាក្យផ្ទុយ អត្តាធីន**

**បរាធីន** *ន.* (បា.) អ្នកដែលលុះនៅក្នុងអំណាចអ្នកដទៃ, អ្នកដែលលុះនៅក្នុងបង្គាប់នៃអ្នកដទៃ។

**អត្តាធីន** *ន.* (បា.) អ្នកដែលមិនលុះនៅក្នុងអំណាចអ្នកដទៃ, អ្នកដែលមិនលុះនៅក្នុងបង្គាប់នៃអ្នកដទៃ។

📖 **បាតរាស ពាក្យផ្ទុយ សាយមាស**

**បាតរាស** *ន.* (បា.សំ.) អាហារពេលព្រឹក, អាហារព្រឹក, អាហារស្រស់ស្រូប :

❖ ធ្វើបាតរាស

❖ ពេលបាតរាស។

**សាយមាស** *ន.* (បា.សំ.) ភោជនដែលត្រូវបរិភោគវេលាល្ងាច, ភោជនល្ងាច :

❖ បរិភោគសាយមាស

❖ ពេលសាយមាស (ហៅ សាយភោជន ក៏បាន)។

📖 **បាត់ខ្លួន** **ពាក្យផ្ទុយ** **មានខ្លួន**

**បាត់ខ្លួន** *កិ.* គ្មានរូបនៅជាអាង។

**មានខ្លួន** *កិ.* មានរូបនៅជាអាង។

📖 **បាបកម្ម** **ពាក្យផ្ទុយ** **បុញ្ញកម្ម**

**បាបកម្ម** *ន.* (បា.) អំពើអាក្រក់។

**បុញ្ញកម្ម** *ន.* (បា.) អំពើដែលជាបុណ្យ។

📖 **បាបគ្រោះ** **ពាក្យផ្ទុយ** **សោមគ្រោះ**

**បាបគ្រោះ** *ន.* (សំ.ភ្ល.) គ្រោះអាក្រក់, គ្រោះកាច។

**សោមគ្រោះ** *ន.* (សំ.ភ្ល.) គ្រោះល្អ, គ្រោះជា។

📖 **បុគ្គលបរិភោគ** **ពាក្យផ្ទុយ** **សង្ឃបរិភោគ**

**បុគ្គលបរិភោគ** *ន.* (បា.) ការប្រើប្រាស់របស់ក្នុងអំណាចបុគ្គល។

**សង្ឃបរិភោគ** *ន.* (បា.) ការប្រើប្រាស់របស់ក្នុងអំណាចសង្ឃ។

📖 **បុគ្គលិក ពាក្យផ្ទុយ សង្ឃិក**

**បុគ្គលិក** *គុ.* (បា.) ដែលចំពោះបុគ្គល, ដែលសម្រាប់បុគ្គលម្នាក់ៗមិនមែនជាសាធារណៈទូទៅ :

❖ របស់បុគ្គលិក។

**សង្ឃិក** *គុ.* (បា.) ដែលជារបស់សង្ឃ។

📖 **បុគ្គលិកទាន ពាក្យផ្ទុយ សង្ឃគតទាន, សង្ឃទាន**

**បុគ្គលិកទាន** *ន.* (បា.) ទានដែលទាយកឱ្យចំពោះបុគ្គល គឺឱ្យសំដៅរូបបុគ្គលតាមស្មគ្រស្រលាញ់គាប់ចិត្តបុគ្គលណាឱ្យសំដៅបុគ្គលនោះ។

**សង្ឃគតទាន** *ន.* (បា.សំ.) ទានដែលបង្អោនទៅចំពោះសង្ឃ គឺទានដែលទាយកប្រគេនចំពោះសង្ឃ។

**សង្ឃទាន** *ន.* (បា.សំ.) ទានដែលទាយកប្រគេនចំពោះសង្ឃ។

📖 **បុគ្គលិកបរិភោគ ពាក្យផ្ទុយ សង្ឃិកបរិភោគ**

**បុគ្គលិកបរិភោគ** *ន.* (បា.) ការប្រើប្រាស់របស់បុគ្គលក្នុងកិច្ចការ, ការប្រើប្រាស់របស់បុគ្គលក្នុងអំណាចបុគ្គល។

**សង្ឃិកបរិភោគ** *ន.* (បា.) ការប្រើប្រាស់របស់សង្ឃក្នុងកិច្ចការ, ការប្រើប្រាស់របស់សង្ឃក្នុងអំណាចសង្ឃ (ព.វិ.)។

📖 **បុនប្បុនក្កម្ម** **ពាក្យផ្ទុយ** **អបុនប្បុក្កម្ម**

**បុនប្បុនក្កម្ម** *ន.* (បា.) កម្មដដែលៗ គឺអំពើដដែលៗ, កិច្ចការដដែលៗ, ការរវល់ដដែលៗរបស់សត្វលោក។

**អបុនប្បុនក្កម្ម** *ន.* (បា.) ខន្ធនិព្វានដែលឥតកម្មដដែលៗ។

📖 **បុប្ផព្រឹក្ស** **ពាក្យផ្ទុយ** **ផលព្រឹក្ស**

**បុប្ផព្រឹក្ស** *ន.* (បា. និង សំ.ក្លា.) បុស្បព្រឹក្ស, ឈើដែលមានផ្កា។

**ផលព្រឹក្ស** *ន.* (បា. និង សំ.ក្លា.) ឈើដែលមានផ្លែ គឺឈើដែលបញ្ចេញផ្កាហើយកកើតជាផ្លែផង។

📖 **បុព្វណ្ហ:** **ពាក្យផ្ទុយ** **សាយណ្ហ:**

**បុព្វណ្ហ:** *ន.* (បា.ក្លា.) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

**សាយណ្ហ:** *ន.* (បា.ក្លា.) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហ:។

📖 **បុព្វណ្ហ** **ពាក្យផ្ទុយ** **សាយណ្ហ**

**បុព្វណ្ហ** *ន.* (បា.) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺ វេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

**សាយណ្ហ** *ន.* (បា.) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហ។

📖 **បុព្វណ្ហកាល ពាក្យផ្ទុយ សាយណ្ហកាល**

**បុព្វណ្ហកាល** *ន.* (បា.) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

**សាយណ្ហកាល** *ន.* (បា.) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហកាល។

📖 **បុព្វណ្ហសម័យ ពាក្យផ្ទុយ សាយណ្ហសម័យ**

**បុព្វណ្ហសម័យ** *ន.* (បា.ក្ល.) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

**សាយណ្ហសម័យ** *ន.* (បា.ក្ល.) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហសម័យ។

📖 **បំព្រៃប្រទេស ពាក្យផ្ទុយ បំភ្លឺប្រទេស**

**បំព្រៃប្រទេស** *កិ.* ធ្វើប្រទេសរបស់ខ្លួនឱ្យប្រហែលដូចជាព្រៃ។

**បំភ្លឺប្រទេស** *កិ.* ធ្វើប្រទេសរបស់ខ្លួនឱ្យភ្លឺល្វូតលាស់ចម្រើន, ធ្វើប្រទេសរបស់ខ្លួនឱ្យរុងរឿង, ធ្វើប្រទេសរបស់ខ្លួនឱ្យថ្កើងថ្កាន។

📖 **បំព្រៃលោក** **ពាក្យផ្ទុយ** **បំភ្លឺលោក**

**បំព្រៃលោក** *កិ.* ញុំាងលោកឱ្យប្រហែលដូចជាព្រៃ :

❖ ព្រះសម្ពុទ្ធទ្រង់ប្រទានព្រះឱវាទថា ន សិយា លោកវឌ្ឍនោ "កុំធ្វើខ្លួនឱ្យជាមនុស្សបំព្រៃលោក", មានអត្ថន័យថា កុំប្រព្រឹត្តអាក្រក់ហួសហេតុឱ្យមានខ្លួនប្រហែលដូចជាព្រៃទ្រុបទ្រុលឬប្រហែល ដូចជាចម្រូងចម្រឹង, ប្រហែលដូចជាដង្កត់ក្នុងលោកឱ្យគេទើសមុខទើសក្រោយ ឱ្យគេពិបាកចិត្តគំនិតអាប់អួចំបែងរាល់គ្នា។

**បំភ្លឺលោក** *កិ.* ញុំាងលោកឱ្យភ្លឺ, ញុំាងលោកឱ្យរុងរឿង, ញុំាងលោកឱ្យប្រកបដោយសុចរិតយុត្តិធម៌, ញុំាងលោកឱ្យបានសុខស្ងប់ :

❖ អ្នកប្រាជ្ញទាំងឡាយជាមនុស្សបំភ្លឺលោក; ព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយ ជាអ្នកបំភ្លឺលោកខាងការពន្យល់ឱ្យសត្វលោករាវរកធម៌ដើម្បីរំលត់ទុក្ខឃើញ។

📖 **ប្រមាថ** **ពាក្យផ្ទុយ** **អប្រមាថ**

**ប្រមាថ** *ន.* (សំ.) ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឱ្យ

គេលំបាក; ការមើលងាយគេ។

**អប្បមាទ** *ន.* (សំ.) ការមិនបៀតបៀន; ការមិនធ្វើទុក្ខបុកម្នេញអ្នកដទៃ។

📖 **ប្រមាទ ពាក្យផ្ទុយ អប្រមាទ**

**ប្រមាទ** *ន.* (សំ.) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្តីប្រហែស, ការធ្វេសប្រហែស។

**អប្រមាទ** *ន.* (សំ.) ការមិនភ្លេចស្មារតី, ការមិនធ្វេសស្មារតី, សេចក្តីមិនប្រហែស, ការមិនធ្វេសប្រហែស។

📖 **ប្រយោគវិបត្តិ ពាក្យផ្ទុយ ប្រយោគសម្បត្តិ**

**ប្រយោគវិបត្តិ** *ន.* (សំ.) ការមិនបរិបូរដោយកាយប្រយោគនិងវចីប្រយោគ គឺសភាពនៃបុគ្គលដែលអ្នកធំស្អប់, សភាពនៃបុគ្គលដែលអ្នកធំមិនស្គាល់ក៏ឃ្លាងចាកការឧបត្ថម្ភនៃអ្នកធំ :

- ❖ ប្រយោគវិបត្តិជាភាពរារាំងបាំងមុខកុសលមិនឱ្យចេញមុខផ្តល់ផលដល់បុគ្គលអ្នកបំពេញការកសាងបានឡើយ។

**ប្រយោគសម្បត្តិ** *ន.* (សំ.) ការបរិបូណ៌ដោយកាយប្រយោគនិងវចីប្រយោគ គឺសភាពនៃបុគ្គលដែលមានអ្នកធំស្រលាញ់រាប់អានកាន់ទ្រង់ក៏អាចញ៉ាំងសេចក្តីចម្រើនឱ្យលូតលាស់កើតកើនបាន :

❖ ប្រយោគសម្បត្តិអាចរារាំងបាំងមុខបាបតិចតួចស្ដួចស្ដើងឱ្យងាស់គាំងចេញមុខឱ្យផលពុំកើត។

📖 **ប្រាក់ដុំ** **ពាក្យផ្ទុយ** **ប្រាក់រាយ**

**ប្រាក់ដុំ** *ន.* ប្រាក់ដុំដែលមិនរលែកចែកដោយឡែក។

**ប្រាក់រាយ** *ន.* ប្រាក់រាយរងដែលរលែកចេញដោយឡែក។

📖 **ប្រែរៀងសេចក្ដី** **ពាក្យផ្ទុយ** **ប្រែលោតប្រយោគ**

**ប្រែរៀងសេចក្ដី** *កិ.* ប្រែពីភាសាមួយមកជាភាសាមួយ ដូចជាប្រែពីបាលីមកជាខ្មែរជាដើម, ក្នុងប្រយោគនីមួយៗមួយសង្កាត់ៗបណ្ដោយពីខាងដើមរៀងទៅតាមដំណើរសេចក្ដីមកជាខ្មែរ។

**ប្រែលោតប្រយោគ** *កិ.* ប្រែពីបាលីឬពីសំស្ក្រឹតក្នុងប្រយោគមួយៗមកជាខ្មែរដោយលោតផ្លោះតាមដំណើរសេចក្ដីខ្មែរ។

📖 **ផាសុក** **ពាក្យផ្ទុយ** **អផាសុក**

**ផាសុក** *ន.* (បា.) សេចក្ដីសុខ, សេចក្ដីសម្រាន្ត, សេចក្ដីសប្បាយ :

❖ នៅតាមផាសុក។

**អផាសុក** *ន.* (បា.) សេចក្ដីមិនសប្បាយ; សេចក្ដីអផ្សុក; សេចក្ដីព្រួយចិត្ត; ដំណើរមិនស្រួលចិត្ត; ដំណើរមិនសូវបានសុខ, ការប្រដាក់ប្រទុក្ខ (ដោយ

ហេតុមានជំងឺតម្កាត់ជាដើម)។

📖 **ផ្កាប់** **ពាក្យផ្ទុយ** **ផ្ងារ**

**ផ្កាប់** ***កិ.*** ដាក់ត្រលប់យកមុខឬបាតចុះក្រោម, ដាក់ត្រលប់យកពោះចុះក្រោម :

❖ ផ្កាប់មុខ។

**ផ្ងារ** ***កិ.*** ឬ ***កិ.វិ.*** ប្រែយកពោះមកខាងលើយកខ្នងទៅខាងក្រោមឬយកមុខមកខាងលើយកក្រោយទៅខាងក្រោម :

❖ ផ្ងារប្រអប់។

📖 **ផ្ទុយ** **ពាក្យផ្ទុយ** **ស្រប**

**ផ្ទុយ** ***កិ.វិ.*** ឬ ***គុ.*** ដែលច្រាសត្រលប់, ដែលមិនស្របគ្នា, ដែលជាទំនាស់នឹងគ្នា :

❖ ពាក្យផ្ទុយ។

**ស្រប** ***កិ.វិ.*** ឬ ***គុ.*** ដែលបណ្ដោយតាមគ្នា; ដែលមានសូរសម្លស្បចុងចួនត្រូវគ្នា :

❖ ពាក្យស្របគ្នា។

📖 **ផ្លាខ** **ពាក្យផ្ទុយ** **សាំខ, ស៊ាំ**

**ផ្លាខ** ***គុ.*** ដែលនៅផ្អើលភ្ញាក់មិនទាន់សាំង, ដែលមិនទាន់ស៊ាំ :

❖ គោផ្លាង។

**សាំង** *គុ.* ដែលមិនផ្លាង, ដែលមិនផ្អើល, ដែលងាយឱ្យចាប់ឱ្យកាន់ (ចំពោះតែសត្វ) :

❖ មាន់សាំង។

**ស៊ាំ** *គុ.* ថ្នឹក :

❖ ចិត្តស៊ាំ។

📖 **ពទ្ធសីមា** **ពាក្យផ្ទុយ** **អពទ្ធសីមា**

**ពទ្ធសីមា** *ន.* (**បា.**) ឈ្មោះសីមាមួយប្រភេទដែលសង្ឃសូត្រចងតាមលក្ខណៈច្បាប់វិន័យព្រះពុទ្ធសាសនាកំណត់ជាព្រំដែនសម្រាប់ធ្វើសង្ឃកិច្ចផ្សេងៗ :

❖ ពទ្ធសីមាវត្ត (ព.វិ.ពុ.)។

**អពទ្ធសីមា** *ន.* (**បា.**) សីមាដែលសង្ឃមិនបាច់សូត្រចង។ មាន៣យ៉ាង :

១- **គាមសីមា** : ព្រំដែនស្រុក។

២- **ឧទកុក្ខេបសីមា** : ព្រំដែនដែលសាចទឹកក្នុងទឹកនឹងថ្កល់មិនហូរ។

៣- **អព្ភន្តរសីមា** : ព្រំដែនក្នុងព្រៃស្ងួតដែលវាស់ប្រវែង៧អព្ភន្តរគឺ៤៩ព្យាមឬ១៩៦ហត្ថជុំវិញរៀងខ្លួន (ព.វិ.ពុ.)។

📖 **ពហុវចនៈ** **ពាក្យផ្ទុយ** **ឯកវចនៈ**

**ពហុព្យាង្គ** *គុ.* ឬ *ន.* (បា.) សព្ទដែលមានព្យាង្គច្រើន គឺសព្ទឬសម្ដីដែលមានសូរច្រើនម៉ាត់តាំងពីបីម៉ាត់ឡើងទៅ :

- ❖ កន្ទាទូក
- ❖ កន្ទក់កន្ទេញ។

**ឯកព្យាង្គ** *ន.* (បា.) ពាក្យមួយព្យាង្គដូចជា កត់, កប, កាត់, គង, ទំ, នំ ជាដើម ។

📖 **ពហុវចនៈ ពាក្យផ្ទុយ ឯកវចនៈ**

**ពហុវចនៈ** *ន.* (បា.ភ្ល.) ពាក្យសម្រាប់ប្រើក្នុងវេយ្យាករណ៍ប្រាប់ចំនួនច្រើន។

**ឯកវចនៈ** (បា.ភ្ល.) ពាក្យប្រាប់ចំនួនតែមួយឬតែម្នាក់, ដូចជា គោមួយ, សៀវភៅមួយ, ក្មេងម្នាក់ ជាដើម (ព.វ.)។

📖 **ពាហិរត្ថ ពាក្យផ្ទុយ អព្ភន្តរត្ថ**

**ពាហិរត្ថ** *ន.* (បា.) រូបសេចក្ដីដែលនៅក្នុងពាហិរសញ្ញា (លេខក្រៅ)។

**អព្ភន្តរត្ថ** *ន.* (បា.) រូបសេចក្ដីដែលនៅក្នុងអព្ភន្តរសញ្ញា (លេខក្នុង), ដូចជាកាលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ជិតចូលបរិនិព្វានទ្រង់ត្រាស់ផ្ដាំថា :

- ❖ អ្នកទាំងឡាយចូរកុំប្រមាទ!។

📖 **ពិរោធ ពាក្យផ្ទុយ អពិរោធ**

**ពិរោធ** *ន.* (បា.សំ.ភ្ល.) កំហឹង; កំហុស; សេចក្ដីស្អប់; ជម្លោះ; សត្រូវ។

**អពិរោធ** *ន.* (បា.សំ.ក្ល.) សេចក្ដីមិនពិរោធ; ដំណើរឥតកំហុស, ដំណើរឥតសេចក្ដីស្អប់; អ្នកដែលឥតពិរោធ, អ្នកដែលឥតកំហុស។

📖 **ពិស្ដារ** **ពាក្យផ្ទុយ** **សង្ខេប**

**ពិស្ដារ** *ន.* (សំ.ក្ល.) សេចក្ដីទូលាយ, សេចក្ដីវែង; ដំណើរយឺតយូរ :

❖ និយាយដោយពិស្ដារ។

**សង្ខេប** *ន.* (បា.) សេចក្ដីបំប្រួញ, សេចក្ដីយ៉ :

❖ និយាយដោយសង្ខេប។

📖 **ពុទ្ធប្បញ្ញត្តិ** **ពាក្យផ្ទុយ** **ពុទ្ធានុញ្ញាត**

**ពុទ្ធប្បញ្ញត្តិ** *ន.* (បា.) បម្រាមព្រះពុទ្ធ គឺវិន័យដែលព្រះពុទ្ធទ្រង់ត្រាស់ហាមមិនឱ្យពួកបព្វជិតប្រព្រឹត្តកន្លងព្រោះទ្រង់យល់ថាជាទោសដែលអ្នកបួសត្រូវវៀរ។

**ពុទ្ធានុញ្ញាត** *កុ.* ឬ *ន.* (បា.) វិន័យដែលព្រះពុទ្ធទ្រង់អនុញ្ញាត គឺដែលទ្រង់យល់ព្រមឱ្យធ្វើ, ដែលទ្រង់យល់ព្រមឱ្យប្រព្រឹត្ត, ដែលទ្រង់យល់ព្រមឱ្យប្រតិបត្តិព្រោះទ្រង់យល់ឃើញថាមានប្រយោជន៍ :

❖ វិន័យនេះជាពុទ្ធានុញ្ញាត, នុ៎ះជាពុទ្ធប្បញ្ញត្តិ (ព.វិ.ពុ.)។

📖 **ពុទ្ធិ** **ពាក្យផ្ទុយ** **អពុទ្ធិ**

**ពុទ្ធិ** *ន.* (**បា.សំ.**) ប្រាជ្ញា, ការយល់ :

❖ មនុស្សមានពុទ្ធិ។

**អពុទ្ធិ** *ន.* (**បា.សំ.**) សេចក្ដីល្ងង់; ដំណើរមមិងមមាំង, ការមិនដឹងរង៉េះរង៉ោះ; ការមិនយល់អ្វីសោះ :

❖ មនុស្សអពុទ្ធិ។

📖 **ពុំសូវមានព្រះអង្គ ពាក្យផ្ទុយ មានព្រះអង្គ**

**ពុំសូវមានព្រះអង្គ** *គុ.* (រ.ស. ឬ ស.ស.) ស្គម។

**មានព្រះអង្គ** *គុ.* (រ.ស. ឬ ស.ស.) ធាត់។

📖 **ពោះដំឡើង ពាក្យផ្ទុយ ពោះសម្រក**

**ពោះដំឡើង** *ន.* ផ្ទៃទឹកដែលឡើង, ផ្ទៃទឹកដែលកំពុងឡើង :

❖ ពោះដំឡើងទន្លេ

❖ ពោះដំឡើងស្ទឹង។

**ពោះសម្រក** *ន.* ផ្ទៃទឹកដែលស្រក, ផ្ទៃទឹកដែលកំពុងស្រក :

❖ ពោះសម្រកទន្លេ

❖ ពោះសម្រកស្ទឹង។

📖 **ព្យាធៈ ពាក្យផ្ទុយ សុខៈ**

**ព្យញ្ជនៈ** *ន.* (បា.ក្ល.) ម្ហូបក្រៅពីសម្លទឹក :

❖ ម្ហូបខាប់

❖ ម្ហូបគោក

❖ ម្ហូបក្រៀម។

**សូបៈ** *ន.* (បា.ក្ល.) សម្លទឹក, ម្ហូបមានទឹក។

📖 **ព្យត្ត　　　ពាក្យផ្ទុយ　　　អព្យត្ត**

**ព្យត្ត** *គុ.* (បា.) ដែលឈ្លាស, ដែលប៉ិន, ដែលវាងវៃ :

❖ មនុស្សព្យត្ត។

**អព្យត្ត** *គុ.* (បា.) ដែលមិនឈ្លាស, ដែលមិនប៉ិន, ដែលមិនវាងវៃ :

❖ មនុស្សអព្យត្ត។

📖 **ព្យាបាទ　　　ពាក្យផ្ទុយ　　　អព្យាបាទ**

**ព្យាបាទ** *ន.* (បា.) ដំណើរចងចិត្តនឹងធ្វើអ្នកដទៃឱ្យវិនាស, សេចក្ដីគុំក្ួន។

**អព្យាបាទ** *ន.* (បា.) ការមិនព្យាបាទ គឺការមិនចងគំនុំ, ការមិនគុំក្ួន។

📖 **ព្រហ្មចរិយ　　　ពាក្យផ្ទុយ　　　អព្រហ្មចរិយ**

**ព្រហ្មចរិយ** *ន* (បា) បែបបទរបស់ព្រហ្មចរិយ, សណ្ដាប់ធ្នាប់របស់ព្រហ្មចរិយ; ការប្រព្រឹត្តធម៌ដ៏ប្រសើរ។ (ហៅ ព្រហ្មចរិយធម៌ ក៏បាន)។

**អព្រហ្មចរិយ** *ន.*(បា.) ការមិនប្រព្រឹត្តព្រហ្មចរិយ (ហៅ អព្រហ្មចរិយធម៌ ក៏បាន)។

📖 **ព្រហ្មចារិនី ពាក្យផ្ទុយ អព្រហ្មចារិនី**

**ព្រហ្មចារិនី** *ន.* (បា.) ស្ត្រីអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ។

**អព្រហ្មចារិនី** *ន.* (បា.) ស្ត្រីអ្នកដែលមិនមែនជាព្រហ្មចារិនី។

📖 **ព្រហ្មចារី ពាក្យផ្ទុយ អព្រហ្មចារី**

**ព្រហ្មចារី** *ន.* (បា.) អ្នកប្រព្រឹត្តព្រហ្មចារ្យ។ ពាក្យនេះតាមលទ្ធិព្រាហ្មណ៍សំដៅយកអ្នកដែលកំពុងហាត់រៀនវេទ ឬអ្នកដែលកំពុងសិក្សាលទ្ធិសាសនាសំដៅយកអ្នកដែលកំពុងហាត់រៀនវេទ ឬសំដៅចំពោះតែអ្នកដែលរៀនមេថុនធម្មដោយដាច់ខាតយ៉ាងដូចបព្វជិតមានភិក្ខុសាមណេរជាដើម។ តាមលទ្ធិបុរាណសំដៅយកកុមារឬកុមារីដែលនៅលីវសុទ្ធសាធ; ខាងលទ្ធិខ្មែរដែលប្រើតាមទម្លាប់ច្រើនតែសំដៅយកកុមារីជំទង់ហៅថា ស្ត្រីព្រហ្មចារី; តែបើតាមបែបត្រឹមត្រូវ :

✍ ព្រហ្មចារិនី សម្រាប់ហៅស្ត្រី។

✍ ព្រហ្មចារី សម្រាប់ហៅបុរស។

**អព្រហ្មចារី** *ន.* (បា.) អ្នកដែលមិនមែនជាព្រហ្មចារី។

📖 **ព្រហ្មចារ្យ ពាក្យផ្ទុយ អព្រហ្មចារ្យ**

**ព្រហ្មចារ្យ** *ន.* (សំ.ភ្ល.) បែបបទរបស់ព្រហ្មចារីឬព្រហ្មចារិនី, សណ្ដាប់ធ្នាប់របស់ព្រហ្មចារីឬព្រហ្មចារិនី; ការប្រព្រឹត្តធម៌ដ៏ប្រសើរ។ តាមន័យខាងពុទ្ធសាសនាថា ការឱ្យទាន, ការខ្វល់ខ្វាយ, ការខ្នះខ្នែងចំពោះអំពើជាកុសល, ការរក្សាសីល៥, ការចម្រើនព្រហ្មវិហារ៤ ការសម្ដែងធម៌ឬណែនាំពន្យល់ឱ្យអ្នកដទៃកាន់អំពើសុចរិត, ការវៀរចាកមេថុនធម្ម, សេចក្ដីសន្ដោសចំពោះភរិយារបស់ខ្លួន, សេចក្ដីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការកុសល, ការរក្សាឧបោសថសីលតាមកាលកំណត់, អរិយមគ្គ, ព្រះពុទ្ធសាសនាទាំងមូល, អធ្យាស្រ័យ (ទាំង១២យ៉ាងនេះ) ហៅថា ព្រហ្មចារ្យ (ហៅថា ព្រហ្មចរិយធម៌ក៏បាន)។

**អព្រហ្មចារ្យ** *ន.* (ឆ.) ការមិនប្រព្រឹត្តព្រហ្មចារ្យ (ហៅ អព្រហ្មចរិយធម៌ ក៏បាន)។

📖 **ព្រឹក** **ពាក្យផ្ទុយ** **ល្ងាច**

**ព្រឹក** *ន.* វេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ; ដរាបដល់ថ្ងៃត្រង់ក៏នៅហៅ ព្រឹក បានដែរ។

**ល្ងាច** *ន.* វេលាដែលព្រះអាទិត្យទោរទាបចុះ :

- ធ្វើការតាំងពីព្រឹកដល់ល្ងាច។

📖 **ព្រៃខាង** **ពាក្យផ្ទុយ** **ស្រុកខាង**

**ព្រៃខារ** *ន.* ជនជាតិវេស្ស:ឬវៃស្ស: (ក្នុងកម្ពុជប្រទេសមានតែក្នុងរជ្ជកាលអំពីដើម)។

**អ្នកខារ** *ន.* អ្នកធ្វើការងារមានកម្រិតតាមរាជប្បញ្ញត្តិ គឺជនដែលត្រូវទោសរបឹបជាដើមហើយធ្លាក់ខ្លួនទៅជាមនុស្សថ្នាក់ទី៤ (សូទ្រ:) ជាប់ជាពូជវង្សតរៀងទៅឬជនដែលកើតក្នុងពូជវង្សនោះ :

- ❖ ពួកអ្នកងារ
- ❖ ពូជអ្នកងារ។

☞ ក្នុងកម្ពុជរដ្ឋលើកលែងមិនឱ្យមានអ្នកងារពីក្នុងឆ្នាំរោង ចត្វាស័ក ព.ស.២៤៣៦ គ.ស.១៨៩២; តាំងពីនោះមកពាក្យថា អ្នកខារ ថា ព្រៃខារ ក៏បាត់បន្តិចម្តងៗដរាបមកដល់សម័យបច្ចុប្បន្ននេះ។

📖 **គព្វ** **ពាក្យផ្ទុយ** **អគព្វ**

**គព្វ** *គុ.* (បា.) ភព្យ, ដែលគួរ, ដែលគួរដល់កិច្ចការ; ដែលមានសំណាងល្អ, ដែលមានសេចក្តីសុខ។

**អគព្វ** *គុ.* (បា.) អភព្យ, ដែលមិនគួរ, ដែលពុំគួរដល់កិច្ចការ, ដែលពុំអាច; ដែលឥតសំណាងល្អ, ដែលមានសំណាងតិច; ដែលឃ្លាងចាកប្រយោជន៍, ដែលឃ្លាងចាកមគ្គផល។

📖 **គព្វបុគ្គល ពាក្យផ្ទុយ អគព្វបុគ្គល**

**គព្វបុគ្គល** *ន.* (បា.) បុគ្គលដែលមានសំណាងល្អ; បុគ្គលដែលគួរបួសជាបព្វជិតក្នុងព្រះពុទ្ធសាសនាបាន។

**អគព្វបុគ្គល** *ន.* (បា.) បុគ្គលអភព្វ។ បុគ្គលដែលមិនគួរបួសក្នុងព្រះពុទ្ធសាសនាបាន (ព.វិ.ពុ.)។

📖 **គព្វរូប ពាក្យផ្ទុយ អគព្វរូប**

**គព្វរូប** *គុ.* (បា.) ដែលមានសភាពដ៏សមគួរ។

**អគព្វរូប** *ន.* (បា.) សភាពពុំសមគួរ; ដែលមានសភាពពុំសមគួរ; ការឃ្លាងចាកប្រយោជន៍, ការឃ្លាងចាកលាភ; សេចក្ដីទុក្ខ។

📖 **ភាព ពាក្យផ្ទុយ អភាព**

**ភាព** *ន.* (បា.សំ.ភ្ល.) ភាវៈ; បែប, បែបបទ; លំនាំ, លំនាំសមសា, ឫកពា; ទម្រង់, សណ្ឋាន, ទ្រង់ទ្រាយ; ភេទ :

- ភាពល្អ
- ភាពអាក្រក់
- ភាពត្រឹមត្រូវ។

**អភាព** *ន.* (បា.សំ.ភ្ល.) ការឥតភាព; ការមិនមាន; សេចក្ដីស្លាប់។

📖 **ភូត** **ពាក្យផ្ទុយ** **សម្ភវេសី**

**ភូត** *ន.* (បា.សំ.) អ្វីដែលកើតមានហើយ; ទេវតា; សត្វលោក; ខ្មោចបិសាច; បញ្ចក្ខន្ធ; ធាតុទាំងបួន; សេចក្ដីពិត។

**សម្ភវេសី** *ន.* (បា.) អ្នករកដំណើរកើត គឺសត្វដែលនៅក្នុងគភ៌ឬនៅក្នុងស្រោមស៊ុតបម្រុងនឹងសម្រាលឬញាស់តាមកាលកំណត់ (ចំពោះ ជលម្ពុជៈ និង អណ្ឌជៈ); សត្វដែលផ្ដើមចាប់កំណើតក្នុងខណៈចិត្តទី១ឬដែលផ្ដើមចាប់កំណើតឡើងដោយឥរិយាបថណានៅមិនទាន់ផ្លាស់ឥរិយាបថនោះ (ចំពោះ សំសេទជៈ និង ឧបបាតកៈ); សត្វដែលកំពុងស្វែងរកទីកើតតៗទៅទៀត (និយាយដោយរួបរួម); បើស្ត្រីជា សម្ភវេសិនី (តែមិនសូវប្រើ)។

📖 **ភេជ្ជរូប** **ពាក្យផ្ទុយ** **អភេជ្ជរូប**

**ភេជ្ជរូប** *គុ.* ឬ *ន.* (បា.) ដែលមានសភាពឆាប់ធ្លុះធ្លាយ, ឆាប់បែក, ដែលមិនជាប់បានយូរ, ឆាប់ខូច, មិនជាស្ថាពរ :

❖ របស់ភេជ្ជរូប។

**អភេជ្ជរូប** *គុ.* ឬ *ន.* (បា.) ដែលមានសភាពរឹងប៉ឹង, មាំ, ជាប់បានយូរ, មិនងាយធ្លុះធ្លាយ, ជាស្ថាពរ :

❖ របស់អភេជ្ជរូប។

📖 **ឆ្លូក** **ពាក្យផ្ទុយ** **ស្ទ**

**ឆ្លូក** *ន.* អវយវៈជាឆ្អឹងដុះចេញពីក្នុងមាត់ដំរីឈ្មោលមានសណ្ឋានមូលធំចុងស្រួចកាលណាលូតវែងមានទ្រង់ទ្រាយងទន្ទាំ, តាមធម្មតាតែងតែដុះចេញមកមួយគូ, ប៉ុន្តែចួនណាដុះទោលតែមួយក៏មានខ្លះហៅថា ឆ្លូកឧក។ ដំរីឈ្មោលដែលដុះភ្លុកពីកំណើតគេមិនហៅ ឈ្មោល ទេគេហៅ ឆ្លូក :

❖ ហ្មដំរីខ្លះទាក់បានភ្លុក ខ្លះទាក់បានស្ទ (បើញីគេហៅ មេ គេមិនហៅ ញី ទេ)។

**ស្ទ** *ន.* ដំរីឈ្មោលឥតភ្លុកមានតែចៃ, បើដំរីឈ្មោលឥតភ្លុកឥតចៃហៅ គោត។

📖 **មង្គល** **ពាក្យផ្ទុយ** **អមង្គល, អពមង្គល**

**មង្គល** *ន.* (បា.សំ.) សេចក្តីចម្រើន; សេចក្តីសុខ; ហេតុដែលនាំឱ្យកើតសេចក្តីសុខចម្រើន; ស្រីសួស្តី។

**អមង្គល** *គុ.* (បា.សំ.) ដែលប្រាសចាកមង្គល, ដែលឃ្លាងចាកមង្គល គឺដែលឥតមង្គល, ដែលឥតសេចក្តីចម្រើន; ដែលមិនសមដល់ភ្នែកអ្នកផង; ដែលត្រូវចង្រៃរួមរឹត។

**អពមង្គល** *ន.* (បា.សំ.ភ្ល.) សេចក្តីមិនចម្រើន; ហេតុដែលនាំឱ្យវិនាស, ហេតុដែលនាំឱ្យអាប់ឱន។

📖 **មហាថេរ** **ពាក្យផ្ទុយ** **អនុត្ថេរ**

**មហាថេរ** *ន.* (បា.) ថេរៈធំ, ព្រះថេរៈធំ។ បើភិក្ខុនីជាមហាថេរី "ថេរីធំ"។

**អនុត្ថេរ** *ន.* (បា.) ថេរៈបន្ទាប់, ថេរៈតូច។

📖 **មហិច្ឆតា** **ពាក្យផ្ទុយ** **អប្បិច្ឆតា**

**មហិច្ឆតា** *ន.* (បា.) សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន់ :

❖ មហិច្ឆតាជាធម្មជាតិនាំឱ្យមានការច្រណែនឈ្នានីសចំពោះគ្នីគ្នា។

**អប្បិច្ឆតា** *ន.* (បា.) បែបបទនៃអ្នកដែលមានសេចក្តីប្រាថ្នាតិច :

❖ ចិញ្ចឹមជីវិតដោយអប្បិច្ឆតា។

📖 **មហិច្ឆតាភាព** **ពាក្យផ្ទុយ** **អប្បិច្ឆតាភាព**

**មហិច្ឆតាភាព** *ន.* (បា.ភ្ល.) សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន់ :

❖ មហិច្ឆភាពជាធម្មជាតិនាំឱ្យមានការច្រណែនឈ្នានីសចំពោះគ្នីគ្នា។

**អប្បិច្ឆតាភាព** *ន.* (បា.ភ្ល.) បែបបទនៃអ្នកដែលមានសេចក្តីប្រាថ្នាតិច :

❖ ចិញ្ចឹមជីវិតដោយអប្បិច្ឆភាព។

📖 **មហេសក្ខ** **ពាក្យផ្ទុយ** **អប្បេសក្ខ**

**មហេសក្ខ** *គុ.* ឬ *ន.* (បា.) ពាក្យសម្រាប់ហៅទេវតាដែលមានអានុភាពធំ;

ក្នុងកាព្យប្រើជា មហេសក្ខា ក៏បាន។

**អប្បេសក្ខ** *គុ.* (បា.) ដែលមានអំណាចតិច, ដែលខ្សោយអំណាចជាងគេ, ដែលតូចជាងគេ។

**🕮 មានពុត ពាក្យផ្ទុយ ស្លូតត្រង់**

**មានពុត** *គុ.* ដែលមានចិត្តរបិញរបុញ។

**ស្លូតត្រង់** *គុ.* ស្លូតផងត្រង់ផង។

**🕮 មានព្រលឹង ពាក្យផ្ទុយ មិនសូវមានព្រលឹង**

**មានព្រលឹង** *គុ.* មានសាច់, ធាត់។

**មិនសូវមានព្រលឹង** *គុ.* មិនសូវមានសាច់, ស្គម។

**🕮 មិច្ឆា ពាក្យផ្ទុយ សម្មា**

**មិច្ឆា** *កិ.វិ.* ឬ *គុ.* (បា.) ខុស, មិនពិត, មិនមែន។

**សម្មា** *និ.* (បា.) ប្រពៃ, ពិត, មែន, ត្រូវ, ត្រឹមត្រូវ។

**🕮 មិច្ឆាកម្មន្តៈ ពាក្យផ្ទុយ សម្មាកម្មន្តៈ**

**មិច្ឆាកម្មន្តៈ** *ន.* (បា.ក្ល.) ការងារខុស។

**សម្មាកម្មន្តៈ** *ន.* (បា.ក្ល.) ការងារត្រូវ។

**🕮 មិច្ឆាចារ ពាក្យផ្ទុយ សម្មាចារ**

**មិច្ឆាចារ** *ន.* (បា.) ដំណើរប្រព្រឹត្តទាស់ខុសប្រពៃណី; មារយាទអាក្រក់។

**សម្មាចារ** *ន.* (បា.) ការកាន់ត្រូវ; មារយាទត្រឹមត្រូវ; មារយាទល្អ។

📖 **មិច្ឆាជីព ពាក្យផ្ទុយ សម្មាជីព**

**មិច្ឆាជីព** *ន.* (បា.សំ.) ការចិញ្ចឹមជីវិតខុស។

**សម្មាជីព** *ន.* (បា.សំ.) ការចិញ្ចឹមជីវិតត្រូវ។

📖 **មិច្ឆាជីវ ពាក្យផ្ទុយ សម្មាជីវ**

**មិច្ឆាជីវ** *ន.* (បា.) ការចិញ្ចឹមជីវិតខុស។

**សម្មាជីវ** *ន.* (បា.) ការចិញ្ចឹមជីវិតត្រូវ។

📖 **មិច្ឆាជីវៈ ពាក្យផ្ទុយ សម្មាជីវៈ**

**មិច្ឆាជីវៈ** *ន.* (បា.សំ.) ការចិញ្ចឹមជីវិតខុស។

**សម្មាជីវៈ** *ន.* (បា.សំ.) ការចិញ្ចឹមជីវិតត្រូវ។

📖 **មិច្ឆាអាជីវ ពាក្យផ្ទុយ សម្មាអាជីវ**

**មិច្ឆាអាជីវ** *ន.* (បា.) ការចិញ្ចឹមជីវិតខុស។

**សម្មាអាជីវ** *ន.* (បា.) ការចិញ្ចឹមជីវិតត្រូវ។

📖 **មិច្ឆាអាជីវោ ពាក្យផ្ទុយ សម្មាអាជីវោ**

**មិច្ឆាអាជីវោ** *ន.* (បា.) ការចិញ្ចឹមជីវិតខុស។

**សម្មាអាជីវោ** *ន.* (បា.) ការចិញ្ចឹមជីវិតត្រូវ។

📖 **មិច្ឆាទស្សនៈ ពាក្យផ្ទុយ សម្មាទស្សនៈ**

**មិច្ឆាទស្សនៈ** *ន.* (បា.ភ្ល.) ការយល់ឃើញខុស។

**សម្មាទស្សនៈ** *ន.* (បា.ភ្ល.) ការយល់ឃើញត្រូវ។

📖 **មិច្ឆាទិដ្ឋិ ពាក្យផ្ទុយ សម្មាទិដ្ឋិ**

**មិច្ឆាទិដ្ឋិ** *ន.* (បា.) សេចក្ដីយល់ឃើញខុស គឺដំណើរយល់ខុសអំពីសេចក្ដីពិត ដូចយ៉ាងយល់ឃើញថា មាតាបិតាគ្មានគុណ, សត្វទាំងអស់ស្លាប់ហើយលែងកើតទៀតជាដើម។

**សម្មាទិដ្ឋិ** *ន.* (បា.) សេចក្ដីយល់ឃើញត្រូវ។

📖 **មិច្ឆាបដិបត្តិ ពាក្យផ្ទុយ សម្មាបដិបត្តិ**

**មិច្ឆាបដិបត្តិ** *ន.* (បា.) ការប្រតិបត្តិខុស។

**សម្មាបដិបត្តិ** *ន.* (បា.) ការប្រតិបត្តិត្រូវ។

📖 **មិច្ឆាវាចា ពាក្យផ្ទុយ សម្មាវាចា**

**មិច្ឆាវាចា** *ន.* (បា.ភ្ល.) សម្ដីខុស គឺការប្រើវាចាខុសគន្លងមានពោលពាក្យកុហក, ពាក្យញុះញង់ជាដើម។

**សម្មាវាចា** *ន.* (បា.) សម្ដីត្រូវ។

📖 **មិច្ឆាវាយាម ពាក្យផ្ទុយ សម្មាវាយាម**

**មិច្ឆាព្យាយាម** *ន.* (បា. និង សំ.ក្ល.) ព្យាយាមខុស គឺព្យាយាមធ្វើអំពើអាក្រក់។

**សម្មាព្យាយាម** *ន.* (បា. និង សំ.ក្ល.) ព្យាយាមត្រូវគឺព្យាយាមធ្វើអំពើល្អ។

📖 **មិច្ឆាមគ្គ ពាក្យផ្ទុយ សម្មាមគ្គ**

**មិច្ឆាមគ្គ** *ន.* (បា.) ផ្លូវខុស គឺផ្លូវដែលមិនពិត, គន្លងដែលមិនពិត។

**សម្មាមគ្គ** *ន.* (បា.) ផ្លូវត្រូវ, គន្លងត្រូវ, លំអានត្រូវ។

📖 **មិច្ឆាវាចា ពាក្យផ្ទុយ សម្មាវាចា**

**មិច្ឆាវាចា** *ន.* (បា.) សម្ដីខុស គឺការប្រើវាចាខុសគន្លងមានពោលពាក្យកុហក, ពាក្យញុះញង់ជាដើម។

**សម្មាវាចា** *ន.* (បា.) សម្ដីត្រូវ គឺការប្រើវាចាត្រូវគន្លងមានពោលពាក្យមិនកុហក, ពាក្យមិនញុះញង់ជាដើម។

📖 **មិច្ឆាសង្កប្បៈ ពាក្យផ្ទុយ សម្មាសង្កប្បៈ**

**មិច្ឆាសង្កប្បៈ** *ន.* (បា.ក្ល.) សេចក្ដីត្រិះរិះខុស, តម្រិះខុស។

**សម្មាសង្កប្បៈ** *ន.* (បា.ក្ល.) សេចក្ដីត្រិះរិះត្រូវ, តម្រិះត្រូវ។

📖 **មិច្ឆាសតិ ពាក្យផ្ទុយ សម្មាសតិ**

**មិច្ឆាសតិ** *ន.* (បា.) សតិខុស, ការរលឹកខុស។

**សម្មាសតិ** *ន.* (បា.) សតិត្រូវ, ការរលឹកត្រូវ។

📖 **មិច្ឆាសមាធិ ពាក្យផ្ទុយ សម្មាសមាធិ**

**មិច្ឆាសមាធិ** *ន.* (បា.) សមាធិខុស។

**សម្មាសមាធិ** *ន.* (បា.) សមាធិត្រូវ។

📖 **មិត្ត ពាក្យផ្ទុយ អមិត្ត**

**មិត្ត** *ន.* (បា.) អ្នកដែលរាប់អានគ្នាជិតដិត, មនុស្សដែលស្រលាញ់រាប់រកគ្នាយ៉ាងជិតស្និទ្ធ, សម្លាញ់។

**អមិត្ត** *ន.* (បា.) អ្នកដែលមិនមែនជាមិត្ត (សត្រូវ)។

📖 **មិត្តភាព ពាក្យផ្ទុយ អមិត្តភាព**

**មិត្តភាព** *ន.* (បា.ភ្ន.) ភាពនៃមិត្ត គឺបែបបទសណ្ដាប់ធ្នាប់របស់មិត្ត :

❖ រាប់អានគ្នាដោយមិត្តភាព។

**អមិត្តភាព** *ន.* (បា.ភ្ន.) ភាពនៃបុគ្គលមិនមែនជាមិត្ត, ភាពនៃជនជាសត្រូវ, ការដែលជាខ្មាំងសត្រូវនឹងគ្នា, ទោសសត្រូវ។

📖 **មិត្រ ពាក្យផ្ទុយ អមិត្រ**

**មិត្រ** *ន.* (សំ.) អ្នកដែលរាប់អានគ្នាជិតដិត, មនុស្សដែលស្រលាញ់រាប់រកគ្នាយ៉ាងជិតស្និទ្ធ, សម្លាញ់។

**អមិត្រ** *ន.* (សំ.) អ្នកដែលមិនមែនជាមិត្រ (សត្រូវ)។

📖 **មោឃ** **ពាក្យផ្ទុយ** **អមោឃ**

**មោឃ** *គុ.* (បា.សំ.) ដែលសោះសូន្យ, ដែលឥតប្រយោជន៍, ដែលអសារឥតការ, ដែលអសារឥតអំពើ; ទទេ, ឃែត, ចោលម្សៀត។

**អមោឃ** *គុ.* (បា.សំ.) ដែលមិនមែនទទេ, ដែលមិនសោះសូន្យ, ដែលមិនឥតប្រយោជន៍, ដែលមិនឥតអំពើ គឺកើតការ, បានការ, មានប្រយោជន៍។

📖 **មោហៈ** **ពាក្យផ្ទុយ** **អមោហៈ**

**មោហៈ** *ន.* (បា.សំ.ភ្ល.) អវិជ្ជា, សេចក្ដីវង្វេង, សេចក្ដីល្ងង់, សេចក្ដីភន្តស្មារតីមិនយល់ការណ៍ពិត, សេចក្ដីមិនស្គាល់ខុសត្រូវ។

**អមោហៈ** *ន.* (បា.សំ.ភ្ល.) ការមិនវង្វេងស្មារតី, ការមិនភន្តច្រលំ, សេចក្ដីដឹង; ការស្គាល់ខុសត្រូវ; ប្រីជា, ប្រាជ្ញា។

📖 **មោហោ** **ពាក្យផ្ទុយ** **អមោហោ**

**មោហោ** *ន.* (បា.សំ.) អវិជ្ជា, សេចក្ដីវង្វេង, សេចក្ដីល្ងង់, សេចក្ដីភន្តស្មារតីមិនយល់ការណ៍ពិត, ការមិនស្គាល់ខុសត្រូវ។

**អមោហោ** *ន.* (បា.សំ.) ការមិនវង្វេងស្មារតី, ការមិនភន្តច្រលំ, សេចក្ដីដឹង; ការស្គាល់ខុសត្រូវ។

📖 **ម្ដាយមាន់** **ពាក្យផ្ទុយ** **ម្ដាយអណ្ដើក**

**ម្ដាយមាន់** *ន.* ម្ដាយដូចជាមេមាន់។

**ម្ដាយអណ្ដើក** *ន.* ម្ដាយណាដែលគ្រាន់តែបង្កើតកូនមកហើយក៏បោះបង់ចោលមិនបីបាច់រក្សា, អ្នកប្រាជ្ញលោកពោលដោយឧបមាថា ម្ដាយនោះឯងដូចជាមេអណ្ដើកដែលគ្រាន់តែបញ្ចេញស៊ុតហើយ ក៏កកាយដីលុបកប់ស៊ុតហើយបោះបង់ចោលឥតនឹកនាដូច្នោះដែរ; លទ្ធិពុទ្ធពោលថា ទោះបីយ៉ាងនេះក៏ដោយមាតានោះក៏ឈ្មោះថាជា ម្ដាយនៃកូននោះហើយ, កាលបើកូននោះបានស្គាល់ថាជាម្ដាយបង្កើតរបស់ខ្លួនក៏ត្រូវតែកូននោះជា កតវេទី ឬ កតវេទិនី ចំពោះម្ដាយនោះដែរ។

📖 **យស** **ពាក្យផ្ទុយ** **អយស**

**យស** *ន.* (**បា.សំ.**) អានុភាព; ឥស្សរភាព; បរិវារ; ទ្រព្យធន; កេរ្តិ៍ឈ្មោះល្អ; សេចក្ដីថ្កើងថ្កាន។

**អយស** *ន.* (**បា.សំ.**) គ្មានអានុភាព; គ្មានឥស្សរភាព; គ្មានបរិវារ; គ្មានទ្រព្យធន; គ្មានកេរ្តិ៍ឈ្មោះល្អ; គ្មានសេចក្ដីថ្កើងថ្កាន។

📖 **យុត្តិធម៌** **ពាក្យផ្ទុយ** **អយុត្តិធម៌**

**យុត្តិធម៌** *ន.* (**បា.** និង **សំ.**) ធម៌ដែលគួរកាន់; សេចក្ដីទៀងត្រង់; ការប្រព្រឹត្តត្រឹមត្រូវ :

❖ វិនិច្ឆ័យក្ដីដោយយុត្តិធម៌។

**អយុត្តិធម៌** *ន.* (បា. និង សំ.) សភាពមានដំណើរខុសធម៌, សភាពមានដំណើរខុសច្បាប់, ការប្រព្រឹត្តពុំត្រឹមត្រូវតាមគន្លងធម៌, ការប្រព្រឹត្តពុំត្រឹមត្រូវតាមគន្លងច្បាប់ :

❖ ចៅក្រមវិនិច្ឆ័យក្ដីដោយអយុត្តិធម៌។

📖 **យុវជន** **ពាក្យផ្ទុយ** **វយជន**

**យុវជន** *ន.* (បា.) ជនកំលោះ; ជនកំលោះក្រមុំ។

**វយជន** *ន.* (បា.) ជនចាស់។

📖 **យោគិន** **ពាក្យផ្ទុយ** **អយោគិន**

**យោគិន** *ន.* (សំ.) អ្នកមានព្យាយាមខាងការភាវនា, អ្នកមានព្យាយាមខាងការស្ងៀងស្ងាត់, អ្នកចម្រើនកម្មដ្ឋាន; បព្វជិត; តាបស, ឥសី។

**អយោគិន** *ន.* (សំ.) អ្នកដែលមិនមែនជាយោគិន។

📖 **យោគិនី** **ពាក្យផ្ទុយ** **អយោគិនី**

**យោគិនី** *ន.* (បា.) ស្ត្រីអ្នកមានព្យាយាមខាងការភាវនា, ស្ត្រីអ្នកមានព្យាយាមខាងការស្ងៀងស្ងាត់, ស្ត្រីអ្នកចម្រើនកម្មដ្ឋាន។

**អយោគិនី** *ន.* (បា.) ស្ត្រីអ្នកដែលមិនមែនជាយោគិនី។

📖 **យោគី** **ពាក្យផ្ទុយ** **អយោគី**

**យោគី** *ន.* (បា.) អ្នកមានព្យាយាមខាងការភាវនា, អ្នកមានព្យាយាមខាងការស្ងឹងស្មាធិ៍, អ្នកចម្រើនកម្មដ្ឋាន; បព្វជិត; តាបស, ឥសី។

**អយោគី** *ន.* (បា.) អ្នកដែលមិនមែនជាយោគី។

📖 **យោធ** **ពាក្យផ្ទុយ** **អយោធ**

**យោធ** *ន.* (បា.សំ.) អ្នកចម្បាំង, ទាហាន។

**អយោធ** *ន.* (បា.សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោធា** **ពាក្យផ្ទុយ** **អយោធា**

**យោធា** *ន.* ទាហានទាំងឡាយ, ពួកទាហាន។

**អយោធា** *ន.* (បា.សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោធិន** **ពាក្យផ្ទុយ** **អយោធិន**

**យោធិន** *ន.* (សំ.) អ្នកចម្បាំង, ទាហាន។

**អយោធិន** *ន.* (សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោនិសោមនសិការ** **ពាក្យផ្ទុយ** **អយោនិសោមនសិការ**

**យោនិសោមនសិការ** *ន.* (បា.) ការពិចារណាដោយឧបាយទៀងទាត់, ការពិចារណាដោយគំនិតទៀងទាត់; ដំណើរយកចិត្តទុកដាក់; សេចក្ដីគិត

ត្រូវទំនង។

**អយោនិសោមនសិការ** *ន.* (បា.) ការមិនពិចារណាដោយឧបាយ, ការមិនពិចារណាដោយគំនិតទៀងទាត់, ការមិនពិចារណាដោយគំនិតល្អិតល្អ; ដំណើរមិនយកចិត្តទុកដាក់, ការគិតខុសទំនង; ការឥតបើគិត។

📖 **រស់ ពាក្យផ្ទុយ ស្លាប់**

**រស់** *កិ.* មានជីវិតនៅ, មិនទាន់ស្លាប់។

**ស្លាប់** *កិ.* អស់ខ្យល់ដង្ហើម, អស់ជីវិត។

📖 **រាជទ្រព្យ ពាក្យផ្ទុយ រាជ្យទ្រព្យ**

**រាជទ្រព្យ** *ន.* (បា. និង សំ.ក្ល.) ទ្រព្យរបស់ព្រះរាជា មិនមែនសម្រាប់រាជ្យ។

**រាជ្យទ្រព្យ** *ន.* (សំ. និង សំ.ក្ល.) ទ្រព្យសម្រាប់រាជ្យ, របស់រាជការ។

📖 **រាត្រីសួស្តី! ពាក្យផ្ទុយ សាយណ្ហសួស្តី!, អរុណសួស្តី!**

**រាត្រីសួស្តី!** *ន.* សួស្តីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់ (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាយប់!។

**សាយណ្ហសួស្តី!** *ន.* សួស្តីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីថ្ងៃត្រង់របៀតដល់ថ្ងៃល្ងាច (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាល្ងាច!។

**អរុណសុទត្ថិ!** *ន.* សួស្ដីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាព្រឹក!។

📖 **រាត្រីសួស្ដី! ពាក្យផ្ទុយ សាយណ្ហសួស្ដី!, អរុណសួស្ដី!**

**រាត្រីសួស្ដី!** *ន.* សួស្ដីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាយប់!។

**សាយណ្ហសួស្ដី!** *ន.* សួស្ដីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីថ្ងៃត្រង់រហូតដល់ថ្ងៃល្ងាច (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាល្ងាច!។

**អរុណសួស្ដី!** *ន.* សួស្ដីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នាឬគំនាប់គ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាព្រឹក!។

📖 **រាស្ត្រ ពាក្យផ្ទុយ ស្ដេច**

**រាស្ត្រ** *ន.* (**សំ.**) ដែន, ប្រទេស; អ្នកនៅក្នុងដែន, ប្រជាជន។ ខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា "ប្រជាជនសម្រាប់ដែន (ក្រៅពីពួកក្សត្រនិងនាហ្មឺន)" :

- ពួករាស្ត្រ។

**ស្ដេច** *ន.* ក្សត្រ, អ្នកដែលកើតក្នុងវង្សក្សត្រ :

❖ ជាតិស្ដេច។

📖 **រូបនាម ពាក្យផ្ទុយ អរូបនាម**

**រូបនាម** *ន.* (បា.) រូបនិងនាម (ព.អ.)។ នាមនាមដែលមានរូបដូចយ៉ាង :

❖ ដី

❖ ទឹក

❖ សត្វ

❖ មនុស្ស។

**អរូបនាម** *ន.* (ព.វ.) នាមសព្ទដែលឥតរូប :

❖ ចិត្ត

❖ វិញ្ញាណ

❖ បំណង។

📖 **រូបព្រហ្ម ពាក្យផ្ទុយ អរូបព្រហ្ម**

**រូបព្រហ្ម** *ន.* (បា.) ព្រហ្មមានរូប, ព្រហ្មដែលកើតក្នុងរូបភព។

**អរូបព្រហ្ម** *ន.* (បា.) ព្រហ្មឥតរូប។

📖 **រូបភព ពាក្យផ្ទុយ អរូបភព**

**រូបភព** *ន.* (បា.ភ្ល.) កន្លែងកើតនៃព្រហ្ម។

**អរូបភព** *ន.* (បា.ភ្ល.) លោកជាទីនៅនៃអរូបព្រហ្ម។

📖 **រូបលោក** **ពាក្យផ្ទុយ** **អរូបលោក**

**រូបលោក** *ន.* (បា.) កន្លែងកើតនៃព្រហ្ម។

**អរូបលោក** *ន.* (បា.) លោកជាទីនៅនៃអរូបព្រហ្ម។

📖 **លក់ដុំ** **ពាក្យផ្ទុយ** **លក់រាយ**

**លក់ដុំ** *កិ.* លក់ទាំងដុំៗទីទៃពីលក់រាយ។

**លក់រាយ** *កិ.* លក់រាយៗតាមតែគេទិញអ្វីៗប៉ុន្មានៗក៏ដោយទីទៃពីលក់ដុំ។

📖 **លជ្ជាភាព** **ពាក្យផ្ទុយ** **អលជ្ជាភាព**

**លជ្ជាភាព** *ន.* (បា.ភ្ល.) ភាវៈនៃសេចក្ដីខ្មាស, ដំណើរអៀនខ្មាស :

❖ ចូលទៅរកគេដោយលជ្ជាភាព។

**អលជ្ជាភាព** *ន.* (បា.ភ្ល.) ភាវៈនៃសេចក្ដីឥតខ្មាស, ដំណើរឥតខ្មាស; ភាពជាអ្នកឥតខ្មាស :

❖ ប្រព្រឹត្តអនាចារដោយអលជ្ជាភាព។

📖 **លជ្ជិតា** **ពាក្យផ្ទុយ** **អលជ្ជិតា**

**លជ្ជិតា** *ន.* (បា.) ភាវៈនៃសេចក្ដីខ្មាស, ដំណើរអៀនខ្មាស :

❖ ចូលទៅរកគេដោយលជ្ជិតា។

**អលជ្ជិតា** *ន.* (បា.) ភាវៈនៃសេចក្ដីឥតខ្មាស, ដំណើរឥតខ្មាស; ភាពជាអ្នកឥតខ្មាស :

❖ ប្រព្រឹត្តអនាចារដោយអលជ្ជិតា។

📖 **លជ្ជិនី** **ពាក្យផ្ទុយ** **អលជ្ជិនី**

**លជ្ជិនី** *គុ.* ឬ *ន.* (បា.) ដែលមានសេចក្ដីខ្មាស; ស្ត្រីអ្នកមានខ្មាស :

❖ មនុស្សលជ្ជិនី។

**អលជ្ជិនី** *គុ.* ឬ *ន.* (បា.) ដែលឥតខ្មាស; ស្ត្រីអ្នកឥតខ្មាស :

❖ មនុស្សអលជ្ជិនី។

📖 **លជ្ជី** **ពាក្យផ្ទុយ** **អលជ្ជី**

**លជ្ជី** *គុ.* ឬ *ន.* (បា.) ដែលមានសេចក្ដីខ្មាស; អ្នកមានខ្មាស :

❖ មនុស្សលជ្ជី។

**អលជ្ជី** *គុ.* ឬ *ន.* (បា.) ដែលឥតខ្មាស; អ្នកឥតខ្មាស :

❖ មនុស្សអលជ្ជី។

📖 **លជ្ជីបព្វជិត** **ពាក្យផ្ទុយ** **អលជ្ជីបព្វជិត**

**លជ្ជីបព្វជិត** *ន.* (បា.) បព្វជិតមានខ្មាស។

**អលជ្ជីបព្វជិត** *ន.* (បា.) បព្វជិតឥតខ្មាស។

📖 **លជ្ជីបុគ្គល** **ពាក្យផ្ទុយ** **អលជ្ជីបុគ្គល**

**លជ្ជីបុគ្គល** *ន.* (បា.) បុគ្គលមានខ្មាស។

**អលជ្ជីបុគ្គល** *ន.* (បា.) បុគ្គលឥតខ្មាស។

📖 **លជ្ជីភាព** **ពាក្យផ្ទុយ** **អលជ្ជីភាព**

**លជ្ជីភាព** *ន.* (បា.ក្ល.) ភាពរបស់អ្នកមានសេចក្ដីខ្មាស, ដំណើររបស់អ្នកមានសេចក្ដីខ្មាស។

**អលជ្ជីភាព** *ន.* (បា.ក្ល.) ភាពរបស់អ្នកឥតខ្មាស, ដំណើររបស់អ្នកឥតខ្មាស។

📖 **លជ្ជីភិក្ខុ** **ពាក្យផ្ទុយ** **អលជ្ជីភិក្ខុ**

**លជ្ជីភិក្ខុ** *ន.* (បា.) ភិក្ខុមានខ្មាស។

**អលជ្ជីភិក្ខុ** *ន.* (បា.) ភិក្ខុឥតខ្មាស។

📖 **លជ្ជីសមណៈ** **ពាក្យផ្ទុយ** **អលជ្ជីសមណៈ**

**លជ្ជីសមណៈ** *ន.* (បា.ក្ល.) សមណៈមានខ្មាស។

**អលជ្ជីសមណៈ** *ន.* (បា.ក្ល.) សមណៈឥតខ្មាស។

📖 **លាភ** **ពាក្យផ្ទុយ** **អលាភ**

**លាភ** *ន.* (បា.សំ.) ការបាន, ដំណើរប្រទះលើការបាន, អ្វីៗដែលគួរបាន;

ចំណេញ :

❖ មានលាភ។

**អលាភ** *ន.* (បា.សំ.) ការឥតលាភ, ការខានបាន, ដំណើរប្រទះលើការខានបាន; ការខាតបង់ :

❖ ប្រទះលើអលាភ។

📖 **លិច** **ពាក្យផ្ទុយ** **អណ្តែត**

**លិច** *កិ.* លិបចុះបាត់ទៅ, ចូលកប់បាត់ទៅក្នុងទឹកជាដើម :

❖ ទូកលិច

❖ បន្ទាមុតលិច។

**អណ្តែត** *កិ.* ឋិតនៅលើទឹក; រសាត់ឬលឿនលើទឹកដោយកម្លាំងខ្សែទឹក; រសាត់ឬលឿននាអាកាសដោយកម្លាំងខ្យល់ :

❖ ផ្តិលអណ្តែតទឹកក្នុងពាង

❖ ប៉ុយគរសាត់អណ្តែតទៅតាមខ្យល់។

📖 **លោកិយ** **ពាក្យផ្ទុយ** **លោកុត្តរ**

**លោកិយ** *គុ.* (បា.) ដែលមានក្នុងលោក; ដែលជាប់ទាក់ទងដោយលោក; សម្រាប់លោក។

**លោកុត្តរ** *ន.* (បា.) ធម៌ចម្លងសត្វឱ្យចេញផុតចាកលោក គឺមគ្គ៤, ផល៤, និព្វាន១; ហៅថា នព្វលោកុត្តរធម៌ ក៏បាន (ព.ពុ.)។

📖 **លោភោ** **ពាក្យផ្ទុយ** **អលោភោ**

**លោភោ** *គុ.* (បា.) ដែលចង់បានហួសពេក :

❖ ចិត្តលោភោ

❖ មនុស្សលោភោ។

**អលោភោ** *គុ.* (បា.) ដែលឥតលោភ, ដែលមិនសូវមានលោភ :

❖ ចិត្តអលោភោ

❖ មនុស្សអលោភោ។

📖 **វឌ្ឍនៈ** **ពាក្យផ្ទុយ** **ហាយនៈ**

**វឌ្ឍនៈ** *ន.* (បា.សំ.) សេចក្តីចម្រើន; ការលូតលាស់; ដំណើរដុះដាល; ដំណើរកើតកាលវាលគុម្ព។

**ហាយនៈ** *ន.* (បា.សំ.) សេចក្តីវិនាស, សេចក្តីសាបសូន្យ; ដំណើរទ្រុឌទ្រោម។

📖 **វឌ្ឍនភាគិនី** **ពាក្យផ្ទុយ** **ហានភាគិនី**

**វឌ្ឍនភាគិនី** *គុ.* ឬ *ន.* (បា.) ដែលមានចំណែកខាងចម្រើន; ស្រ្តីអ្នកដែលមានចំណែកទៅខាងតែចម្រើន, ស្រ្តីអ្នកដែលចេះតែចម្រើន :

❖ មនុស្សប្រព្រឹត្តអំពើត្រង់ជាវឌ្ឍនភាគិនី។

**ហានភាគិនី** *គុ.* ឬ *ន.* (បា.) ដែលមានចំណែកខាងវិនាស; ស្ត្រីអ្នកដែលមានចំណែកទៅខាងតែវិនាស, ស្ត្រីអ្នកដែលចេះតែវិនាស :

❖ មនុស្សប្រព្រឹត្តអំពើវៀចជាហានភាគិនី។

📖 **វឌ្ឍនភាគី ពាក្យផ្ទុយ ហានភាគី**

**វឌ្ឍនភាគី** *គុ.* ឬ *ន.* (បា.) ដែលមានចំណែកខាងចម្រើន; អ្នកដែលមានចំណែកទៅខាងតែចម្រើន, អ្នកដែលចេះតែចម្រើន :

❖ មនុស្សប្រព្រឹត្តអំពើត្រង់ជាវឌ្ឍនភាគី។

**ហានភាគី** *គុ.* ឬ *ន.* (បា.) ដែលមានចំណែកខាងវិនាស; អ្នកដែលមានចំណែកទៅខាងតែវិនាស, អ្នកដែលចេះតែវិនាស :

❖ មនុស្សប្រព្រឹត្តអំពើវៀចជាហានភាគី។

📖 **វន្ទិយបុគ្គល ពាក្យផ្ទុយ អវន្ទិយបុគ្គល**

**វន្ទិយបុគ្គល** *ន.* (បា.) បុគ្គលដែលគួរគេសំពះ :

❖ មាតាបិតាជាវន្ទីយបុគ្គលរបស់បុត្រធីតា។

**អវន្ទិយបុគ្គល** *ន.* (បា.) បុគ្គលដែលមិនគួរសំពះ :

❖ អវន្ទីយបុគ្គល១០ចំពួកឬ២៥ចំពួកភិក្ខុពុំត្រូវសំពះឡើយ (ព.វិ.ពុ.)។

📖 **ទិវាសសមោធានិទាន ពាក្យផ្ទុយ សាយណ្ហាភិវាទន**

**ទិវាសសមោធានិទាន** *ន.* (បា.) ការពោលពាក្យគំនាប់គ្នាទៅវិញទៅមកក្នុងវេលាព្រឹក, ដូចជា :

❖ សុភស្តេប្រភាត! "វេលាព្រឹកដ៏ល្អចូរមានដល់អ្នក!"។

**សាយណ្ហាភិវាទន** *ន.* (បា.) ការពោលពាក្យគំនាប់គ្នាក្នុងវេលាសាយណ្ហថា :

❖ សាយណ្ហសុវត្ថិ! ឬសាយណ្ហសួស្តី!។

📖 **វិជ្ជមាន ពាក្យផ្ទុយ អវិជ្ជមាន**

**វិជ្ជមាន** *គុ.* (បា.) ដែលកំពុងមាននៅឡើយ, ធរមាន។

**អវិជ្ជមាន** *គុ.* (បា.) ដែលកំពុងតែមិនមាន, ដែលឥតមានសោះឡើយ។

📖 **វិជ្ជា ពាក្យផ្ទុយ អវិជ្ជា**

**វិជ្ជា** *ន.* (បា.) សេចក្ដីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម :

❖ វិជ្ជាលេខ

❖ វិជ្ជាពេទ្យ។

**អវិជ្ជា** *ន.* (បា.) ការមិនដឹងច្បាស់, សេចក្ដីល្ងង់, មោហៈ, មោហោ :

❖ សត្វលោកត្រូវអវិជ្ជារួបរឹតងងឹតភន្តច្រលំយល់ខុសថាជាត្រូវ។

📖 **វិញ្ញាណកក្ខន្ធ ពាក្យផ្ទុយ អវិញ្ញាណកក្ខន្ធ**

**វិញ្ញាណកទ្រព្យ** *ន.* (បា. និង សំ.ក្ល.) ទ្រព្យមានវិញ្ញាណ :

❖ គោ

❖ ក្របី។

**អវិញ្ញាណកទ្រព្យ** *ន.* (បា. និង សំ.ក្ល.) ទ្រព្យឥតវិញ្ញាណ :

❖ មាស

❖ ប្រាក់។

🕮 **វិញ្ញូ** **ពាក្យផ្ទុយ** **អវិញ្ញូ**

**វិញ្ញូ** *ន.* (បា.) អ្នកដឹងច្បាស់, អ្នកដឹងហេតុផ្សេងៗ (អ្នកប្រាជ្ញ)។

**អវិញ្ញូ** *គុ.* (បា.) ដែលមិនមានការដឹង; ល្ងង់, ខ្លៅ។

🕮 **វិញ្ញូជន** **ពាក្យផ្ទុយ** **អវិញ្ញូជន**

**វិញ្ញូជន** *ន.* (បា.) អ្នកប្រាជ្ញ។

**អវិញ្ញូជន** *ន.* (បា.) ជនល្ងង់, ជនខ្លៅ។

🕮 **វិញ្ញូបុរស** **ពាក្យផ្ទុយ** **អវិញ្ញូបុរស**

**វិញ្ញូបុរស** *ន.* (បា.) អ្នកប្រាជ្ញ។

**អវិញ្ញូបុរស** *ន.* (បា.) បុរសល្ងង់, បុរសខ្លៅ។

🕮 **វិញ្ញូភាព** **ពាក្យផ្ទុយ** **អវិញ្ញូភាព**

**វិញ្ញូភាព** *ន.* (បា.ភ្ន.) ភាពនៃវិញ្ញូ; ភាវៈនៃកូនក្មេងដឹងក្តី។

**អវិញ្ញូភាព** *ន.* (បា.ភ្ន.) ភាពនៃអវិញ្ញូ; ភាវៈនៃកូនក្មេងតូចពុំទាន់ដឹងក្តី។

📖 **វិជ្ជា** **ពាក្យផ្ទុយ** **អវិជ្ជា**

**វិជ្ជា** *ន.* (សំ.) សេចក្តីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម :

❖ វិទ្យាលេខ

❖ វិទ្យាពេទ្យ។

**អវិជ្ជា** *ន.* (សំ.) ការមិនដឹងច្បាស់, សេចក្តីល្ងង់, មោហៈឬមោហោ :

❖ សត្វលោកត្រូវអវិទ្យារួបរឹតងងឹតភន្តច្រលំយល់ខុសថាជាត្រូវ។

📖 **វិនយកថា** **ពាក្យផ្ទុយ** **អវិនយកថា**

**វិនយកថា** *ន.* (បា.) សម្តីប្រារព្ធវិន័យ, សម្តីអាងវិន័យ។

**អវិនយកថា** *ន.* (បា.) សម្តីខុសច្បាប់, សម្តីក្រៅច្បាប់។

📖 **វិនយវាចា** **ពាក្យផ្ទុយ** **អវិនយវាចា**

**វិនយវាចា** *ន.* (បា.) សម្តីត្រូវច្បាប់, សម្តីក្នុងច្បាប់។

**អវិនយវាចា** *ន.* (បា.)  សម្តីខុសច្បាប់, សម្តីក្រៅច្បាប់។

📖 **វិនយវាទ** **ពាក្យផ្ទុយ** **អវិនយវាទ**

**វិនយវាទ** *ន.* (បា.) ពាក្យពោលអាងវិន័យ។

**អវិនយវាទ** *ន.* (បា.) សម្ដីខុសច្បាប់, សម្ដីក្រៅច្បាប់។

📖 **វិនយវាទិន** **ពាក្យផ្ទុយ** **អវិនយវាទិន**

**វិនយវាទិន** *ន.* (សំ.) អ្នកពោលអាងវិន័យ, អ្នកនិយាយប្រកាន់តាមវិន័យ។

**អវិនយវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែនិយាយខុសច្បាប់, អ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 **វិនយវាទិនី** **ពាក្យផ្ទុយ** **អវិនយវាទិនី**

**វិនយវាទិនី** *ន.* (បា.) ស្ត្រីអ្នកពោលអាងវិន័យ, ស្ត្រីអ្នកនិយាយប្រកាន់តាមវិន័យ។

**អវិនយវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែនិយាយខុសច្បាប់, ស្ត្រីអ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 **វិនយវាទី** **ពាក្យផ្ទុយ** **អវិនយវាទី**

**វិនយវាទី** *ន.* (បា.) អ្នកពោលអាងវិន័យ, អ្នកនិយាយប្រកាន់តាមវិន័យ។

**អវិនយវាទី** *ន.* (បា.) អ្នកដែលច្រើនតែនិយាយខុសច្បាប់, អ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 **វិរុទ្ធ** **ពាក្យផ្ទុយ** **អវិរុទ្ធ**

**វិរុទ្ធ** *គុ.* (បា.សំ.) ដែលខុស; ដែលទីទៃពីគ្នា, ដែលផ្ទុយគ្នា។

**អវិរុទ្ធ** *គុ.* (បា.សំ.) ដែលមិនខុស, ដែលឥតខុស; ដែលឥតទាស់, ដែលឥតឆ្គង គឺត្រឹមត្រូវ; ស្រួល; ស្របគ្នា, ត្រូវគ្នា (ប្រើជា អពិរុទ្ធ ក៏បាន)។

📖 **វិរុទ្ធកថា** **ពាក្យផ្ទុយ** **អវិរុទ្ធកថា**

**វិរុទ្ធកថា** *ន.* (បា.សំ.) សម្ដីមិនត្រឹមត្រូវ។

**អវិរុទ្ធកថា** *ន.* (បា.សំ.) សម្ដីត្រឹមត្រូវ។

📖 **វិរុទ្ធបាលី** **ពាក្យផ្ទុយ** **អវិរុទ្ធបាលី**

**វិរុទ្ធបាលី** *ន.* (បា.សំ.) បាលីខុស។

**អវិរុទ្ធបាលី** *ន.* (បា.សំ.) បាលីត្រឹមត្រូវ។

📖 **វិរុទ្ធភាព** **ពាក្យផ្ទុយ** **អវិរុទ្ធភាព**

**វិរុទ្ធភាព** *ន.* (បា.សំ.ភ្ល.) ភាពមិនត្រឹមត្រូវ; ភាពឆ្គង។

**អវិរុទ្ធភាព** *ន.* (បា.សំ.ភ្ល.) ភាពត្រឹមត្រូវ; ភាពឥតឆ្គង។

📖 **វិរុទ្ធវាចា** **ពាក្យផ្ទុយ** **អវិរុទ្ធវាចា**

**វិរុទ្ធវាចា** *ន.* (បា.សំ.) សម្ដីខុស។

**អវិរុទ្ធវាចា** *ន.* (បា.សំ.) សម្ដីត្រឹមត្រូវ។

📖 **វិរុទ្ធវាទ** **ពាក្យផ្ទុយ** **អវិរុទ្ធវាទ**

**វិរុទ្ធវាទ** *ន.* (បា.សំ.) សម្ដីខុស, ពំនោលខុស។

**អវិរុទ្ធវាទ** *ន.* (បា.សំ.) សម្ដីត្រឹមត្រូវ, ពំនោលត្រឹមត្រូវ។

📖 **វិរុទ្ធសព្ទ** **ពាក្យផ្ទុយ** **អវិរុទ្ធសព្ទ**

**វិរុទ្ធសព្ទ** *ន.* (សំ.) សព្ទខុស; សព្ទផ្ទុយគ្នា។

**អវិរុទ្ធសព្ទ** *ន.* (សំ.) សព្ទត្រឹមត្រូវ; សព្ទស្របគ្នា។

📖 **វិរូប** **ពាក្យផ្ទុយ** **សុរូប**

**វិរូប** *គុ.* ឬ *ន.* (បា.សំ.) រូបអាក្រក់; ដែលមានរូបអាក្រក់ប្លែក; ដែលអាក្រក់, គួរខ្ពើម; ពិការ។

**សុរូប** *គុ.* ឬ *ន.* (បា.សំ.) រូបល្អ; ដែលមានរូបល្អ។

📖 **វិរូបា** **ពាក្យផ្ទុយ** **សុរូបា**

**វិរូបា** *គុ.* ឬ *ន.* (បា.សំ.) ស្ត្រីរូបអាក្រក់; ស្ត្រីដែលមានរូបអាក្រក់ប្លែក; ស្ត្រីដែលអាក្រក់, ស្ត្រីគួរខ្ពើម; ស្ត្រីពិការ។

**សុរូបា** *គុ.* ឬ *ន.* (បា.សំ.) ស្ត្រីរូបល្អ; ស្ត្រីដែលមានរូបល្អ។

📖 **វិរោធ** **ពាក្យផ្ទុយ** **អវិរោធ**

**វិរោធ** *ន.* (បា.សំ.) កំហឹង; កំហុស; សេចក្ដីស្អប់; ជម្លោះ; សត្រូវ។

**អវិរោធ** *ន.* (បា.សំ.) សេចក្ដីមិនវិរោធ; ដំណើរឥតកំហុស, ដំណើរឥតសេចក្ដីស្អប់; អ្នកដែលឥតវិរោធ, អ្នកដែលឥតកំហុស។

📖 **វិសទិស ពាក្យផ្ទុយ សទិស**

**វិសទិស** *គុ.* (សំ.) ដែលទីទៃពីគ្នា, មិនដូចគ្នា, ខុសគ្នា, ផ្សេងពីគ្នា; ដែលជាទំនាស់នឹងគ្នា, ផ្ទុយគ្នា។

**សទិស** *គុ.* (បា.) ដែលដូចគ្នា, ត្រូវគ្នា, ប្រហែលគ្នា, ស្រដៀងគ្នា, ឈាំគ្នា។

📖 **វិសទិសន័យ ពាក្យផ្ទុយ សទិសន័យ**

**វិសទិសន័យ** *ន.* (បា.ក្ល.) ន័យផ្សេងគ្នា។

**សទិសន័យ** *ន.* (បា.ក្ល.) ន័យដូចគ្នា, ន័យស្រដៀងគ្នា។

📖 **វិសទិសពណ៌ ពាក្យផ្ទុយ សទិសពណ៌**

**វិសទិសពណ៌** *ន.* (បា. និង សំ.ក្ល.) ពណ៌ផ្សេងគ្នា, សម្បុរផ្សេងគ្នា។

**សទិសពណ៌** *ន.* (បា. និង សំ.ក្ល.) ពណ៌ដូចគ្នា, សម្បុរដូចគ្នា។

📖 **វិសទិសភាព ពាក្យផ្ទុយ សទិសភាព**

**វិសទិសភាព** *ន.* (បា.ក្ល.) ភាពខុសគ្នា, បែបផ្សេងគ្នា។

**សទិសភាព** *ន.* (បា.ក្ល.) ភាពត្រូវគ្នា, បែបស្រដៀងគ្នា។

📖 **វិសទិសសព្ទ ពាក្យផ្ទុយ សទិសសព្ទ**

**វិសទិសសព្ទ** *ន.* (សំ.) សព្ទដែលមានសេចក្ដីផ្សេងគ្នា, ពាក្យផ្ទុយ :

❖ ពាក្យខុសជាវិសទិសសព្ទរបស់ពាក្យត្រូវ។

**សទិសសព្ទ** *ន.* (សំ.) សព្ទដែលមានសេចក្ដីលាំគ្នា, សព្ទដែលមានសេចក្ដីស្រដៀងគ្នា :

❖ ថ្លៃថ្លា

❖ ឧត្ដម

❖ ខ្ពង់ខ្ពស់។

📖 **វិសភាគ** **ពាក្យផ្ទុយ** **សភាគ**

**វិសភាគ** *គុ.* ឬ *ន.* (បា.) ដែលមានចំណែកមិនស្មើគ្នា គឺដែលខុសគ្នា, ដែលជាទំនាស់នឹងគ្នា, ដែលផ្ទុយគ្នា; ដែលជាសត្រូវ។

**សភាគ** *គុ.* (បា.) ដែលមានចំណែកស្មើគ្នា គឺដែលត្រូវគ្នា, ដែលដូចគ្នា; ដែលត្រូវចិត្តត្រូវគំនិតគ្នា, ដែលជិតដិតស្និទ្ធស្នាលនឹងគ្នា។

📖 **វិសម** **ពាក្យផ្ទុយ** **សម**

**វិសម** *គុ.* (បា.សំ.) ដែលមិនស្មើ, ដែលមិនរាប, ដែលមិនរាបទាប, ដែលខ្ពស់ៗទាបៗ។

**សម** *គុ.* (បា.សំ.) ដែលស្មើគ្នា, ដែលប៉ុនគ្នា, ដែលប្រហែលគ្នា; ដែលស្រដៀងគ្នា។

📖 **វិសមចិត្ត** **ពាក្យផ្ទុយ** **សមចិត្ត**

**វិសមចិត្ត** *ន.* (បា.) ចិត្តមិនស្មើ; ចិត្តមិនដូចគ្នា។

**សមចិត្ត** *ន.* (បា.) ចិត្តស្មើ; ចិត្តដូចគ្នា។

📖 **វិសមានចិត្ត ពាក្យផ្ទុយ សមានចិត្ត**

**វិសមានចិត្ត** *ន.* (បា.) ចិត្តមិនស្មោះស្មើ, ចិត្តប្រកបដោយសេចក្ដីវង្វេស, ចិត្តអធ្យាស្រ័យមិនត្រូវគ្នា; សេចក្ដីគ្នាន់ក្នាញ់, ការមួម៉ៅក្ដៅក្រហាយ។

**សមានចិត្ត** *ន.* (បា.) ចិត្តស្មោះស្មើ, ចិត្តដែលមានសភាពទោរទន់រកគ្នាដោយសេចក្ដីស្រលាញ់។

📖 **វិសាទិស ពាក្យផ្ទុយ សាទិស**

**វិសាទិស** *គុ.* (សំ.) ដែលទីទៃពីគ្នា, ដែលមិនដូចគ្នា, ដែលខុសគ្នា, ដែលផ្សេងពីគ្នា; ដែលជាទំនាស់នឹងគ្នា, ដែលផ្ទុយគ្នា។

**សាទិស** *គុ.* (សំ.) ដែលដូចគ្នា, ដែលត្រូវគ្នា, ដែលប្រហែលគ្នា, ដែលស្រដៀងគ្នា, ដែលលំគ្នា។

📖 **វិសាមញ្ញនាម ពាក្យផ្ទុយ សាមញ្ញនាម**

**វិសាមញ្ញនាម** *ន.* (បា.) នាមនាមដែលមិនទូទៅ។

**សាមញ្ញនាម** *ន.* (បា.) នាមនាមដែលនៅទូទៅទៀតបាន។

📖 **វិសារទ ពាក្យផ្ទុយ អវិសារទ**

**វិសារទ** *គុ.* (បា.សំ.) ដែលក្លៀវក្លា, ដែលអង់អាច, ដែលឈ្លាសវៃក្នុងការនិយាយស្តី, ដែលឈ្លាសវៃក្នុងការជជែក (ផ្ទុយពីពាក្យ ប្រជុំ) :

❖ មនុស្សវិសារទ។

**អវិសារទ** *គុ.* (បា.សំ.) ដែលមិនក្លៀវក្លា, ដែលមិនអង់អាច, ដែលមិនឈ្លាសវៃក្នុងការនិយាយស្តី, ដែលមិនឈ្លាសវៃក្នុងការជជែក (ផ្ទុយនឹងប្រជុំ) :

❖ មនុស្សអវិសារទ។

📖 **វិសារទភាព ពាក្យផ្ទុយ អវិសារទភាព**

**វិសារទភាព** *ន.* (បា.ភ្ល.) ភាពអង់អាច, សេចក្តីអង់អាច :

❖ មានវិសារទភាព

❖ វិសារទភាពរបស់អ្នករៀន។

**អវិសារទភាព** *ន.* (បា.ភ្ល.) ភាពជាអ្នកមិនក្លៀវក្លា, ភាពមិនអង់អាច។

📖 **វិស្សាសិក ពាក្យផ្ទុយ អវិស្សាសិក**

**វិស្សាសិក** *គុ.* (បា.) ដែលមានវិស្សាសៈ; ដែលប្រកបដោយសេចក្តីស្និទ្ធស្នាល :

❖ មនុស្សវិស្សាសិក។

**អវិស្សាសិក** *គុ.* (បា.) ដែលមិនមានវិស្សាសៈ, ដែលមិនប្រកបដោយ

សេចក្តីស្និទ្ធស្នាល ៖

❖ មនុស្សអវិស្សាសិក។

📖 **វិស្សាសិកដ្ឋាន ពាក្យផ្ទុយ អវិស្សាសិកដ្ឋាន**

**វិស្សាសិកដ្ឋាន** *ន.* (បា.) ទីដែលប្រកបដោយវិស្សាសៈ។

**អវិស្សាសិកដ្ឋាន** *ន.* (បា.) ទីដែលមិនមានវិស្សាសៈ។

📖 **វិស្សាសិកា ពាក្យផ្ទុយ អវិស្សាសិកា**

**វិស្សាសិកា** *គុ.* ឬ *ន.* (បា.) ដែលមានវិស្សាសៈ; ស្ត្រីដែលប្រកបដោយសេចក្តីស្និទ្ធស្នាល ៖

❖ មនុស្សវិស្សាសិកា។

**អវិស្សាសិកា** *គុ.* ឬ *ន.* (បា.) ដែលមិនមានវិស្សាសៈ; ស្ត្រីដែលមិនប្រកបដោយសេចក្តីស្និទ្ធស្នាល ៖

❖ មនុស្សអវិស្សាសិកា។

📖 **វិហិង្សា ពាក្យផ្ទុយ អវិហិង្សា**

**វិហិង្សា** *ន.* (បា.សំ.) សេចក្តីបៀតបៀន, ការធ្វើឱ្យគេបានសេចក្តីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

**អវិហិង្សា** *ន.* (បា.សំ.) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្តី

ទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 **ខហឹសា ពាក្យផ្ទុយ អខហឹសា**

**ខហឹសា** *ន.* (បា.) សេចក្ដីបៀតបៀន, ការធ្វើឱ្យគេបានសេចក្ដីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

**អខហឹសា** *ន.* (បា.) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្ដីទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 **ខហេសា ពាក្យផ្ទុយ អខហេសា**

**ខហេសា** *ន.* (បា.) សេចក្ដីបៀតបៀន, ការធ្វើឱ្យគេបានសេចក្ដីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

**អខហេសា** *ន.* (បា.) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្ដីទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 **វីតក្កម ពាក្យផ្ទុយ អវីតក្កម**

**វីតក្កម** *ន.* (បា.) អជ្ឈាចារ, ការកន្លងបញ្ញត្តិ, ការល្មើសបញ្ញត្តិ, ការបំពានច្បាប់។

**អវីតក្កម** *ន.* (បា.) ការមិនកន្លងបញ្ញត្តិ, ការមិនល្មើសបញ្ញត្តិ, ការមិនបំពានច្បាប់។

📖 **វីតក្កមចេតនា ពាក្យផ្ទុយ អវីតក្កមចេតនា**

**វីតក្កមចេតនា** *ន.* (បា.) គំនិតដែលបម្រុងនឹងកន្លង, គំនិតដែលបម្រុងនឹងបំពានលើបញ្ញត្តិ។

**អវីតក្កមចេតនា** *ន.* (បា.) ចេតនាដែលប្រុងប្រយត្នមិនបម្រុងនឹងកន្លង, ចេតនាដែលប្រុងប្រយត្នមិនបម្រុងនឹងបំពានលើបញ្ញត្តិ។

📖 **វីតិក្រម ពាក្យផ្ទុយ អវីតិក្រម**

**វីតិក្រម** *ន.* (សំ.) អជ្ឈាចារ, ការកន្លងបញ្ញត្តិ, ការល្មើសបញ្ញត្តិ, ការបំពានច្បាប់។

**អវីតិក្រម** *ន.* (សំ.) ការមិនកន្លងបញ្ញត្តិ, ការមិនល្មើសបញ្ញត្តិ, ការមិនបំពានច្បាប់។

📖 **សកម្មកិរិយា ពាក្យផ្ទុយ អកម្មកិរិយា**

**សកម្មកិរិយា** *ន.* (បា.) កិរិយាសព្ទដែលកាលណានិយាយត្រូវស្រែកហៅអំពើដែលត្រូវធ្វើមកផង, ដូចជា ធ្វើ, ស៊ី, ឧទ្ទូល, វាយ, មិន ជាដើម។

**អកម្មកិរិយា** *ន.* (បា.) កិរិយាសព្ទដែលកាលណានិយាយមិនបាច់ដាក់អំពើដែលត្រូវធ្វើមកផងទេ, ដូចជា ដេក, ដួល, ឈរ, អង្គុយ ជាដើម។

📖 **សកម្មធាតុ ពាក្យផ្ទុយ អកម្មធាតុ**

**សកម្មធាតុ** *ន.* (បា.) ឫសដើមរបស់កិរិយាសព្ទប្រកបដោយកម្ម, កាលណានិយាយត្រូវដាក់ពាក្យជាអំពើដែលត្រូវធ្វើមកផង។

**អកម្មធាតុ** *ន.* (បា.) ឫសដើមនៃកិរិយាសព្ទដែលមិនមានកម្ម។

📖 **សង្ខតធម៌ ពាក្យផ្ទុយ អសង្ខតធម៌**

**សង្ខតធម៌** *ន.* (បា. និង សំ.) ធម៌ដែលបច្ច័យប្រជុំតាក់តែង, សង្ខារធម៌ :

❖ សកលលោកជាសង្ខតធម៌។

**អសង្ខតធម៌** *ន.* (បា. និង សំ.) ធម៌ដែលបច្ច័យប្រជុំតាក់តែងពុំបាន :

❖ ព្រះនិព្វានជាអសង្ខតធម៌។

📖 **សង្ហារិម ពាក្យផ្ទុយ អសង្ហារិម**

**សង្ហារិម** *គុ.* (បា.ភ្ល.) ដែលនាំយកទៅមកបាន, ដែលលើកយកទៅមកបាន, ដែលអាចធ្វើឱ្យកក្រើក, ដែលអាចធ្វើឱ្យឃ្លាតចាកទីបាន :

❖ ចាន

❖ កៅអី។

**អសង្ហារិម** *គុ.* (បា.ភ្ល.) ដែលនាំយកទៅមកពុំបាន, ដែលលើកយកទៅមកពុំបាន, ដែលពុំអាចធ្វើឱ្យកក្រើក, ដែលពុំអាចធ្វើឱ្យឃ្លាតចាកទីបាន :

❖ ស្រែ

❖ ចម្ការ។

📖 **សតេកិច្ឆៈ ពាក្យផ្ទុយ អតេកិច្ឆៈ**

**សតេកិច្ឆៈ** *គុ.* (បា.ភ្ល.) ដែលគួររក្សាបាននៅឡើយ, ដែលនៅកែបាន :

❖ ទោសទ្ទុះជាសតេកិច្ឆៈ។

**អតេកិច្ឆៈ** *គុ.* (បា.ភ្ល.) ដែលមិនគួររក្សាបាន, ដែលអស់កែបាន, ដែលកែខៃលែងកើត :

❖ ទោសទ្ទុះជាអតេកិច្ឆៈ។

📖 **សតេកិច្ឆា ពាក្យផ្ទុយ អតេកិច្ឆា**

**សតេកិច្ឆា** *គុ.* (បា.) ដែលគួររក្សាបាននៅឡើយ, ដែលនៅកែបាន :

❖ ទោសទ្ទុះជាសតេកិច្ឆា។

**អតេកិច្ឆា** *គុ.* (បា.) ដែលមិនគួររក្សាបាន, ដែលអស់កែបាន, ដែលកែខៃលែងកើត :

❖ ទោសទ្ទុះជាអតេកិច្ឆា។

📖 **សត្យ ពាក្យផ្ទុយ អសត្យ**

**សត្យ** *គុ.* (សំ.) ដែលទៀង, ទៀងត្រង់, ពិត, ប្រាកដ, មែន :

❖ ពាក្យសត្យ។

**អសត្យ** *គុ.* (សំ.) ដែលមិនទៀង, ដែលមិនពិត :

❖ សម្តីអសត្យ។

📖 **សន្តិសុខ ពាក្យផ្ទុយ អសន្តិសុខ**

**សន្តិសុខ** *ន.* (បា.) សុខដែលកើតអំពីសេចក្តីស្ងប់។

**អសន្តិសុខ** *ន.* (បា.) ការមិនមានសេចក្តីសុខសាន្ត, ដំណើរដែលឥតមានសេចក្តីស្ងប់រៀបរយក្នុងស្រុក, ចលាចល, ការរបះរបោរ។

📖 **សន្ទិដ្ឋមិត្ត ពាក្យផ្ទុយ សម្ភត្តមិត្ត, អទិដ្ឋមិត្ត**

**សន្ទិដ្ឋមិត្ត** *ន.* (បា.) មិត្តដែលគ្រាន់តែបានជួបឃើញគ្នាមួយដងមួយកាលមិនសូវស្និទ្ធស្នាលប៉ុន្មាន, មនុស្សស្គាល់គ្នា :

❖ លុះខ្ញុំទៅដល់ទីនុះ មានពួកសន្ទិដ្ឋមិត្តនិងសម្ភត្តមិត្តមកទទួលឈូឆរអបអរសាទរ។

**សម្ភត្តមិត្ត** *ន.* (បា.) មិត្តជិតដិតទុកចិត្តស្និទ្ធស្នាលយ៉ាងមាំ (ទល្ហមិត្ត) :

❖ អ្នកនុះជាសម្ភត្តមិត្តរបស់ខ្ញុំ។

**អទិដ្ឋមិត្ត** *ន.* (បា.) មិត្តមិនដែលឃើញគ្នា គឺអ្នកដែលរាប់អានគ្នាជាមិត្តប៉ុន្តែមិនដែលបានជួប មិនដែលបានឃើញគ្នាសោះគ្រាន់តែបានផ្ញើសំបុត្រឬផ្តាំដំណឹងទៅវិញទៅមករកគ្នា ឬក៏ផ្ញើទ្រព្យរបស់ភស្តុភារអ្វីៗទៅវិញទៅមក

ដោយអ្នកដទៃ។

📖 **សប្បុរស ពាក្យផ្ទុយ អសប្បុរស**

**សប្បុរស** *ន.* (បា.ភ្ល.) បុរសអ្នកស្ងប់ គឺមនុស្ស (ប្រុសក្តីស្រីក្តី) អ្នកមិនធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត, អ្នកប្រព្រឹត្តល្អ, អ្នកត្រឹមត្រូវ។

**អសប្បុរស** *ន.* (បា.ភ្ល.) បុរសអ្នកមិនស្ងប់ គឺបុរសស្ត្រីអ្នកកាន់អំពើអាក្រក់ដោយកាយវាចាចិត្ត; អ្នកមានចិត្តអាក្រក់។

📖 **សប្បុរិស ពាក្យផ្ទុយ អសប្បុរិស**

**សប្បុរិស** *ន.* (បា.) បុរសអ្នកស្ងប់។

**អសប្បុរិស** *ន.* (បា.) បុរសអ្នកមិនស្ងប់។

📖 **សប្បុរិសកម្ម ពាក្យផ្ទុយ អសប្បុរិសកម្ម**

**សប្បុរិសកម្ម** *ន.* (បា.) អំពើរបស់សប្បុរស, កិច្ចការរបស់សប្បុរស។

**អសប្បុរិសកម្ម** *ន.* (បា.) អំពើរបស់អសប្បុរស, កិច្ចការរបស់អសប្បុរស។

📖 **សប្បុរិសចរិយា ពាក្យផ្ទុយ អសប្បុរិសចរិយា**

**សប្បុរិសចរិយា** *ន.* (បា.) ការប្រព្រឹត្តរបស់សប្បុរស។

**អសប្បុរិសចរិយា** *ន.* (បា.) ចរិយារបស់អសប្បុរស។

📖 **សប្បុរិសដ្ឋាន ពាក្យផ្ទុយ អសប្បុរិសដ្ឋាន**

**សប្បុរិសជាតិ** *ន.* (បា.) ជាតិរបស់សប្បុរស។

**អសប្បុរិសជាតិ** *ន.* (បា.) ជាតិនៃអសប្បុរស។

📖 **សប្បុរិសទាន ពាក្យផ្ទុយ អសប្បុរិសទាន**

**សប្បុរិសទាន** *ន.* (បា.) ទានរបស់សប្បុរស គឺទានដែលគេឱ្យដោយគោរព។

**អសប្បុរិសទាន** *ន.* (បា.) ទានរបស់អសប្បុរស គឺទានដែលគេឱ្យដោយខ្ជីខ្ជា។

📖 **សប្បុរិសធម៌ ពាក្យផ្ទុយ អសប្បុរិសធម៌**

**សប្បុរិសធម៌** *ន.* (បា. និង សំ.) ធម៌របស់សប្បុរស។

**អសប្បុរិសធម៌** *ន.* (បា. និង សំ.) ធម៌របស់អសប្បុរស។

📖 **សព្ភិ ពាក្យផ្ទុយ អសព្ភិ**

**សព្ភិ** *អា.និ.* (បា.) ដោយសប្បុរសទាំងឡាយ, ជាមួយនឹងពួកសប្បុរស។

**អសព្ភិ** *អា.និ.* (បា.) ដោយអសប្បុរសទាំងឡាយ, ជាមួយនឹងពួកអសប្បុរស។

📖 **សព្ភិកម្ម ពាក្យផ្ទុយ អសព្ភិកម្ម**

**សព្ភិកម្ម** *ន.* (បា.) អំពើរបស់ពួកសប្បុរស។

**អសព្ភិកម្ម** *ន.* (បា.) អំពើរបស់ពួកអសប្បុរស។

📖 **សព្ភិធម៌ ពាក្យផ្ទុយ អសព្ភិធម៌**

**សព្ភិធម៌** *ន.* (បា. និង សំ.) ធម៌របស់ពួកអ្នកស្ងប់។

**អសប្បុរិសធម៌** *ន.* (បា. និង សំ.) ធម៌របស់ពួកអសប្បុរស។

📖 **សប្បុរិសវាចា ពាក្យផ្ទុយ អសប្បុរិសវាចា**

**សប្បុរិសវាចា** *ន.* (បា.) សម្ដីរបស់ពួកសប្បុរស។

**អសប្បុរិសវាចា** *ន.* (បា.) សម្ដីរបស់ពួកអសប្បុរស។

📖 **សប្បុរិសវាទ ពាក្យផ្ទុយ អសប្បុរិសវាទ**

**សប្បុរិសវាទ** *ន.* (បា.) សម្ដីរបស់ពួកសប្បុរស។

**អសប្បុរិសវាទ** *ន.* (បា.) សម្ដីរបស់ពួកអសប្បុរស។

📖 **សម្ភិន្ន ពាក្យផ្ទុយ អសម្ភិន្ន**

**សម្ភិន្ន** *កិ.* ឬ *គុ.* (បា.សំ.) បែកហើយ, ធ្លាយហើយ; ដែលបែកហើយ, ដែលធ្លាយហើយ; ដែលបែកបាក់គ្នា។

**អសម្ភិន្ន** *កិ.* ឬ *គុ.* (បា.សំ.) មិនបែក, មិនធ្លាយ; ដែលមិនបែក, ដែលមិនធ្លាយ; ដែលមិនលាយច្រលំ, ដែលមិនច្រលំបល់, ដែលមិនច្របូកច្របល់; ដែលមិនឈ្លោះប្រកែកបែកបាក់គ្នា។

📖 **សម្ភិន្នញាត ពាក្យផ្ទុយ អសម្ភិន្នញាត**

**សម្ភិន្នញាត** *គុ.* ឬ *ន.* (បា.) ញាតិដែលបែកគ្នា; ដែលកើតឈ្លោះប្រកែកបែកបាក់គ្នា។

**អសម្ភិន្នញាតិ** *ន.* (បា.) ញាតិដែលមិនឈ្លោះប្រកែកបែកបាក់គ្នា; ញាតិពិត។

📖 **សម្ភិន្នពង្ស ពាក្យផ្ទុយ អសម្ភិន្នពង្ស**

**សម្ភិន្នពង្ស** *ន.* (បា.ក្ល.) ពង្សដែលបែកគ្នា, ត្រកូលដែលបែកគ្នា។

**អសម្ភិន្នពង្ស** *ន.* (បា.ក្ល.) ពង្សដែលមិនលាយច្រលំគ្នា, ត្រកូលដែលមិនលាយច្រលំគ្នា, ពង្សមិនច្របូកច្របល់គ្នា, ត្រកូលដែលមិនច្របូកច្របល់គ្នា។

📖 **សម្ភិន្នវង្ស ពាក្យផ្ទុយ អសម្ភិន្នវង្ស**

**សម្ភិន្នវង្ស** *ន.* (បា.ក្ល.) វង្សដែលបែកគ្នា, ត្រកូលដែលបែកគ្នា។

**អសម្ភិន្នវង្ស** *ន.* (បា.ក្ល.) វង្សដែលមិនលាយច្រលំគ្នា, ត្រកូលដែលមិនលាយច្រលំគ្នា, វង្សមិនច្របូកច្របល់គ្នា, ត្រកូលដែលមិនច្របូកច្របល់គ្នា។

📖 **សម្មតិសង្ឃ ពាក្យផ្ទុយ អរិយសង្ឃ**

**សម្មតិសង្ឃ** *ន.* (បា.) ភិក្ខុសង្ឃបុថុជ្ជនដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា (ព.ពុ.)។

**អរិយសង្ឃ** *ន.* (បា.) សង្ឃជាអរិយបុគ្គល (ព.ពុ.)។

📖 **សម្រិត ពាក្យផ្ទុយ សំរូប**

**សម្រិត** *គុ.* ដែលស្រិតរួចហើយ (ប្រើចំពោះតែអង្ករ) :

- ❖ អង្ករសម្រិត។

**សរូប** *គុ.* ដែលនៅមិនទាន់ស្រិត (ចំពោះតែអក្សរ) :

❖ អក្សរសរូប។

📖 **សវិញ្ញាណកៈ ពាក្យផ្ទុយ អវិញ្ញាណកៈ**

**សវិញ្ញាណកៈ** *គុ.* (បា.ភ្ល.) ដែលមានវិញ្ញាណ។

**អវិញ្ញាណកៈ** *គុ.* (បា.ភ្ល.) ដែលឥតវិញ្ញាណ។

📖 **សវិញ្ញាណកទ្រព្យ ពាក្យផ្ទុយ អសវិញ្ញាណកទ្រព្យ**

**សវិញ្ញាណកទ្រព្យ** *ន.* (បា. និង សំ.ភ្ល.) ទ្រព្យមានវិញ្ញាណ :

❖ គោ

❖ ក្របី។

**អសវិញ្ញាណកទ្រព្យ** *ន.* (បា. និង សំ.ភ្ល.) ទ្រព្យឥតវិញ្ញាណ :

❖ មាស

❖ ប្រាក់។

📖 **សស្សាមិក ពាក្យផ្ទុយ អស្សាមិក**

**សស្សាមិក** *គុ.* (បា.) ដែលមានម្ចាស់, ដែលមានចៅហ្វាយនាយ។

**អស្សាមិក** *គុ.* (បា.) ដែលឥតម្ចាស់, ដែលឥតចៅហ្វាយនាយ :

❖ របស់អស្សាមិក

❖ មនុស្សអស្សាមិក។

📖 **សស្សាមិកា ពាក្យផ្ទុយ អស្សាមិកា**

**សស្សាមិកា** *គុ.* (បា.) ដែលមានស្វាមី, ដែលមានប្ដី, ដែលមានប្ដីហើយ។

**អស្សាមិកា** *គុ.* (បា.) ដែលឥតស្វាមី, ដែលឥតប្ដី; ដែលពុំទាន់មានប្ដីនៅឡើយ។

📖 **សូន្យ ពាក្យផ្ទុយ ហេង**

**សូន្យ** *កិ.* ឬ *គុ.* (ចិ.) មិនប្រទះលាភ, ឃ្លាងលាភ; មិនសមបំណង; មោឃៈ, ឥតបានអ្វី។

**ហេង** *គុ.* (ចិ.) ដែលចម្រើន, ដែលឡើងដៃ, ដែលមានលាភ, ដែលមានចំណេញ, ដែលសមប្រកប; ដែលមានជោគ។

📖 **សាធារណៈ ពាក្យផ្ទុយ អសាធារណៈ**

**សាធារណៈ** *គុ.* (បា.សំ.ក្លា.) ដែលទូទៅ; ដែលទុកជាកណ្ដាល, ដែលប្រើបានទាំងអស់គ្នា, ដែលមិនចំពោះមួយៗ; សាមញ្ញ, ដែលរាប់រយរាប់ពាន់។

**អសាធារណៈ** *គុ.* (បា.សំ.ក្លា.) ដែលមិនមែនសាធារណៈ, ដែលមិនទូទៅ, ដែលចំពោះតែមួយៗ; ផ្ទាល់ខ្លួន។

📖 **សាធារណដ្ឋាន ពាក្យផ្ទុយ អសាធារណដ្ឋាន**

**សាធារណដ្ឋាន** *ន.* (បា.) ទីដែលទៅមក, ទីប្រើប្រាស់បានទាំងអស់គ្នា។

**អសាធារណដ្ឋាន** *ន.* (បា.) កន្លែងសម្រាប់ជនម្នាក់ៗ។

📖 **សាធារណទាន ពាក្យផ្ទុយ អសាធារណទាន**

**សាធារណទាន** *ន.* (បា.) ទានដែលឱ្យដល់ជនទូទៅមិនរើសមុខ។

**អសាធារណទាន** *ន.* (បា.) ទានដែលទាយកឱ្យចំពោះបុគ្គល គឺឱ្យសំដៅបុគ្គលម្នាក់ៗមិនទូទៅដល់បុគ្គលឯទៀត, បុគ្គលិកទាន។

📖 **សាធារណទ្រព្យ ពាក្យផ្ទុយ អសាធារណទ្រព្យ**

**សាធារណទ្រព្យ** *ន.* (បា. និង **សំ.ភ្ល.**) ទ្រព្យសាមញ្ញ, របស់រាយ។

**អសាធារណទ្រព្យ** *ន.* (បា. និង **សំ.ភ្ល.**) ទ្រព្យដែលមិនទូទៅដល់បុគ្គលដទៃ; ទ្រព្យឧត្តម។

📖 **សាធារណនាម ពាក្យផ្ទុយ អសាធារណនាម**

**សាធារណនាម** *ន.* (បា.) នាមនាមដែលនៅទូទៅទៀតបាន (សាមញ្ញនាម)។

**អសាធារណនាម** *ន.* (បា.) នាមនាមដែលមិនទូទៅទៀត (វិសាមញ្ញនាម)។

📖 **សាធារណបណ្ណ ពាក្យផ្ទុយ អសាធារណបណ្ណ**

**សាធារណបណ្ណ** *ន.* (បា.) សំបុត្រសាធារណៈ។

**អសាធារណបណ្ណ** *ន.* (បា.) សំបុត្រផ្ទាល់ខ្លួន។

📖 **សាធារណបត្រ ពាក្យផ្ទុយ អសាធារណបត្រ**

**សាធារណបុត្រ** *ន.* (សំ.) សំបុត្រសាធារណៈ។

**អសាធារណបុត្រ** *ន.* (សំ.) សំបុត្រផ្ទាល់ខ្លួន។

📖 **សាធារណប្បញ្ញត្តិ ពាក្យផ្ទុយ អសាធារណប្បញ្ញត្តិ**

**អសាធារណប្បញ្ញត្តិ** *ន.* (បា.) ពុទ្ធប្បញ្ញត្តិដែលទូទៅដល់សហធម្មិកទាំងប្រាំ (ព.វិ.ពុ.)។

**អសាធារណប្បញ្ញត្តិ** *ន.* (បា.) ពុទ្ធប្បញ្ញត្តិដែលមិនទូទៅដល់សហធម្មិកទាំងប្រាំ (ព.វិ.ពុ.)។

📖 **សាធារណប្រយោជន៍ ពាក្យផ្ទុយ អសាធារណប្រយោជន៍**

**សាធារណប្រយោជន៍** *ន.* (សំ.ក្ល.) ប្រយោជន៍សម្រាប់សាធារណជន។

**អសាធារណប្រយោជន៍** *ន.* (សំ.ក្ល.) ប្រយោជន៍ផ្ទាល់ខ្លួន។

📖 **សាធារណសុខ ពាក្យផ្ទុយ អសាធារណសុខ**

**សាធារណសុខ** *ន.* (បា.សំ.) សេចក្ដីសុខរបស់ប្រជាជនទូទៅ។

**អសាធារណសុខ** *ន.* (បា.សំ.) សេចក្ដីសុខផ្ទាល់ខ្លួន។

📖 **សាធារណស្ថាន ពាក្យផ្ទុយ អសាធារណស្ថាន**

**សាធារណស្ថាន** *ន.* (សំ.) ទីដែលទៅមកបានទាំងអស់គ្នា, ទីដែលប្រើប្រាស់បានទាំងអស់គ្នា។

**អសាធារណស្ថាន** *ន.* (សំ.) កន្លែងសម្រាប់ជនម្នាក់ៗ។

📖 **សាធុ ពាក្យផ្ទុយ អសាធុ**

**សាធុ** *គុ.* (បា.សំ.) ល្អ, ប្រពៃ; ត្រូវ, ត្រឹមត្រូវ; ស្រួល, ស្រួលបួល; ដែលឱ្យសម្រេចផល, ដែលសម្រេចប្រយោជន៍; ដែលពិត, មែន។

**អសាធុ** *គុ.* (បា.សំ.) ដែលមិនល្អ, ដែលពុំប្រពៃ, ដែលមិនត្រឹមត្រូវ; អាក្រក់។

📖 **សាធុកម្ម ពាក្យផ្ទុយ អសាធុកម្ម**

**សាធុកម្ម** *ន.* (បា.) អំពើល្អ, បុណ្យ, កុសល។

**អសាធុកម្ម** *ន.* (បា.) អំពើមិនល្អ, អំពើរបស់អសប្បុរស។

📖 **សាធុការ ពាក្យផ្ទុយ អសាធុការ**

**សាធុការ** *ន.* (បា.) សម្ដីពីរោះ, សម្ដីត្រឹមត្រូវ, សាធុវាទ។

**អសាធុការ** *ន.* (បា.) សម្ដីអាក្រក់, សម្ដីអសប្បុរស, អសាធុវាទ។

📖 **សាធុជន ពាក្យផ្ទុយ អសាធុជន**

**សាធុជន** *ន.* (បា.) ជនអ្នកត្រឹមត្រូវ, មនុស្សអ្នកកាន់អំពើល្អ។

**អសាធុជន** *ន.* (បា.) ជនចិត្តអាក្រក់, មនុស្សអ្នកកាន់អំពើអាក្រក់។

📖 **សាធុបថ ពាក្យផ្ទុយ អសាធុបថ**

**សាធុបថ** *ន.* (បា.សំ.) ផ្លូវនៃអំពើល្អ, ផ្លូវត្រឹមត្រូវ។

**អសាធុបថ** *ន.* (បា.សំ.) ផ្លូវនៃអំពើពុំប្រសើរ, ផ្លូវអាក្រក់។

📖 **សាធុវាចា ពាក្យផ្ទុយ អសាធុវាចា**

**សាធុវាចា** *ន.* (បា.) សម្ដីពីរោះ, សម្ដីត្រឹមត្រូវ; សាធុការ។

**អសាធុវាចា** *ន.* (បា.) សម្ដីអាក្រក់, សម្ដីអសប្បុរស។

📖 **សាធុវាទ ពាក្យផ្ទុយ អសាធុវាទ**

**សាធុវាទ** *ន.* (បា.) សម្ដីពីរោះ, សម្ដីត្រឹមត្រូវ; សាធុការ។

**អសាធុវាទ** *ន.* (បា.) សម្ដីអាក្រក់, សម្ដីអសប្បុរស។

📖 **សាធុវាទិន ពាក្យផ្ទុយ អសាធុវាទិន**

**សាធុវាទិន** *ន.* (សំ.) អ្នកពោលពាក្យពីរោះ, អ្នកពោលពាក្យត្រឹមត្រូវ; សាធុការី។

**អសាធុវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែប្រើសម្ដីផ្ដន្ទា, អ្នកដែលច្រើនតែប្រើសម្ដីនៃអសប្បុរស។

📖 **សាធុវាទិនី ពាក្យផ្ទុយ អសាធុវាទិនី**

**សាធុវាទិនី** *ន.* (បា.) ស្រ្ដីអ្នកពោលពាក្យពីរោះ, ស្រ្ដីអ្នកពោលពាក្យត្រឹមត្រូវ; សាធុការិនី។

**អសាធុវាទិនី** *ន.* (បា.) ស្រ្ដីដែលច្រើនតែប្រើសម្ដីផ្ដន្ទា, ស្រ្ដីដែលច្រើនតែប្រើ

សម្ដីនៃអសប្បុរស។

📖 **សាធុវាទី ពាក្យផ្ទុយ អសាធុវាទី**

**សាធុវាទី** *ន.* (បា.) អ្នកពោលពាក្យពីរោះ, អ្នកពោលពាក្យត្រឹមត្រូវ; សាធុការី។

**អសាធុវាទី** *ន.* (បា.) អ្នកដែលច្រើនតែប្រើសម្ដីផ្ដន្ទា, អ្នកដែលច្រើនតែប្រើសម្ដីនៃអសប្បុរស។

📖 **សាមញ្ញនាម ពាក្យផ្ទុយ អសាមញ្ញនាម**

**សាមញ្ញនាម** *ន.* (បា.) នាមនាមដែលនៅទូទៅទៀតបាន (សាធារណនាម)។

**អសាមញ្ញនាម** *ន.* (បា.) នាមនាមដែលមិនទូទៅទៀត (អសាធារណនាម)។

📖 **សាមញ្ញសាសនា ពាក្យផ្ទុយ ព្រហ្មញ្ញសាសនា, អញ្ញលទ្ធិ**

**សាមញ្ញសាសនា** *ន.* (បា.) សាសនារបស់ព្រះពុទ្ធដែលមានភាពជាសមណៈពិត, សាសនាស្រោចស្រង់សត្វ (ពុទ្ធសាសនា)។

**ព្រហ្មញ្ញសាសនា** *ន.* (បា.) សាសនាដែលមានការជាប់ទាក់ទងដោយសេចក្ដីប្រកាន់ជឿថាមហាព្រហ្មជាអ្នកបង្កើតពពួកសត្វ។

**អញ្ញលទ្ធិ** *ន.* (បា.) លទ្ធិដទៃ។

📖 **សាយណ្ហសុវត្ថិ! ពាក្យផ្ទុយ រាត្រីសុវត្ថិ!, អរុណសុវត្ថិ!**

**សាយណ្ហសុខត្ថិ!** *កិ.* ឬ *ឧ.* សួស្ដីក្នុងវេលារសៀល, សួស្ដីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នា, ពាក្យសម្រាប់គំនាប់គ្នាក្នុងវេលាតាំងអំពីថ្ងៃជ្រេពីត្រង់រហូតដល់ថ្ងៃអស្ដង្គត (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលារសៀល, សូមឱ្យមានសួស្ដីក្នុងវេលាល្ងាច!។

**រាត្រីសុខត្ថិ!** *កិ.* ឬ *ឧ.* សួស្ដីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាយប់!។

**អរុណសុខត្ថិ!** *កិ.* ឬ *ឧ.* សួស្ដីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នា, ពាក្យសម្រាប់គំនាប់គ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាព្រឹក!។

📖 **សាយណ្ហសួស្ដី! ពាក្យផ្ទុយ រាត្រីសួស្ដី!, អរុណសួស្ដី!**

**សាយណ្ហសួស្ដី!** *កិ.* ឬ *ឧ.* សួស្ដីក្នុងវេលារសៀល, សួស្ដីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នា, ពាក្យសម្រាប់គំនាប់គ្នាក្នុងវេលាតាំងអំពីថ្ងៃជ្រេពីត្រង់រហូតដល់ថ្ងៃអស្ដង្គត (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលារសៀល,សូមឱ្យមានសួស្ដីក្នុងវេលាល្ងាច!។

**រាត្រីសួស្ដី!** *កិ.* ឬ *ឧ.* សួស្ដីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់

(ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាយប់!។

**អរុណសួស្ដី!** *កិ.* ឬ *ន.* សួស្ដីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នា, ពាក្យសម្រាប់គំនាប់គ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាព្រឹក!។

📖 **សារ ពាក្យផ្ទុយ អសារ**

**សារ** *គុ.* (បា.សំ.) រឹង, រឹងប៉ឹង, ខ្ជាប់ខ្ជួន, មាំមួន; ខ្លាំង, ដែលមានកម្លាំង; ដែលក្លាហាន, ដែលអង់អាច, ដែលអាចហ៊ាន; ដែលពិត, ដែលប្រាកដ; មានតម្លៃ; ថ្លៃ, ថ្លៃថ្លា, ប្រសើរ, ខ្ពង់ខ្ពស់; សំខាន់; គ្រប់, គ្រប់សព្វ; ...។

**អសារ** *គុ.* (បា.សំ.) ដែលឥតខ្លឹម; ដែលឥតប្រយោជន៍, ដែលឥតអំពើ; ដែលមិនកើតការ, ដែលមិនបានការ; ដែលមិនខ្ជាប់ខ្ជួន, ដែលមិនរឹងប៉ឹង; ដែលគ្មានតម្លៃ; ដែលមិនពិត, ដែលពុំប្រាកដ; ...។

📖 **សារគត ពាក្យផ្ទុយ អសារគត**

**សារគត** *ន.* (បា.សំ.) គតិខ្ជាប់ខ្ជួន។

**សារគត** *ន.* (បា.សំ.) គតិមិនខ្ជាប់ខ្ជួន; គតិមិននឹង។

📖 **សារជាត ពាក្យផ្ទុយ អសារជាត**

**សារជាត** *ន.* (បា.សំ.) ឈើមានខ្លឹម។

**អសារជាត** *ន.* (បា.សំ.) ឈើឥតខ្លឹមមានសុទ្ធតែសាច់ស្រាយ :

❖ គ

❖ រកា។

📖 **សារទ្រព្យ ពាក្យផ្ទុយ អសារទ្រព្យ**

**សារទ្រព្យ** *ន.* (សំ.ភ្ល.) ទ្រព្យមានតម្លៃ។

**អសារទ្រព្យ** *ន.* (សំ.ភ្ល.) ទ្រព្យថយថោក, ទ្រព្យឥតតម្លៃ។

📖 **សារធន ពាក្យផ្ទុយ អសារធន**

**សារធន** *ន.* (បា.សំ.) ទ្រព្យមានតម្លៃ។

**អសារធន** *ន.* (បា.សំ.) ទ្រព្យថយថោក, ទ្រព្យឥតតម្លៃ។

📖 **សារធម្ម ពាក្យផ្ទុយ អសារធម្ម**

**សារធម្ម** *ន.* (បា.) ធម៌ជាសារៈ, ធម៌ជាគោល។

**អសារធម្ម** *ន.* (បា.) ធម៌ឥតខ្លឹម, ធម៌ឥតគោល គឺមិច្ឆាប្រតិប័ទ។

📖 **សារធម៌ ពាក្យផ្ទុយ អសារធម៌**

**សារធម៌** *ន.* (សំ.) ធម៌ជាសារៈ, ធម៌ជាគោល។

**អសារធម៌** *ន.* (សំ.) ធម៌ឥតខ្លឹម, ធម៌ឥតគោល គឺមិច្ឆាប្រតិប័ទ។

📖 **សារព្រឹក្ស ពាក្យផ្ទុយ អសារព្រឹក្ស**

**សារព្រឹក្ស** *ន.* (សំ.ភ្ល.) ឈើមានខ្លឹម។

**អសារព្រឹក្ស** *ន.* (សំ.ភ្ល.) ឈើឥតខ្លឹមមានសុទ្ធតែសាច់ស្រោយ :

❖ គ

❖ រកា។

📖 **សារវាចា ពាក្យផ្ទុយ អសារវាចា**

**សារវាចា** *ន.* (បា.) សម្ដីសារៈ, សម្ដីមានសព្ទមានសារ។

**អសារវាចា** *ន.* (បា.) សម្ដីឥតសារៈ, សម្ដីឥតសព្ទឥតសារ។

📖 **សារវាទ ពាក្យផ្ទុយ អសារវាទ**

**សារវាទ** *ន.* (បា.) សម្ដីសារៈ, សម្ដីមានសព្ទមានសារ។

**អសារវាទ** *ន.* (បា.) សម្ដីឥតសារៈ, សម្ដីឥតសព្ទឥតសារ។

📖 **សារវាទិន ពាក្យផ្ទុយ អសារវាទិន**

**សារវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែប្រើសម្ដីមានសារៈ។

**អសារវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែប្រើសម្ដីឥតសារៈ។

📖 **សារវាទិនី ពាក្យផ្ទុយ អសារវាទិនី**

**សារវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែប្រើសម្ដីមានសារៈ។

**អសារវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែប្រើសម្ដីឥតសារៈ។

📖 **សារវាទី ពាក្យផ្ទុយ អសារវាទី**

**សារវាទី** *ន.* (បា.) អ្នកដែលច្រើនតែប្រើសម្ដីមានសារៈ។

**អសារវាទី** *ន.* (បា.) អ្នកដែលច្រើនតែប្រើសម្ដីឥតសារៈ។

📖 **សីតាលុ ពាក្យផ្ទុយ ឧណ្ហាលុ**

**សីតាលុ** *គុ.* ឬ *ន.* (បា.) ដែលមានត្រជាក់ច្រើន; ប្រទេសរងាខ្លាំង; មនុស្សចាញ់រងា។

**ឧណ្ហាលុ** *គុ.* ឬ *ន.* (បា.) ដែលមានក្ដៅច្រើន; ប្រទេសដែលមានក្ដៅច្រើន :

- ប្រទេសឧណ្ហាលុ។

📖 **សីតោទក ពាក្យផ្ទុយ ឧណ្ហោទក**

**សីតោទក** *ន.* (បា.) ទឹកត្រជាក់។

**ឧណ្ហោទក** *ន.* (បា.) ទឹកក្ដៅ។

📖 **ស៊ីជម្រៅ ពាក្យផ្ទុយ ស៊ីរាក់**

**ស៊ីជម្រៅ** *គុ.* ដែលមានបាតជ្រៅ (ចំពោះតែនាវា) :

- ទូកស៊ីជម្រៅ។

**ស៊ីរាក់** *គុ.* ដែលមានបាតរាក់ (ចំពោះតែនាវា) :

- ទូកស៊ីរាក់។

📖 **ស៊ីទឹកជ្រៅ** **ពាក្យផ្ទុយ** **ស៊ីទឹករាក់**

**ស៊ីទឹកជ្រៅ** *គុ.* ដែលមានបាតជ្រៅ (ចំពោះតែនាវា) :

❖ ទូកស៊ីទឹកជ្រៅ។

**ស៊ីទឹករាក់** *គុ.* ដែលមានបាតរាក់ (ចំពោះតែនាវា) :

❖ ទូកស៊ីទឹករាក់។

📖 **ស៊ីតូច** **ពាក្យផ្ទុយ** **ស៊ីធំ**

**ស៊ីតូច** *កិ.* ចាយវាយតូច, ស៊ីម្ហូបតិចមុខ។

**ស៊ីធំ** *កិ.* ចាយវាយធំ, ស៊ីម្ហូបច្រើនមុខ។

📖 **ស៊ីថ្លៃ** **ពាក្យផ្ទុយ** **ស៊ីថោក**

**ស៊ីថ្លៃ** *កិ.* យកតម្លៃថ្លៃ, យកថ្លៃច្រើន។

**ស៊ីថោក** *កិ.* យកតម្លៃថោក, យកថ្លៃតិច។

📖 **ស៊ីទម្លាក់** **ពាក្យផ្ទុយ** **ស៊ីសាប់**

**ស៊ីទម្លាក់** *កិ.* និយាយពីទូក-ងមាឧរឹងបានតែអុំទម្លាក់ច្រវាឱ្យយាងយារមួយៗទើបលឿន :

❖ ទូកនេះស៊ីទម្លាក់អុំសាប់មិនលឿនទេ។

**ស៊ីសាប់** *កិ.* និយាយពីទូក-ងមាឧទន់បានតែអុំសាប់ឱ្យញាប់ច្រវាទើបលឿន :

❖ ទូកនេះស៊ីសាប់អុំយាងយាវមិនលឿនទេ។

📖 **ស៊ីយាងយាវ ពាក្យផ្ទុយ ស៊ីសាប់**

**ស៊ីយាងយាវ** *កិ.* និយាយពីទូក-ងមាឌរឹងបានតែអុំទម្លាក់ច្រវាឱ្យយាង យាវមួយៗទើបលឿន :

❖ ទូកនេះស៊ីទម្លាក់អុំសាប់មិនលឿនទេ។

**ស៊ីសាប់** *កិ.* និយាយពីទូក-ងមាឌទន់បានតែអុំសាប់ឱ្យញាប់ច្រវាទើបលឿន :

❖ ទូកនេះស៊ីសាប់អុំយាងយាវមិនលឿនទេ។

📖 **សុខុម ពាក្យផ្ទុយ ឱឡារិក**

**សុខុម** *គុ.* (បា.) ល្អិត, ឆ្មារ, ម៉ដ្ឋ; ប៉ផូរ, ផូរផង់; ល្វន់; តូចណាស់; ចង្អៀតក្រយល់; ល្អោសវៃ។

**ឱឡារិក** *គុ.* (បា.) គ្រោតៗ, គ្រោតគ្រាត; ច្បាស់លាស់។

📖 **សុខុមរូប ពាក្យផ្ទុយ ឱឡារិករូប**

**សុខុមរូប** *ន.* (បា.) រូបដែលមិនគ្រោតគ្រាត, រូបដែលមិនច្បាស់លាស់។

**ឱឡារិករូប** *ន.* (បា.) រូបគ្រោតគ្រាត; រូបដែលច្បាស់លាស់។

📖 **សុចិ ពាក្យផ្ទុយ អសុចិ**

**សុចិ** *គុ.* (បា.សំ.) ស្អាត, បរិសុទ្ធ, ហ្មត់ហ្មង, ឥតមន្ទិល, សុទ្ធ, ជ្រះ; សមរម្យ;

ស; ថ្លា; ភ្លឺ, រុងរឿង, ត្រចះ, ត្រចង់; ល្អ; ស្លូតត្រង់។

**អសុចិ** *គុ.* (បា.សំ.) ដែលមិនស្អាត, ដែលមិនបរិសុទ្ធ; សោគ្រោក; កខ្វក់ :

- ❖ ទីអសុចិ
- ❖ ទឹកអសុចិ។

📖 **សុចិកម្ម ពាក្យផ្ទុយ អសុចិកម្ម**

**សុចិកម្ម** *ន.* (បា.) អំពើបរិសុទ្ធ; អ្នកដែលមានអំពើស្អាត។

**អសុចិកម្ម** *ន.* (បា.) អំពើមិនស្អាត, អំពើមិនបរិសុទ្ធ; អំពើអាក្រក់; អ្នកដែលមានអំពើមិនស្អាត។

📖 **សុចិគន្ធ ពាក្យផ្ទុយ អសុចិគន្ធ**

**សុចិគន្ធ** *ន.* (បា.សំ.) ក្លិនល្អ។

**អសុចិគន្ធ** *ន.* (បា.សំ.) ក្លិនមិនល្អ។

📖 **សុចិចរិត ពាក្យផ្ទុយ អសុចិចរិត**

**សុចិចរិត** *ន.* (បា.សំ.) ចរិតល្អ; អ្នកដែលមានចរិតល្អ។

**អសុចិចរិត** *ន.* (បា.សំ.) ចរិតមិនស្អាត; អ្នកដែលមានចរិតមិនស្អាត។

📖 **សុចិចរិយា ពាក្យផ្ទុយ អសុចិចរិយា**

**សុចិចរិយា** *ន.* (បា.) ចរិយាល្អ; ការប្រព្រឹត្តស្លូតត្រង់។

**អសុចិចរិយា** *ន.* (បា.) ចរិយាមិនស្អាត, ការប្រព្រឹត្តខ្ជីខ្ជា។

📖 **សុចិដ្ឋាន** **ពាក្យផ្ទុយ** **អសុចិដ្ឋាន**

**សុចិដ្ឋាន** *ន.* (បា.) ឋានស្អាត, ទីស្អាត។

**អសុចិដ្ឋាន** *ន.* (បា.) ឋានមិនស្អាត, ទីកខ្វក់។

📖 **សុចិនន្ត** **ពាក្យផ្ទុយ** **អសុចិនន្ត**

**សុចិនន្ត** *ន.* (បា.សំ.) ធ្មេញស; អ្នកដែលមានធ្មេញស; របស់ដែលធ្វើដោយភ្លុកសុទ្ធ។

**អសុចិនន្ត** *ន.* (បា.សំ.) ធ្មេញមិនស្អាត, អ្នកដែលមានធ្មេញមិនស្អាត។

📖 **សុចិភាព** **ពាក្យផ្ទុយ** **អសុចិភាព**

**សុចិភាព** *ន.* (បា.សំ.ភ្ល.) ភាពស្អាត; ភាពល្អ។

**អសុចិភាព** *ន.* (បា.សំ.ភ្ល.) ភាពមិនស្អាត, ភាពអាក្រក់។

📖 **សុចិភូមិ** **ពាក្យផ្ទុយ** **អសុចិភូមិ**

**សុចិភូមិ** *ន.* (បា.សំ.) ភូមិស្អាត, ទីស្អាត។

**អសុចិភូមិ** *ន.* (បា.សំ.) ភូមិមិនស្អាត, ទីកខ្វក់។

📖 **សុចិវត្ថុ** **ពាក្យផ្ទុយ** **អសុចិវត្ថុ**

**សុចិវត្ថុ** *ន.* (បា.) វត្ថុស្អាត។

**អសុចិវត្ថុ** *ន.* (បា.) វត្ថុមិនស្អាត។

📖 **សុចិសន្តាន ពាក្យផ្ទុយ អសុចិសន្តាន**

**សុចិសន្តាន** *ន.* (បា.) សន្តានស្អាត។

**អសុចិសន្តាន** *ន.* (បា.) សន្តានមិនស្អាត។

📖 **សុចិសភាព ពាក្យផ្ទុយ អសុចិសភាព**

**សុចិសភាព** *ន.* (បា.សំ.ភ្ល.) សភាពល្អ; អ្នកដែលមានសណ្ដាប់ធ្នាប់ល្អ។

**អសុចិសភាព** *ន.* (បា.សំ.ភ្ល.) សភាពមិនល្អ, សភាពមិនបរិសុទ្ធ។

📖 **សុទ្ធិ ពាក្យផ្ទុយ អសុទ្ធិ**

**សុទ្ធិ** *ន.* (បា.សំ.) ការជម្រះ, សេចក្ដីស្អាត, បរិសុទ្ធិ; សេចក្ដីហ្មត់ហ្មង; ដំណើរមិនលាយ; សេចក្ដីពិត; សេចក្ដីត្រឹមត្រូវ។

**អសុទ្ធិ** *ន.* (បា.សំ.) សេចក្ដីមិនបរិសុទ្ធ, ដំណើរសៅហ្មង, ដំណើរមោះហ្មង, ដំណើរមោះមិនគាប់; អំពើអាក្រក់; បាប, អកុសល។

📖 **សុទ្ធិភាព ពាក្យផ្ទុយ អសុទ្ធិភាព**

**សុទ្ធិភាព** *ន.* (បា.សំ.ភ្ល.) ភាពនៃសេចក្ដីបរិសុទ្ធ។

**អសុទ្ធិភាព** *ន.* (បា.សំ.ភ្ល.) ភាពនៃសេចក្ដីមិនបរិសុទ្ធ។

📖 **សុទ្ធិមតី ពាក្យផ្ទុយ អសុទ្ធិមតី**

**សុទ្ធិមតី** *ន.* (បា.) ស្ត្រីអ្នកដែលមានសេចក្ដីបរិសុទ្ធ។

**អសុទ្ធិមតី** *ន.* (បា.) ស្ត្រីអ្នកដែលមានសេចក្ដីមិនបរិសុទ្ធ។

📖 **សុទ្ធិមន្ត** **ពាក្យផ្ទុយ** **អសុទ្ធិមន្ត**

**សុទ្ធិមន្ត** *ន.* (បា.) អ្នកដែលមានសេចក្ដីបរិសុទ្ធ។

**អសុទ្ធិមន្ត** *ន.* (បា.) អ្នកដែលមានសេចក្ដីមិនបរិសុទ្ធ។

📖 **សុន្ទរ** **ពាក្យផ្ទុយ** **អសុន្ទរ**

**សុន្ទរ** *គុ.* (បា.សំ.) ល្អ, ប្រពៃ; ពីរោះ, ដែលគួរចង់ឮគួរចង់ស្ដាប់, ពីរោះ ចាប់ចិត្ត; ដែលគួរស្រលាញ់; គួររីករាយ។

**អសុន្ទរ** *គុ.* (បា.សំ.) ដែលមិនល្អ; ដែលពុំពីរោះ។

📖 **សុន្ទរពាក្យ** **ពាក្យផ្ទុយ** **អសុន្ទរពាក្យ**

**សុន្ទរពាក្យ** *ន.* (បា.ខ្មែ.) សម្ដីពីរោះ, សម្ដីគួរចង់ស្ដាប់។

**អសុន្ទរពាក្យ** *ន.* (បា.ខ្មែ.) សម្ដីពុំពីរោះ; សម្ដីអាក្រក់។

📖 **សុន្ទរពេចន៍** **ពាក្យផ្ទុយ** **អសុន្ទរពេចន៍**

**សុន្ទរពេចន៍** *ន.* (បា.ខ្មែ.) ពាក្យពីរោះ។

**អសុន្ទរពេចន៍** *ន.* (បា.ខ្មែ.) សម្ដីពុំពីរោះ; សម្ដីអាក្រក់។

📖 **សុន្ទរវាចា** **ពាក្យផ្ទុយ** **អសុន្ទរវាចា**

**សុន្ទរវាចា** *ន.* (បា.) ពាក្យពីរោះ។

**អសុន្ទរវាចា** *ន.* (បា.) សម្ដីពុំពីរោះ; សម្ដីអាក្រក់។

📖 **សុន្ទរវាទ ពាក្យផ្ទុយ អសុន្ទរវាទ**

**សុន្ទរវាទ** *ន.* (បា.) ពាក្យពីរោះ។

**អសុន្ទរវាទ** *ន.* (បា.) សម្ដីពុំពីរោះ; សម្ដីអាក្រក់។

📖 **សុន្ទរវាទិន ពាក្យផ្ទុយ អសុន្ទរវាទិន**

**សុន្ទរវាទិន** *ន.* (សំ.) អ្នកដែលមានសម្ដីពីរោះ។

**អសុន្ទរវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែប្រើសម្ដីអាក្រក់។

📖 **សុន្ទរវាទិនី ពាក្យផ្ទុយ អសុន្ទរវាទិនី**

**សុន្ទរវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលមានសម្ដីពីរោះ។

**អសុន្ទរវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែប្រើសម្ដីអាក្រក់។

📖 **សុន្ទរវាទី ពាក្យផ្ទុយ អសុន្ទរវាទី**

**សុន្ទរវាទី** *ន.* (បា.) អ្នកដែលមានសម្ដីពីរោះ។

**អសុន្ទរវាទី** *ន.* (បា.) អ្នកដែលច្រើនតែប្រើសម្ដីអាក្រក់។

📖 **សុន្ទរសព្ទ ពាក្យផ្ទុយ អសុន្ទរសព្ទ**

**សុន្ទរសព្ទ** *ន.* (សំ.) សូរសព្ទពីរោះ។

**អសុន្ទរសព្ទ** *ន.* (សំ.) សូរសព្ទពុំពីរោះ។

📖 **សុភ ពាក្យផ្ទុយ អសុភ**

**សុភ** *គុ.* (បា.សំ.) ល្អ, ប្រពៃ; ស្អាត, ឥតមានហ្មង; សម, សមរម្យ; ដែលគួរស្រលាញ់, ដែលគួរចាប់ចិត្ត; មានសិទ្ធិជោគ; មានសិរី, មានសួស្តី; មានលាភ; មានសេចក្តីសុខ; មានសេចក្តីចម្រើន; ដែលឱ្យគុណ, ដែលឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង។

**អសុភ** *គុ.* (បា.សំ.) មិនល្អ; គួរខ្ពើម, គួរឆ្អើម :

- ❖ រូបអសុភ
- ❖ របស់អសុភ។

📖 **សុភានុបស្សិនី ពាក្យផ្ទុយ អសុភានុបស្សិនី**

**សុភានុបស្សិនី** *ន.* (បា.) ស្ត្រីអ្នកដែលសម្លឹងរំពឹងឃើញរូបកាយថាល្អ។

**អសុភានុបស្សិនី** *ន.* (បា.) ស្ត្រីអ្នកដែលសម្លឹងរំពឹងឃើញរូបកាយថាមិនល្អ។

📖 **សុភានុបស្សី ពាក្យផ្ទុយ អសុភានុបស្សី**

**សុភានុបស្សី** *ន.* (បា.) អ្នកដែលសម្លឹងរំពឹងឃើញរូបកាយថាល្អ។

**អសុភានុបស្សី** *ន.* (បា.) អ្នកដែលសម្លឹងរំពឹងឃើញរូបកាយថាមិនល្អ។

📖 **សុភារម្មណ៍ ពាក្យផ្ទុយ អសុភារម្មណ៍**

**សុភារម្មណ៍** *ន.* (បា.ភ្គ.) អារម្មណ៍ដែលមិនតោងជាប់ចំពោះទៅរករូបអសុភ។

**អសុភារម្មណ៍** *ន.* (បា.ភ្គ.) អារម្មណ៍ដែលតោងជាប់ចំពោះទៅរករូបអសុភ។

📖 **សេក្ខៈ ពាក្យផ្ទុយ អសេក្ខៈ**

**សេក្ខៈ** *ន.* (បា.ភ្គ.) អ្នកដែលនៅកំពុងសិក្សា, អ្នករៀន។

**អសេក្ខៈ** *ន.* (បា.ភ្គ.) អ្នកដែលអស់កិច្ចក្នុងការសិក្សាហើយ; អ្នកដែលឈប់លែងសិក្សាតទៅទៀតហើយ។

📖 **សេក្ខបុគ្គល ពាក្យផ្ទុយ អសេក្ខបុគ្គល**

**សេក្ខបុគ្គល** *ន.* (បា.) បុគ្គលអ្នកនៅកំពុងសិក្សាតទៅទៀត។

**អសេក្ខបុគ្គល** *ន.* (បា.) បុគ្គលដែលអស់ការសិក្សាតទៅទៀតហើយ។

📖 **សេក្ខភូមិ ពាក្យផ្ទុយ អសេក្ខភូមិ**

**សេក្ខភូមិ** *ន.* (បា.) ថ្នាក់នៃសេក្ខបុគ្គល។

**អសេក្ខភូមិ** *ន.* (បា.) ថ្នាក់នៃអសេក្ខបុគ្គល។

📖 **សេខៈ ពាក្យផ្ទុយ អសេខៈ**

**សេខៈ** *ន.* (បា.ភ្គ.) អ្នកដែលនៅកំពុងសិក្សា, អ្នករៀន។

**អសេខៈ** *ន.* (បា.ភ្គ.) អ្នកដែលអស់កិច្ចក្នុងការសិក្សាហើយ; អ្នកដែលឈប់លែងសិក្សាតទៅទៀតហើយ។

📖 **សេរប្បទេស** **ពាក្យផ្ទុយ** **អសេរប្បទេស**

**សេរប្បទេស** *ន.* (បា.) ប្រទេសឯករាជ្យដែលមានអំណាចលើខ្លួនឯង។

**អសេរប្បទេស** *ន.* (បា.) ប្រទេសមិនមានឯករាជ្យដែលមិនមានអំណាចលើខ្លួនឯង។

📖 **សេរិនី** **ពាក្យផ្ទុយ** **អសេរិនី**

**សេរិនី** *ន.* (បា.) ស្ត្រីអ្នកដែលមានអំណាចលើខ្លួនឯង។

**អសេរិនី** *ន.* (បា.) ស្ត្រីអ្នកដែលមិនមានអំណាចលើខ្លួនឯង, ស្ត្រីអ្នកដែលនៅក្រោមបង្គាប់គេ។

📖 **សេរី** **ពាក្យផ្ទុយ** **អសេរី**

**សេរី** *ន.* (បា.) អ្នកដែលមានអំណាចលើខ្លួនឯង, អត្តាធីន។

**អសេរី** *ន.* (បា.) អ្នកដែលមិនមានអំណាចលើខ្លួនឯង, អ្នកដែលនៅក្រោមបង្គាប់គេ។

📖 **សេរីបទេស** **ពាក្យផ្ទុយ** **អសេរីបទេស**

**សេរីបទេស** *ន.* (បា.) ប្រទេសឯករាជ្យដែលមានអំណាចពេញទី។

**អសេរីបទេស** *ន.* (បា.) ប្រទេសឥតអំណាច, ប្រទេសជាចំណុះគេ។

📖 **សេរីភាព** **ពាក្យផ្ទុយ** **អសេរីភាព**

**សេរីភាព** *ន.* (បា.ក្ល.) អំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ប៉ុន្តែនៅក្រោមច្បាប់, អំណាចពេញទី (ប៉ុន្តែមានមាត្រាច្បាប់ជាគោលដែរ) :

- ❖ ទៅមកដោយសេរីភាព
- ❖ ចិញ្ចឹមជីវិតដោយសេរីភាព។

**អសេរីភាព** *ន.* (បា.ក្ល.) ភាវៈនៃអ្នកឥតអំណាច។

📖 **សំហារិម ពាក្យផ្ទុយ អសំហារិម**

**សំហារិម** *គុ.* (បា.) ដែលនាំយកទៅមកបាន, ដែលលើកយកទៅមកបាន, ដែលអាចធ្វើឱ្យកក្រើកចាកទីបាន, ដែលអាចធ្វើឱ្យឃ្លាតចាកទីបាន :

- ❖ ចាន
- ❖ កៅអី។

**អសំហារិម** *គុ.* (បា.) ដែលនាំយកទៅមកពុំបាន, ដែលលើកយកទៅមកពុំបាន, ដែលពុំអាចធ្វើឱ្យកក្រើក, ដែលពុំអាចធ្វើឱ្យឃ្លាតចាកទីបាន :

- ❖ ស្រែ
- ❖ ចម្ការ។

📖 **ស្រលាញ់ ពាក្យផ្ទុយ ស្អប់**

**ស្រលាញ់** *កិ.* គាប់ចិត្តដោយស្នេហា, គាប់ចិត្តដោយមេត្តា, ពេញចិត្តដោយ

ស្នេហា, ពេញចិត្តដោយមេត្តា, ក្តួចកាន់ចិត្តដោយស្នេហា, ក្តួចកាន់ចិត្តដោយមេត្តា, ជាប់ចិត្តដោយស្នេហា, ជាប់ចិត្តដោយមេត្តា :

❖ មាតាបិតាស្រលាញ់បុត្រ។

**ស្អប់** *កិ.* មិនស្រលាញ់, ទាស់ចិត្ត មិនចង់ឱ្យប៉ះអារម្មណ៍ :

❖ ស្អប់មិនចង់ឃើញមុខ។

📖 **ស្រូវធ្ងន់ ពាក្យផ្ទុយ ស្រូវស្រាល**

**ស្រូវធ្ងន់** *ន.* ស្រូវដែលធ្វើយូរខែទើបបានផ្លែទុំ។

**ស្រូវស្រាល** *ន.* ស្រូវដែលធ្វើតិចខែបានផ្លែទុំ។

📖 **ស្វាគម្លុល ពាក្យផ្ទុយ ស្វាខ្ចី, ស្វាស្លឹង**

**ស្វាគម្លុល** *ន.* ផ្លែស្វាទុំដែលផ្អាប់ទុកឱ្យរលួយសំបក។

**ស្វាខ្ចី** *ន.* ផ្លែស្វាខ្ចីស្រស់។

**ស្វាស្លឹង** *ន.* ស្វាទុំសាច់ស្ងួត។

📖 **ស្វៃរិន ពាក្យផ្ទុយ អស្វៃរិន**

**ស្វៃរិន** *ន.* (សំ.) អ្នកដែលមានអំណាចលើខ្លួនឯង, អត្តាធីន។

**អស្វៃរិន** *ន.* (សំ.) អ្នកដែលមិនមានអំណាចលើខ្លួនឯង, អ្នកដែលនៅក្រោមបង្គាប់គេ។

📖 **ស្វៃរិនី** **ពាក្យផ្ទុយ** **អស្វៃរិនី**

**ស្វៃរិនី** *ន.* (សំ.) ស្ត្រីអ្នកដែលមានអំណាចលើខ្លួនឯង។

**អស្វៃរិនី** *ន.* (សំ.) ស្ត្រីអ្នកដែលមិនមានអំណាចលើខ្លួនឯង, ស្ត្រីអ្នកដែលនៅក្រោមបង្គាប់គេ។

📖 **ស្វៃរីប្រទេស** **ពាក្យផ្ទុយ** **អស្វៃរីប្រទេស**

**ស្វៃរីប្រទេស** *ន.* (សំ.) ប្រទេសឯករាជ្យដែលមានអំណាចពេញទី។

**អស្វៃរីប្រទេស** *ន.* (សំ.) ប្រទេសឥតអំណាច, ប្រទេសជាចំណុះគេ។

📖 **ស្វៃរីភាព** **ពាក្យផ្ទុយ** **អស្វៃរីភាព**

**ស្វៃរីភាព** *ន.* (សំ.ភ្ល.) អំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ប៉ុន្តែនៅក្រោមច្បាប់, អំណាចពេញទី (ប៉ុន្តែមានមាត្រាច្បាប់ជាគោលដែរ) :

❖ មានស្វៃរីភាព

❖ ចិញ្ចឹមជីវិតដោយស្វៃរីភាព។

**អស្វៃរីភាព** *ន.* (សំ.ភ្ល.) ភាពនៃអ្នកឥតអំណាច។

📖 **ហិត** **ពាក្យផ្ទុយ** **អហិត**

**ហិត** *ន.* (បា.សំ.) ផលប្រយោជន៍, ប្រយោជន៍ដ៏ល្អ; សេចក្តីសុខក្សេមក្សាន្ត; ការទំនុកបម្រុង, ការផ្គុងផ្គើម; សម្លាញ់ភ្ញា; ...។

**អហិត** *គុ.* (បា.សំ.) ដែលឥតផលប្រយោជន៍; ដែលមិនមែនជាការទំនុកបម្រុង, ដែលមិនមែនជាការផ្គុងផ្គើម។

📖 **ហិតកម្ម** **ពាក្យផ្ទុយ** **អហិតកម្ម**

**ហិតកម្ម** *ន.* (បា.) អំពើមានផលប្រយោជន៍។

**អហិតកម្ម** *ន.* (បា.) អំពើឥតផលប្រយោជន៍។

📖 **ហិតករ** **ពាក្យផ្ទុយ** **អហិតករ**

**ហិតករ** *ន.* (បា.) អ្នកធ្វើផលប្រយោជន៍, អ្នកទំនុកបម្រុង, អ្នកផ្គុងផ្គើម។

**អហិតករ** *ន.* (បា.) អ្នកដែលធ្វើអំពើឥតផលប្រយោជន៍, អ្នកដែលធ្វើឱ្យឥតផលប្រយោជន៍។

📖 **ហិតការកៈ** **ពាក្យផ្ទុយ** **អហិតការកៈ**

**ហិតការកៈ** *ន.* (បា.ក្ល.) អ្នកធ្វើផលប្រយោជន៍ឱ្យ, អ្នកទំនុកបម្រុង, អ្នកផ្គុងផ្គើម។

**អហិតការកៈ** *ន.* (បា.ក្ល.) អ្នកដែលធ្វើអំពើឥតផលប្រយោជន៍, អ្នកដែលធ្វើឱ្យឥតផលប្រយោជន៍។

📖 **ហិតការិកា** **ពាក្យផ្ទុយ** **អហិតការិកា**

**ហិតការិកា** *ន.* (បា.) ស្ត្រីអ្នកធ្វើផលប្រយោជន៍ឱ្យ, ស្ត្រីអ្នកទំនុកបម្រុង,

ស្ត្រីអ្នកផ្គុងផ្ដើម។

**អហិតការិកា** *ន.* (បា.) ស្ត្រីអ្នកដែលធ្វើអំពើឥតផលប្រយោជន៍, ស្ត្រីអ្នកដែលធ្វើឱ្យឥតផលប្រយោជន៍។

📖 **ហិតការិនី ពាក្យផ្ទុយ អហិតការិនី**

**ហិតការិនី** *ន.* (បា.) ស្ត្រីអ្នកធ្វើផលប្រយោជន៍ឱ្យ, ស្ត្រីអ្នកទំនុកបម្រុង, ស្ត្រីអ្នកផ្គុងផ្ដើម។

**អហិតការិនី** *ន.* (បា.) ស្ត្រីអ្នកដែលធ្វើអំពើឥតផលប្រយោជន៍, ស្ត្រីអ្នកដែលធ្វើឱ្យឥតផលប្រយោជន៍។

📖 **ហិតការី ពាក្យផ្ទុយ អហិតការី**

**ហិតការី** *ន.* (បា.) អ្នកធ្វើផលប្រយោជន៍ឱ្យ, អ្នកទំនុកបម្រុង, អ្នកផ្គុងផ្ដើម។

**អហិតការី** *ន.* (បា.) អ្នកដែលធ្វើអំពើឥតផលប្រយោជន៍, អ្នកដែលធ្វើឱ្យឥតផលប្រយោជន៍។

📖 **ហិតប្រឹថពី ពាក្យផ្ទុយ អហិតប្រឹថពី**

**ហិតប្រឹថពី** *ន.* (សំ.ភ្ល.) ដីមានផលប្រយោជន៍ គឺដីដែលធ្វើរបរកើត។

**អហិតប្រឹថពី** *ន.* (សំ.ភ្ល.) ដីឥតផលប្រយោជន៍ គឺដីដែលធ្វើរបរអ្វីពុំកើត។

📖 **ហិតពាក្យ ពាក្យផ្ទុយ អហិតពាក្យ**

**ហិតពាក្យ** *ន.* (បា.ភ្ល.) សម្ដីមានផលប្រយោជន៍។

**អហិតពាក្យ** *ន.* (បា.ភ្ល.) សម្ដីឥតមានផលប្រយោជន៍។

📖 **ហិតវាចា** **ពាក្យផ្ទុយ** **អហិតវាចា**

**ហិតវាចា** *ន.* (បា.) សម្ដីមានផលប្រយោជន៍។

**អហិតវាចា** *ន.* (បា.) សម្ដីឥតមានផលប្រយោជន៍។

📖 **ហិតវាទ** **ពាក្យផ្ទុយ** **អហិតវាទ**

**ហិតវាទ** *ន.* (បា.) សម្ដីមានផលប្រយោជន៍។

**អហិតវាទ** *ន.* (បា.) សម្ដីឥតផលប្រយោជន៍។

📖 **ហិតវាទិន** **ពាក្យផ្ទុយ** **អហិតវាទិន**

**ហិតវាទិន** *ន.* (សំ.) អ្នកដែលពេញចិត្តនិយាយតែអំពីការមានផលប្រយោជន៍។

**អហិតវាទិន** *ន.* (សំ.) អ្នកដែលច្រើនតែនិយាយសម្ដីឥតផលប្រយោជន៍។

📖 **ហិតវាទិនី** **ពាក្យផ្ទុយ** **អហិតវាទិនី**

**ហិតវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលពេញចិត្តនិយាយតែអំពីការមានផល ប្រយោជន៍។

**អហិតវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែនិយាយសម្ដីឥតផលប្រយោជន៍។

📖 **ហិតវាទី** **ពាក្យផ្ទុយ** **អហិតវាទី**

**ហិតវាទី** *ន.* (បា.) អ្នកដែលពេញចិត្តនិយាយតែអំពីការមានផលប្រយោជន៍។

**អហិតវាទី** *ន.* (បា.) អ្នកដែលច្រើនតែនិយាយសម្ដីឥតផលប្រយោជន៍។

📖 **ហិតានុគ្រោះ ពាក្យផ្ទុយ អហិតានុគ្រោះ**

**ហិតានុគ្រោះ** *កិ.* (សំ.ក្ល.) អនុគ្រោះដោយការមានផលប្រយោជន៍។

**អហិតានុគ្រោះ** *កិ.* (សំ.ក្ល.) អនុគ្រោះដោយការឥតផលប្រយោជន៍។

📖 **ហិតេសិនី ពាក្យផ្ទុយ អហិតេសិនី**

**ហិតេសិនី** *ន.* (បា.) ស្ត្រីអ្នកស្វែងរកផលប្រយោជន៍, ស្ត្រីអ្នកត្រូវការផលប្រយោជន៍។

**អហិតេសិនី** *ន.* (បា.) ស្ត្រីអ្នកស្វែងរកតែអំពើឥតផលប្រយោជន៍, ស្ត្រីអ្នកត្រូវការរកតែអំពើឥតផលប្រយោជន៍។

📖 **ហិតេសី ពាក្យផ្ទុយ អហិតេសី**

**ហិតេសី** *ន.* (បា.) អ្នកស្វែងរកផលប្រយោជន៍, អ្នកត្រូវការផលប្រយោជន៍។

**អហិតេសី** *ន.* (បា.) អ្នកស្វែងរកតែអំពើឥតផលប្រយោជន៍, អ្នកត្រូវការរកតែអំពើឥតផលប្រយោជន៍។

📖 **ហិម ពាក្យផ្ទុយ អហិម**

**ហិម** *ន.* (បា.) ទីមានទឹកសន្សើម, ប្រទេសមានទឹកសន្សើម :

❖ ព្រៃហិម។

**អហិម** *គុ.* (បា.សំ.) ដែលឥតទឹកសន្សើម; ដែលមិនមែនរងា។

📖 **ហិមកាល ពាក្យផ្ទុយ អហិមកាល**

**ហិមកាល** *ន.* (បា.សំ.) រដូវមានទឹកសន្សើម។

**អហិមកាល** *ន.* (បា.សំ.) រដូវឥតទឹកសន្សើម (គិម្ហរដូវ, រដូវក្ដៅ)។

📖 **ហិមដ្ឋាន ពាក្យផ្ទុយ អហិមដ្ឋាន**

**ហិមដ្ឋាន** *ន.* (បា.) ទីកន្លែងមានទឹកសន្សើម, ទីកន្លែងដែលរងា។

**អហិមដ្ឋាន** *ន.* (បា.) ទីកន្លែងឥតទឹកសន្សើម, ទីកន្លែងដែលមិនរងា។

📖 **ហិមប្បទេស ពាក្យផ្ទុយ អហិមប្បទេស**

**ហិមប្បទេស** *ន.* (បា.) ប្រទេសមានទឹកសន្សើម, ប្រទេសរងា។

**អហិមប្បទេស** *ន.* (បា.) ប្រទេសឥតទឹកសន្សើម, ប្រទេសឥតរងា។

📖 **ហិមប្រទេស ពាក្យផ្ទុយ អហិមប្រទេស**

**ហិមប្រទេស** *ន.* (សំ.) ប្រទេសមានទឹកសន្សើម, ប្រទេសរងា។

**អហិមប្រទេស** *ន.* (សំ.) ប្រទេសឥតទឹកសន្សើម, ប្រទេសឥតរងា។

📖 **ហិមស្ថាន ពាក្យផ្ទុយ អហិមស្ថាន**

**ហិមស្ថាន** *ន.* (សំ.) ទីកន្លែងមានទឹកសន្សើម, ទីកន្លែងដែលរងា។

**អហិមស្ថាន** *ន.* (សំ.) ទីកន្លែងឥតទឹកសន្សើម, ទីកន្លែងដែលមិនរងា។

📖 **ហេដ្ឋិម ពាក្យផ្ទុយ ឧបរិម**

**ហេដ្ឋិម** *គុ.* (បា.) ដែលជាខាងក្រោម, ដែលជាខាងក្រោយ; ដែលយ៉ាងអន់, ដែលយ៉ាងទាប, ដែលយ៉ាងចុងគេបំផុត។

**ឧបរិម** *កិ.វិ.* ឬ *គុ.* (បា.សំ.) ខាងលើ, ដែលខ្ពង់ខ្ពស់។

📖 **ហេដ្ឋិមដ្ឋាន ពាក្យផ្ទុយ ឧបរិមដ្ឋាន**

**ហេដ្ឋិមដ្ឋាន** *ន.* (បា.) ទីខាងក្រោម។

**ឧបរិមដ្ឋាន** *ន.* (បា.) ទីខាងលើ។

📖 **ហេដ្ឋិមទិស ពាក្យផ្ទុយ ឧបរិមទិស**

**ហេដ្ឋិមទិស** *ន.* (បា.) ទិសខាងក្រោម (រាប់ក្នុងពួកទិស១០)។

**ឧបរិមទិស** *ន.* (បា.) ទិសខាងលើ (រាប់ក្នុងពួកទិស១០)។

📖 **ហេដ្ឋិមបរិច្ឆេទ ពាក្យផ្ទុយ ឧបរិមបរិច្ឆេទ**

**ហេដ្ឋិមបរិច្ឆេទ** *ន.* (បា.) ការកំណត់យ៉ាងទាប, ការកំណត់យ៉ាងចុងគេបំផុត។

**ឧបរិមបរិច្ឆេទ** *ន.* (បា.) ការកំណត់យ៉ាងខ្ពស់, ការកំណត់យ៉ាងលើគេបំផុត។

📖 **ហេដ្ឋិមបរិយាយ ពាក្យផ្ទុយ ឧបរិមបរិយាយ**

**ហេដ្ឋិមបរិយាយ** *ន.* (បា.) បរិយាយយ៉ាងអន់។

**ឧបរិមបរិយាយ** *ន.* (បា.) បរិយាយដ៏ខ្ពង់ខ្ពស់។

📖 **ហេដ្ឋិមភាគ ពាក្យផ្ទុយ ឧបរិមភាគ**

**ហេដ្ឋិមភាគ** *ន.* (បា.) ប៉ែកខាងក្រោម, ភាគខាងក្រោម។

**ឧបរិមភាគ** *ន.* (បា.) ប៉ែកខាងលើ, ភាគខាងលើ។

📖 **ហេដ្ឋិមភូមិ ពាក្យផ្ទុយ ឧបរិមភូមិ**

**ហេដ្ឋិមភូមិ** *ន.* (បា.) ជាន់ខាងក្រោម, ថ្នាក់ខាងក្រោម។

**ឧបរិមភូមិ** *ន.* (បា.) ជាន់ខាងលើ, ថ្នាក់ខាងលើ។

📖 **អគ្ឃ ពាក្យផ្ទុយ អនគ្ឃ**

**អគ្ឃ** *គុ.* (បា.សំ.) ដែលមានតម្លៃ។

**អនគ្ឃ** *គុ.* (បា.សំ.) ដែលកាត់ថ្លៃពុំបាន, ដែលមានតម្លៃឥតបើគណនា :

- របស់អនគ្ឃ
- ទ្រព្យអនគ្ឃ។

📖 **អង្គ ពាក្យផ្ទុយ អនង្គ**

**អង្គ** *ន.* (បា.សំ.) អវយវៈ, រូប, តួរូប, កាយ, រាងកាយ, ខ្លួន, ខ្លួនប្រាណ; ភាគ; ចំណែកនៃរាងកាយ; ប្រភេទ; សេចក្ដីដែលចែកឱ្យឃើញចំនួន; រូបសេចក្ដី; លក្ខណៈ; ហេតុ, ការណ៍, ដើមហេតុ។

**អនង្គ** *ន.* (សំ.) អទិស្សមានកាយពួកមួយហៅថា កាមទេព ជាអ្នកនាំបណ្ដាល ឱ្យកើតសេចក្ដីត្រេកត្រអាល។

☞ ខ្មែរប្រើជាពាក្យប្រៀបសំដៅសេចក្ដីថា "ស្ត្រីមានរូបល្អ, នាងមាន លម្អ, នាងឆើតឆោម" :

- ❖ អនង្គថ្លៃ
- ❖ អនង្គមាសស្ងួន។

📖 **អង្គណ ពាក្យផ្ទុយ អនង្គណ**

**អង្គណ** *ន.* (បា.) កិលេស, មន្ទិលសៅហ្មង, គ្រឿងសៅហ្មងចិត្ត។

**អនង្គណ** *គុ.* ឬ *ន.* (បា.) ដែលឥតកិលេស; អ្នកដែលឥតកិលេស; ដែល ឥតសៅហ្មង; អ្នកបរិសុទ្ធ។

📖 **អញ្ញ ពាក្យផ្ទុយ អនញ្ញ**

**អញ្ញ** *គុ.* (បា.) ដែលដទៃ, ដែលផ្សេងគ្នា គឺដែលមិនត្រូវគ្នា។

**អនញ្ញ** *គុ.* (បា.) ដែលពុំមែនដទៃ, ដែលមិនមែនផ្សេងគ្នា គឺដែលត្រូវគ្នា, តែ មួយ, តែបែបមួយ, តែម្នាក់។

📖 **អតជាតបុត្រ, អនុជាតបុត្រ ពាក្យផ្ទុយ អវជាតបុត្រ**

**អតជាតបុត្រ** *ន.* (សំ.) កូនប្រុសប្រសើរកន្លង។

**អនុជាតបុត្រ** *ន.* (សំ.) កូនប្រុសដែលមានចរិយាធម៌ល្អតាមបែបបទរបស់មាតាបិតា។

**អវជាតបុត្រ** *ន.* (សំ.) កូនប្រុសដែលមានចរិយាធម៌ថោកទាបជាងត្រកូលរបស់ខ្លួន, កូនប្រុសក្រៅគន្លងធម៌។

📖 **អតិជាតបុត្រី, អនុជាតបុត្រី ពាក្យផ្ទុយ អវជាតបុត្រី**

**អតិជាតបុត្រី** *ន.* (សំ.) កូនស្រីប្រសើរកន្លង។

**អនុជាតបុត្រី** *ន.* (សំ.) កូនស្រីដែលមានចរិយាធម៌ល្អតាមបែបបទរបស់មាតាបិតា។

**អវជាតបុត្រី** *ន.* (សំ.) កូនស្រីដែលមានចរិយាធម៌ថោកទាបជាងត្រកូលរបស់ខ្លួន, កូនស្រីក្រៅគន្លងធម៌។

📖 **អតិបរមា ពាក្យផ្ទុយ អប្បបរមា**

**អតិបរមា** *គុ.* ឬ *ន.* (បា.) កម្រិតយ៉ាងច្រើន, កម្រិតយ៉ាងខ្ពស់, កម្រិតយ៉ាងឆ្ងាយបំផុត; ដែលច្រើនបំផុត, ក្រៃលែង, ដ៏លើសលុបបំផុត។

**អប្បបរមា** *គុ.* ឬ *ន.* (បា.) កម្រិតយ៉ាងតិច, កម្រិតយ៉ាងតូចបំផុត; ដែលតិចបំផុត, ដែលមានកំណត់យ៉ាងតូចបំផុត។

📖 **អន្ធា ពាក្យផ្ទុយ អនន្ធា**

**អត្តា** *ន.* (បា.) ខ្លួន; ចិត្ត (អាត្ម័ន, អាត្មា)។

**អនត្តា** *គុ.* (បា.) ដែលមិនមែនជារបស់ចិត្ត, ដែលមិនលុះក្នុងអំណាចចិត្ត; ដែលឥតខ្លឹមសារ។

📖 **អត្តាធីន** **ពាក្យផ្ទុយ** **អនត្តាធីន**

**អត្តាធីន** *ន.* (បា.) អ្នកដែលមានអំណាចលើខ្លួនឯង។

**អនត្តាធីន** *ន.* (បា.) អ្នកដែលមិនមានអំណាចលើខ្លួនឯង, អ្នកដែលពឹងផ្អែកផ្អែកអាស្រ័យអ្នកដទៃ, អញ្ញាធីន។

📖 **អត្ថ** **ពាក្យផ្ទុយ** **អនត្ថ**

**អត្ថ** *ន.* (បា.) ប្រយោជន៍; សេចក្ដី; សេចក្ដីពន្យល់; ពាក្យប្រែស្រាយ; សេចក្ដីចម្រើន; គតិ; រឿង, ហេតុ, ការណ៍; ដំណើរ; ផល; ផលប្រយោជន៍; បំណង; សេចក្ដីប្រាថ្នា; ទ្រព្យ, សម្បត្តិ; របស់; វត្ថុ; អីវ៉ាន់; កិច្ច, កិច្ចការ; ធុរៈ, រវល់; ...។

**អនត្ថ** *គុ.* ឬ *ន.* (បា.) ដែលឥតប្រយោជន៍, ដែលមិនមែនសេចក្ដីចម្រើន, ដែលមិនបានការ, ដែលយកជាការពុំបាន; អ្វីៗដែលយកជាការពុំបាន។

📖 **អត្ថកម្ម** **ពាក្យផ្ទុយ** **អនត្ថកម្ម**

**អត្ថកម្ម** *ន.* (បា.) អំពើមានប្រយោជន៍។

**អនត្ថកម្ម** *ន.* (បា.) អំពើឥតប្រយោជន៍។

📖 **អត្ថការិកា ពាក្យផ្ទុយ អនត្ថការិកា**

**អត្ថការិកា** *ន.* (បា.) ស្ត្រីអ្នកដែលមានប្រយោជន៍។

**អនត្ថការិកា** *ន.* (បា.) ស្ត្រីអ្នកដែលឥតប្រយោជន៍។

📖 **អត្ថការី ពាក្យផ្ទុយ អនត្ថការី**

**អត្ថការី** *ន.* (បា.) អ្នកដែលមានប្រយោជន៍។

**អនត្ថការី** *ន.* (បា.) អ្នកដែលឥតប្រយោជន៍។

📖 **អត្ថបដិរូប ពាក្យផ្ទុយ អត្ថានុរូប**

**អត្ថបដិរូប** *ន.* (បា.) សេចក្តីប្រៀបធៀប, ន័យប្រដូច គឺន័យរបស់ពាក្យដែលបង្វិលបញ្ចៀសពីន័យត្រង់ៗដូចជាពាក្យថា "ស៊ី" តាមអត្ថានុរូប គឺន័យត្រង់ៗទៅតាមដំណើរដើមថា "បរិភោគភោជនាហារ"។

**អត្ថានុរូប** *ន.* (បា.) ន័យរបស់ពាក្យដែលសមទៅតាមសេចក្តី, ន័យរបស់ពាក្យត្រង់ៗ, ន័យដែលមិនបង្វិលបញ្ចៀសខុសឃ្លាតចាកសេចក្តីដើម គឺពាក្យដែលមិនប្រើជាសេចក្តីប្រៀបប្រដូច។

📖 **អត្ថពាក្យ ពាក្យផ្ទុយ អនត្ថពាក្យ**

**អត្ថពាក្យ** *ន.* (បា.ស្ក.) សម្តីមានប្រយោជន៍។

**អនត្ថពាក្យ** *ន.* (បា.ក្ល.) សម្ដីឥតប្រយោជន៍។

📖 **អត្ថវាចា ពាក្យផ្ទុយ អនត្ថវាចា**

**អត្ថវាចា** *ន.* (បា.) សម្ដីមានប្រយោជន៍។

**អនត្ថវាចា** *ន.* (បា.) សម្ដីឥតប្រយោជន៍។

📖 **អត្ថវាទ ពាក្យផ្ទុយ អនត្ថវាទ**

**អត្ថវាទ** *ន.* (បា.) សម្ដីមានប្រយោជន៍។

**អនត្ថវាទ** *ន.* (បា.) សម្ដីឥតប្រយោជន៍។

📖 **អត្ថវាទិនី ពាក្យផ្ទុយ អនត្ថវាទិនី**

**អត្ថវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែនិយាយសម្ដីមានប្រយោជន៍យកជាការបាន។

**អនត្ថវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលច្រើនតែនិយាយសម្ដីឥតប្រយោជន៍យកជាការពុំបាន។

📖 **អត្ថវាទី ពាក្យផ្ទុយ អនត្ថវាទី**

**អត្ថវាទី** *ន.* (បា.) អ្នកច្រើនតែនិយាយសម្ដីមានប្រយោជន៍យកជាការបាន។

**អនត្ថវាទី** *ន.* (បា.) អ្នកច្រើនតែនិយាយសម្ដីឥតប្រយោជន៍យកជាការពុំបាន។

📖 **អនន្ត ពាក្យផ្ទុយ អន្ត**

**អនន្ត** *គុ.* (បា.) ដែលមិនមានទីបំផុត; ដែលមិនចេះចប់; ច្រើនហួសប្រមាណ។

**អន្ត** *គុ.* (បា.) ដែលជាទីបំផុត; ដែលចប់, ដែលស្រេច; លាមក; អាក្រក់; ថោកទាប, ដែលខ្ជីខ្ជា, ដែលពុំប្រសើរ។

📖 **អនន្តរ ពាក្យផ្ទុយ អន្តរ**

**អនន្តរ** *គុ.* (បា.) ដែលមិនមានចន្លោះ, ដែលមិនមានរវាង, ដែលមិនមានឱកាស; ដែលចេះតែជាប់បន្តរឿយៗទៅ; ដែលជាលំដាប់តៗទៅ។

**អន្តរ** *ន.* (បា.) ចន្លោះ, រវាង; ដទៃ; រយៈ; ប្រហោង, រូង, រន្ធ; ទោសភ្លាំងភ្លាត់; ឱកាស; ចំណែកខាងក្នុង, ប៉ែកខាងក្នុង; ចិត្ត, វិញ្ញាណ; សំពត់, សំពត់ស្លៀក។

📖 **អនន្តរកថា ពាក្យផ្ទុយ អន្តរកថា**

**អនន្តរកថា** *ន.* (បា.) សម្តីដែលចេះតែបង្ហូរទៅមិនឈប់។

**អន្តរកថា** *ន.* (បា.) សម្តីដែលចេះតែភ្លាំងភ្លាត់។

📖 **អនន្តរគមនាគមន៍ ពាក្យផ្ទុយ អន្តរគមនាគមន៍**

**អនន្តរគមនាគមន៍** *ន.* (បា.ភ្ល.) ការទៅមកបន្តគ្នាមិនដាច់។

**អន្តរគមនាគមន៍** *ន.* (បា.ភ្ល.) ការមិនទៅមកបន្តគ្នា។

📖 **អនន្តរបុស្ស ពាក្យផ្ទុយ អន្តរបុស្ស**

**អនន្តរបុស្ប** *ន.* (សំ.) ឈើដែលមានផ្កាមិនដាច់, វល្លិដែលមានផ្កាមិនដាច់។

**អន្តរបុស្ប** *ន.* (សំ.) ឈើដែលមិនសូវមានផ្កា, វល្លិដែលមិនសូវមានផ្កា។

📖 **អនន្តរផល ពាក្យផ្ទុយ អន្តរផល**

**អនន្តរផល** *ន.* (បា.) ឈើដែលមានផ្លែមិនដាច់, ដំណាំដែលមានផ្លែមិនដាច់។

**អន្តរផល** *ន.* (បា.) ឈើដែលមិនសូវមានផ្លែ, ដំណាំដែលមិនសូវមានផ្លែ។

📖 **អនភិសិត្តរាជ ពាក្យផ្ទុយ អភិសិត្តរាជ**

**អនភិសិត្តរាជ** *ន.* (បា.សំ.) ព្រះរាជាដែលពុំទាន់បានអភិសេកនៅឡើយ។

**អភិសិត្តរាជ** *ន.* (បា.សំ.) ព្រះរាជាដែលបានអភិសេករួចហើយ។

📖 **អនរិយ ពាក្យផ្ទុយ អរិយ**

**អនរិយ** *គុ.* (បា.) ដែលមិនមែនជាអរិយ; ដែលពុំប្រសើរ; មិនល្អ; ថោកទាប; ដែលមិនចម្រើន; ដែលមិនចុះរបៀប, ដែលឆ្គង, ដែលខ្ជីខ្ជា។

**អរិយ** *គុ.* (បា.) ប្រសើរ; ត្រឹមត្រូវ; សុភាព; រៀបរយ; មានបែបបទល្អ; ស្អាតត្រង់; ដែលឥតទោស។

📖 **អនរិយជន ពាក្យផ្ទុយ អរិយជន**

**អនរិយជន** *ន.* (បា.) ជនពុំប្រសើរ, ជនមានសណ្ដាប់ធ្នាប់ខ្ជីខ្ជា។

**អរិយជន** *ន.* (បា.) ជនមានរបៀបបែបបទទំនៀមសណ្ដាប់ល្អនាំឱ្យមាន

សេចក្ដីចម្រើន។

📖 **អនរិយធម៌ ពាក្យផ្ទុយ អរិយធម៌**

**អនរិយធម៌** *ន.* (បា.) សណ្ដាប់ធ្នាប់ខ្ជីខ្ជា, បែបបទខ្ជីខ្ជា, បែបបទរយីករយាក; អំពើព្រៃផ្សៃ, កំណាចឃោរឃៅ, អំពើសាហាវយង់ឃ្នង។

**អរិយធម៌** *ន.* (បា. និង សំ.) ធម៌ដែលនាំឱ្យកើតសេចក្ដីសុខចម្រើន; ធម៌របស់អរិយជន, ទំនៀមសណ្ដាប់ល្អ; សណ្ដាប់ធ្នាប់រៀបរយ, បែបបទរៀបរយ។

📖 **អនរិយប្បទេស ពាក្យផ្ទុយ អរិយប្បទេស**

**អនរិយប្បទេស** *ន.* (បា.) ប្រទេសមិនចម្រើន, ប្រទេសឥតរបៀប។

**អរិយប្បទេស** *ន.* (បា.) ប្រទេសរីកចម្រើន, ប្រទេសមានរបៀប។

📖 **អនស្ចារ្យ ពាក្យផ្ទុយ អស្ចារ្យ**

**អនស្ចារ្យ** *គុ.* (សំ.ភ្ល.) ដែលមិនមែនជាអស្ចារ្យ, ដែលមិនគួរទះដៃស្ញើច, ដែលមិនគួរស្ញើច។

**អស្ចារ្យ** *គុ.* (សំ.ភ្ល.) ដែលគួរស្ញើចក្រៃពេក, ដែលគួរទះដៃស្ញើចសរសើរ; ដែលគួរស្ញែងក្រៃពេក។

📖 **អនាកុល ពាក្យផ្ទុយ អាកុល**

**អនាកុល** *គុ.* (បា.សំ.) ដែលមិនច្រល្បូកច្រល់, ដែលមិនច្របូកច្របល់, ដែល

មិនសៅហ្មង, ដែលមិនមានទោស។

**អាកុល** *គុ.* (បា.សំ.) ដែលច្រលូកច្រលំ, ច្របូកច្របល់, អាកិណ្ណ; សៅហ្មង; ដែលវីវរ, ដែលវឹកវរ; វិលវល់; សុកមម៉ុក; មិងមាំង, មមិងមមាំង, ស្រឡាំងកាំង; តេងតាង, តតេងតតាង; ដែលខ្វល់ខ្វាយ, ដែលខ្វះខ្វែង។

📖 **អនាគត** **ពាក្យផ្ទុយ** **អាគត**

**អនាគត** *ន.* (បា.សំ.) កាលខាងមុខ, សម័យខាងមុខ។

**អាគត** *ន.* (បា.សំ.) កាលដែលមកដល់, សម័យដែលមកដល់ហើយ។

📖 **អនាគម** **ពាក្យផ្ទុយ** **អាគម**

**អនាគម** *ន.* (បា.សំ.) ការមិនមក; ដំណើរមិនទាន់មកដល់។

**អាគម** *ន.* (បា.សំ.) ការមក, ដំណើរមកដល់; ការរៀនសូត្រ; សេចក្ដីដឹង; ការចេះដឹង; គម្ពីរ, សាស្ត្រា, ពុទ្ធមន្ត; គាថាដែលរៀនចេះចាំតៗគ្នាមក; របៀន។

📖 **អនាគាមី** **ពាក្យផ្ទុយ** **អាគាមី**

**អនាគាមី** *ន.* (បា.) អ្នកមិនមកកាន់កាមធាតុទៀត គឺអរិយបុគ្គលដែលបានសម្រេចផលទី៣នៃលោកុត្តរធម៌ហើយ, លុះអស់អាយុអំពីជាតិនេះតែងតែទៅកើតក្នុងសុទ្ធាវាសព្រហ្មលោកបានសម្រេចអរហត្តផល ហើយបរិនិព្វានក្នុងទីនោះ (បើស្ត្រីជា អនាគាមិនី)។

**អាគាមី** *ន.* (បា.) អ្នកដែលមក។

📖 **អនាគារ** **ពាក្យផ្ទុយ** **អាគារ**

**អនាគារ** *ន.* (បា.សំ.) អ្នកគ្មានផ្ទះ គឺអ្នកដែលលះបង់ផ្ទះលំនៅហើយបួស (បព្វជិត)។

**អាគារ** *ន.* (បា.) អ្នកដែលមានផ្ទះ, អ្នកដែលមានប្រយោជន៍ដោយផ្ទះសំបែង (គ្រហស្ថ)។

📖 **អនាគារធម៌** **ពាក្យផ្ទុយ** **អាគារធម៌**

**អនាគារធម៌** *ន.* (សំ.) ធម៌សម្រាប់បព្វជិត។

**អាគារធម៌** *ន.* (សំ.) ធម៌សម្រាប់គ្រហស្ថ។

📖 **អនាគារិយធម៌** **ពាក្យផ្ទុយ** **អាគារិយធម៌**

**អនាគារិយធម៌** *ន.* (សំ.) ធម៌សម្រាប់បព្វជិត។

**អាគារិយធម៌** *ន.* (សំ.) ធម៌សម្រាប់គ្រហស្ថ។

📖 **អនាគារវិន័យ** **ពាក្យផ្ទុយ** **អាគារវិន័យ**

**អនាគារវិន័យ** *ន.* (បា.សំ.ភ្ល.) វិន័យសម្រាប់អ្នកបួស។

**អាគារវិន័យ** *ន.* (បា.សំ.ភ្ល.) វិន័យសម្រាប់គ្រហស្ថ, ច្បាប់គ្រហស្ថ។

📖 **អនាគារិយ** **ពាក្យផ្ទុយ** **អាគារិយ**

**អនាគារិយ** *ន.* (បា.) អ្នកដែលមិនមានប្រយោជន៍ដោយផ្ទះ, អ្នកដែលមិនមានប្រយោជន៍ដោយការគ្រប់គ្រងផ្ទះ (បព្វជិត)។

**អាគារិយ** *ន.* (បា) អ្នកដែលមានផ្ទះ, អ្នកដែលមានប្រយោជន៍ដោយផ្ទះសំបែង (គ្រហស្ថ)។

📖 **អនាគារិយវិន័យ ពាក្យផ្ទុយ អាគារិយវិន័យ**

**អនាគារិយវិន័យ** *ន.* (បា.សំ.ភ្គ.) វិន័យសម្រាប់អ្នកបួស។

**អាគារិយវិន័យ** *ន.* (បា.សំ.ភ្គ.) វិន័យសម្រាប់គ្រហស្ថ។

📖 **អនាចារ ពាក្យផ្ទុយ អាចារ**

**អនាចារ** *ន.* (បា.សំ.) ការប្រព្រឹត្តខុសបែបបទ, ការខុសសណ្ដាប់ធ្នាប់; ការប្រព្រឹត្តអាក្រក់, ការខ្ជីខ្ជា, ការពុំសមគួរ; ការឥតមារយាទ; មារយាទអាក្រក់។

**អាចារ** *ន.* (បា.សំ.) ការប្រព្រឹត្ត, ចរិយា; ឫក, ឫកពា, មារយាទ, ឫកមារយាទ; បែបបទ, សណ្ដាប់ធ្នាប់។

📖 **អនាតុរភាព ពាក្យផ្ទុយ អាតុរភាព**

**អនាតុរភាព** *ន.* (បា.សំ.ភ្គ.) ភាពឥតជំងឺ, ដំណើរមិនឈឺចាប់, ភាពសុខសប្បាយ, ដំណើរស្រួលខ្លួន, ភាពជាខ្លួន។

**អាតុរភាព** *ន.* (បា.សំ.ក្ល.) ភាពនៃជំងឺ, ភាពនៃជំងឺគ្រុនក្ដៅខ្លាំង។

📖 **អនាទរ** **ពាក្យផ្ទុយ** **អាទរ**

**អនាទរ** *ន.* (បា.សំ.) សេចក្ដីមិនអើពើ; ការពុំគោរព, ការពុំយកចិត្តទុកដាក់; ការមិនប្រុងប្រយត្ន; ការពុំនាំពា; ការពុំស្រវាស្រទេញ; ដំណើរតោះតើយ, ដំណើរសោះអង្គើយ; ការមើលងាយ។

**អាទរ** *ន.* (បា.សំ.) សេចក្ដីអើពើ, ការគោរព; ការយកចិត្តទុកដាក់; ការប្រុងប្រយត្ន; ការស្រវាស្រទេញ, ការនាំពា។

📖 **អនាទរប្បដិសណ្ឋារ** **ពាក្យផ្ទុយ** **អាទរប្បដិសណ្ឋារ**

**អនាទរប្បដិសណ្ឋារ** *ន.* (បា.) ការមិនទទួលរាក់ទាក់ដោយគោរព, ការមិនទទួលរាក់ទាក់ដោយស្រវាស្រទេញ។

**អាទរប្បដិសណ្ឋារ** *ន.* (បា.) ការទទួលរាក់ទាក់ដោយគោរព, ការទទួលរាក់ទាក់ដោយស្រវាស្រទេញ។

📖 **អនាទរប្រតិបត្តិ** **ពាក្យផ្ទុយ** **អាទរប្រតិបត្តិ**

**អនាទរប្រតិបត្តិ** *កិ.* (សំ.) ប្រតិបត្តិដោយមិនយកចិត្តទុកដាក់, ប្រតិបត្តិដោយមិនគោរព។

**អាទរប្រតិបត្តិ** *កិ.* (សំ.) ប្រតិបត្តិដោយយកចិត្តទុកដាក់, ប្រតិបត្តិដោយ

គោរព។

📖 **អនាទរភាព** **ពាក្យផ្ទុយ** **អាទរភាព**

**អនាទរភាព** *ន.* (បា.សំ.ក្ល.) ភាវៈតោះតើយ, ភាពតោះតើយ។

**អាទរភាព** *ន.* (បា.សំ.ក្ល.) ភាវៈនៃសេចក្ដីអើពើ, ភាពនៃសេចក្ដីអើពើ។

📖 **អនាទរមិត្ត** **ពាក្យផ្ទុយ** **អាទរមិត្ត**

**អនាទរមិត្ត** *ន.* (បា.) មិត្តដែលរាប់អានគ្នាដោយការមិនស៊ប់ចិត្ត។

**អាទរមិត្ត** *ន.* (បា.) មិត្តដែលរាប់រកគ្នាដោយយកចិត្តទុកដាក់។

📖 **អនាទិភាព** **ពាក្យផ្ទុយ** **អាទិភាព**

**អនាទិភាព** *ន.* (បា.សំ.ក្ល.) ភាវៈគ្មានដើម, ភាពគ្មានដើម, ដំណើរគ្មានដើម, ដំណើរគ្មានដើមទង :

❖ រឿងនុះជាអនាទិភាព។

**អាទិភាព** *ន.* (បា.សំ.ក្ល.) ភាវៈដើម, ភាពដើម, ដំណើរដើម, ដំណើរដើមទង :

❖ រឿងនុះជាអាទិភាព។

📖 **អនាធិបតេយ្យ** **ពាក្យផ្ទុយ** **អាធិបតេយ្យ**

**អនាធិបតេយ្យ** *ន.* (បា.) ការដែលគ្មានអាធិបតេយ្យ, ការដែលគ្មានឥស្សរភាព, ដំណើរឥតសិទ្ធិសេរីភាពក្នុងការគ្រប់គ្រង, ភាពនៃប្រជារាស្ត្រដែលមិនមាន

មគ្គុទ្ទេសក៍។

**អាធិបតេយ្យ** *ន.* (បា.) អធិបតីភាព, ភាពនៃបុគ្គលជាអធិបតី, ឥស្សរភាព, អំណាចដាច់ខាតលើខ្លួនតាមគន្លងច្បាប់បើកសិទ្ធិឱ្យ។

📖 **អនាបត្តិ ពាក្យផ្ទុយ អាបត្តិ**

**អនាបត្តិ** *ន.* (បា.) ដំណើរមិនត្រូវអាបត្តិ។

**អាបត្តិ** *ន.* (បា.) ទោសដែលភិក្ខុត្រូវព្រោះកន្លងពុទ្ធប្បញ្ញត្តិ, ទោសដែលភិក្ខុត្រូវព្រោះល្មើសពុទ្ធប្បញ្ញត្តិ (ព.វិ.ពុ.)។

📖 **អនាមយ ពាក្យផ្ទុយ អាមយ**

**អនាមយ** *ន.* (បា.សំ.) ដំណើរមិនមានរោគ, ដំណើរមិនមានជំងឺ, សេចក្ដីសុខសប្បាយខ្លួន, ដំណើរជាខ្លួន។

**អាមយ** *ន.* (បា.សំ.) រោគ, អាពាធ, ព្យាធិ, ជំងឺ។

📖 **អនាមយភាព ពាក្យផ្ទុយ អាមយភាព**

**អនាមយភាព** *ន.* (បា.សំ.ភ្ល.) ភាវៈនៅជាសុខឥតរោគាព្យាធិ។

**អាមយភាព** *ន.* (បា.សំ.ភ្ល.) ភាពនៃជំងឺ; ដំណើរមានជំងឺ, ការខ្វះសុខភាព។

📖 **អនាម័យ ពាក្យផ្ទុយ អាម័យ**

**អនាម័យ** *ន.* (បា.សំ.ភ្ល.) ដំណើរមិនមានរោគ, ដំណើរឥតជំងឺ, សេចក្ដីសុខ

សប្បាយខ្លួន, ដំណើរជាខ្លួន។

**អាម័យ** *ន.* (បា.សំ.ភ្ល.) រោគ, អាពាធ, ព្យាធិ, ជំងឺ។

📖 **អនារ្យ** **ពាក្យផ្ទុយ** **អារ្យ**

**អនារ្យ** *គុ.* (សំ.) ដែលមិនមែនជាអនារ្យ; ដែលពុំប្រសើរ; មិនល្អ; ថោកទាប; ដែលមិនចម្រើន; ដែលមិនចុះរបៀប, ឆ្គង, ខ្ជីខ្ជា។

**អារ្យ** *គុ.* (សំ.) ប្រសើរ; ត្រឹមត្រូវ; សុភាព; រៀបរយ; មានបែបបទល្អ; ស្អាតត្រង់; ដែលឥតទោស។

📖 **អនារ្យជន** **ពាក្យផ្ទុយ** **អារ្យជន**

**អនារ្យជន** *ន.* (សំ.) ជនពុំប្រសើរ, ជនមានសណ្ដាប់ធ្នាប់ខ្ជីខ្ជា។

**អារ្យជន** *ន.* (សំ.) ជនពួកអារ្យៈ គឺជនមានរបៀបបែបបទទំនៀមសណ្ដាប់ល្អនាំឱ្យមានសេចក្ដីចម្រើន។

📖 **អនារ្យធម៌** **ពាក្យផ្ទុយ** **អារ្យធម៌**

**អនារ្យធម៌** *ន.* (សំ.) សណ្ដាប់ធ្នាប់ខ្ជីខ្ជា, បែបបទខ្ជីខ្ជា, បែបបទរឃីករឃាក; អំពើព្រៃផ្សៃ, អំពើកំណាចឃោរឃៅ, អំពើសាហាវយង់ឃ្នង។

**អារ្យធម៌** *ន.* (សំ.) ធម៌ដែលនាំឱ្យកើតសេចក្ដីសុខចម្រើន; ធម៌របស់អរិយជន, ទំនៀមសណ្ដាប់ល្អ; សណ្ដាប់ធ្នាប់រៀបរយ, បែបបទរៀបរយ។

📖 **អនាវ្យប្រទេស ពាក្យផ្ទុយ អាវ្យប្រទេស**

**អនាវ្យប្រទេស** *ន.* (សំ.) ប្រទេសមិនចម្រើន, ប្រទេសឥតរបៀប។

**អាវ្យប្រទេស** *ន.* (សំ.) ប្រទេសរីកចម្រើន, ប្រទេសមានរបៀប។

📖 **អនាល័យ ពាក្យផ្ទុយ អាល័យ**

**អនាល័យ** *ន.* (បា.សំ.ភ្ល.) ដំណើរឥតលំនៅ; អ្នកដែលឥតលំនៅ, អ្នកដែលឥតផ្ទះ, អ្នកដែលឥតអាល័យ; ដំណើរអស់បំណង, ដំណើរអស់អាល័យ, ដំណើរអស់សេចក្ដីប្រាថ្នា; ព្រះនិព្វាន។

**អាល័យ** *ន.* (បា.សំ.ភ្ល.) លំនៅ, ផ្ទះលំនៅ; សេចក្ដីជាប់ចិត្ត, ការក្ដួចកាន់, ដំណើរនឹកឆ្ពោះទៅរកដោយសេចក្ដីជាប់ចិត្ត; តណ្ហា។

📖 **អនាវាស ពាក្យផ្ទុយ អាវាស**

**អនាវាស** *ន.* (បា.សំ.) ទីដែលឥតមនុស្សនៅ; វត្តដែលគេបោះបង់ចោលឥតមានបព្វជិតនៅ, អារាមដែលគេបោះបង់ចោលឥតមានបព្វជិតនៅ។

**អាវាស** *ន.* (បា.សំ.) ទីនៅ, លំនៅ, ផ្ទះ, ផ្ទះលំនៅ; វត្ត; ការនៅគ្រប់គ្រង។

📖 **អនាសវៈ ពាក្យផ្ទុយ អាសវៈ**

**អនាសវៈ** *គុ.* ឬ *ន.* (បា.ភ្ល.) ដែលមិនមានអាសវៈ; អ្នកដែលឥតកិលេសជាគ្រឿងត្រាំក្នុងសន្ដាន (អរហន្ត)។

**អាសវៈ** *ន.* (បា.ភ្ល.) គ្រឿងត្រាំ; ទឹកតម្រាំ; ទឹកដម; ស្រាត្រាំ គឺសុរាឬមេរ័យកើតពីទឹកអំពៅឬទឹកឃ្មុំ, ទឹកត្នោតជាដើមដែលត្រាំគ្រឿងផ្សំផ្សេងៗ; គ្រឿងជ្រក់, ទឹកជ្រក់; គ្រឿងសៅហ្មង, ហេតុមោះហ្មង; ឧបទ្រព, ចង្រៃ។

📖 **អនិដ្ឋ ពាក្យផ្ទុយ ឥដ្ឋ**

**អនិដ្ឋ** *គុ.* (បា.) ដែលមិនគួរប្រាថ្នា, ដែលមិនត្រូវចិត្ត។

**ឥដ្ឋ** *ន.* (បា.) ដែលគួរប្រាថ្នា, ដែលត្រូវចិត្ត, ដែលពេញចិត្ត។

📖 **អនិដ្ឋកម្ម ពាក្យផ្ទុយ ឥដ្ឋកម្ម**

**អនិដ្ឋកម្ម** *ន.* (បា.) អំពើដែលមិនត្រូវចិត្ត, កិច្ចការដែលមិនត្រូវចិត្ត។

**ឥដ្ឋកម្ម** *ន.* (បា.) អំពើដែលត្រូវចិត្ត, កិច្ចការដែលត្រូវចិត្ត។

📖 **អនិដ្ឋារម្មណ៍ ពាក្យផ្ទុយ ឥដ្ឋារម្មណ៍**

**អនិដ្ឋារម្មណ៍** *ន.* (បា.ភ្ល.) អារម្មណ៍ដែលមិនគួរប្រាថ្នា, អារម្មណ៍ដែលទាស់ចិត្ត។

**ឥដ្ឋារម្មណ៍** *ន.* (បា.ភ្ល.) អារម្មណ៍ដែលគួរប្រាថ្នា, អារម្មណ៍ដែលត្រូវចិត្ត, អារម្មណ៍ដែលចាប់ចិត្ត។

📖 **អនិស្សរ ពាក្យផ្ទុយ ឥស្សរ**

**អនិស្សរ** *គុ.* ឬ *ន.* (បា.) ដែលមិនមែនជាធំ; អ្នកដែលមិនមែនជាធំលើគេ,

ចិត្តដែលមិនមែនជាធំលើរូបកាយ។

**ឥស្សរ** *គុ.* ឬ *ន.* (បា.) ឥស្សរ។

📖 **អនិស្សរជន** **ពាក្យផ្ទុយ** **ឥស្សរជន**

**អនិស្សរជន** *ន.* (បា.) ជនដែលមិនមែនជាធំលើគេ, បុគ្គលដែលមិនមែនជាធំលើគេ។

**ឥស្សរជន** *ន.* (បា.) ជនជាឥស្សរៈ, បុគ្គលជាឥស្សរៈ (អ្នកធំ)។

📖 **អនិស្សរបុគ្គល** **ពាក្យផ្ទុយ** **ឥស្សរបុគ្គល**

**អនិស្សរបុគ្គល** *ន.* (បា.) បុគ្គលដែលមិនមែនជាធំលើគេ។

**ឥស្សរបុគ្គល** *ន.* (បា.) បុគ្គលជាឥស្សរៈ (អ្នកធំ)។

📖 **អនិស្សរា** **ពាក្យផ្ទុយ** **ឥស្សរា**

**អនិស្សរា** *គុ.* ឬ *ន.* (បា.) ដែលមិនមែនជាធំ; ស្ត្រីអ្នកដែលមិនមែនជាធំលើគេ, ចិត្តដែលមិនមែនជាធំលើរូបកាយ។

**ឥស្សរា** *គុ.* ឬ *ន.* (បា.) ដែលជាធំ; ស្ត្រីអ្នកដែលជាធំលើគេ, ចិត្តដែលជាធំលើរូបកាយ។

📖 **អនុត្តរ** **ពាក្យផ្ទុយ** **ឧត្តរ**

**អនុត្តរ** *គុ.* (បា.សំ.) ដែលប្រសើរផុត, ដែលឥតមានអ្វីស្មើ។

**ឧត្តរ** *គុ.* ឬ *ន.* (បា.) ខ្ពស់; លើ; ឆ្វេង; ក្រោយ; ខាងលើ; ខាងខ្ពស់; ខាងជើង; ខាងឆ្វេង; ខាងចុង; ខាងក្រោយ។

📖 **អនុបការ ពាក្យផ្ទុយ ឧបការ**

**អនុបការ** *គុ.* (បា.សំ.) ដែលមិនមានឧបការ; ដែលមិនមែនជាឧបការ។

**ឧបការ** *ន.* (បា.) ការទំនុកបម្រុង, ការផ្គត់ផ្គង់, ការផ្គុងផ្គើម; ការអនុលោមតាម; ប្រយោជន៍, គុណប្រយោជន៍។

📖 **អនុបចារ ពាក្យផ្ទុយ ឧបចារ**

**អនុបចារ** *គុ.* (បា.សំ.) ដែលមិនមានឧបចារ; ដែលឥតព្រំជាសម្គាល់។

**ឧបចារ** *ន.* (បា.សំ.) ការចូលជិត; ទីជិត; ព្រំ; ខេត្ត។

📖 **អនុបត្ថម្ភ ពាក្យផ្ទុយ ឧបត្ថម្ភ**

**អនុបត្ថម្ភ** *គុ.* (បា.) ដែលឥតសេចក្ដីទំនុកបម្រុង :

❖ មនុស្សអនុបត្ថម្ភ។

**ឧបត្ថម្ភ** *ន.* (បា.) ការទំនុកបម្រុង, គ្រឿងទំនុកបម្រុង; ការទល់ទ្រ, គ្រឿងទល់ទ្រ; ពំនាក់, ទីពំនាក់, គ្រឿងពឹងផ្អែក, បង្អែក :

❖ មានឧបត្ថម្ភ។

📖 **អនុបត្ថម្ភក ពាក្យផ្ទុយ ឧបត្ថម្ភក**

**អនុបត្ថម្ភក** *គុ.* (បា.) ដែលមិនមានអ្នកទំនុកបម្រុង :

❖ មនុស្សអនុបត្ថម្ភក។

**ឧបត្ថម្ភក** *ន.* (បា.) អ្នកទំនុកបម្រុង; អ្នកទល់ទ្រ, អ្នកគាំទ្រ; អ្នកដែលជាទីពឹងផ្អែក, អ្នកដែលជាទីពំនាក់ :

❖ ខ្ញុំមានបងប្រុសជាឧបត្ថម្ភក។

📖 **អនុបទេស ពាក្យផ្ទុយ ឧបទេស**

**អនុបទេស** *គុ.* (បា.សំ.) ដែលឥតឧបទេស គឺដែលឥតបានស្ដាប់ដំបូន្មាន, ដែលឥតបានស្ដាប់ពាក្យប្រៀនប្រដៅ, ដែលឥតបានស្ដាប់ការពន្យល់ឡើង :

❖ មនុស្សអនុបទេស (ប្រើជា និរុបទេស ក៏បាន)។

**ឧបទេស** *ន.* (បា.) ការពន្យល់, ការណែនាំ, ការឱ្យន័យឱ្យទំនង; ការបញ្ចេះ, ការប្រៀនប្រដៅ :

❖ ឱ្យឧបទេស

❖ ធ្វើតាមឧបទេសរបស់គ្រូ។

📖 **អនុបទ្រព ពាក្យផ្ទុយ ឧបទ្រព**

**អនុបទ្រព** *គុ.* (សំ.ភ្ល.) ដែលឥតឧបទ្រព :

❖ ផ្ទះអនុបទ្រព។

**ឧបទ្រព** *ន.* (សំ.ភ្ល.) ចង្រៃ; អពមង្គល; គ្រោះកាច, ភ័យ, អន្តរាយដែលកើតមានក្នុងបច្ចុប្បន្នទាន់ភ្នែក; ហេតុអាក្រក់ :

❖ មានឧបទ្រព។

📖 **អនុបធិ ពាក្យផ្ទុយ ឧបធិ**

**អនុបធិ** *គុ.* (បា.សំ.) ដែលឥតឧបធិ គឺដែលឥតកិលេស។

**ឧបធិ** *ន.* (បា.សំ.) កិលេស, កិលេសជាគ្រឿងទាក់ទិន; ដំណើរឆបោក, ការប្រវញ្ច, ការបញ្ឆោត; កិរិយាកោងកាច។

📖 **អនុបភោគ ពាក្យផ្ទុយ ឧបភោគ**

**អនុបភោគ** *គុ.* (បា.សំ.) ដែលឥតគ្រឿងឧបភោគ :

❖ មនុស្សអនុបភោគ។

**ឧបភោគ** *ន.* (បា.សំ.) គ្រឿងសម្រាប់ប្រើប្រាស់ជិតខ្លួន :

❖ មានគ្រឿងឧបភោគនិងគ្រឿងបរិភោគគ្រប់គ្រាន់។

📖 **អនុបមា ពាក្យផ្ទុយ ឧបមា**

**អនុបមា** (បា.សំ.) *គុ.* ដែលឥតឧបមា, ដែលឥតមានអ្វីប្រៀបផ្ទឹមបាន។

**ឧបមា** *ន.* (បា.សំ.) សេចក្ដីប្រៀប, សេចក្ដីប្រៀបធៀប, ការប្រៀបប្រដូច, ការប្រដូច, ការប្រៀបផ្ទឹម, ការទាញយកដំណើរមកប្រៀប, ការទាញយក

ហេតុជាដើមមកប្រៀប, ការទាញយកហេតុជាដើមមកប្រដូចឱ្យងាយយល់។

📖 **អនុបមេយ្យ ពាក្យផ្ទុយ ឧបមេយ្យ**

**អនុបមេយ្យ** *គុ.* (បា.សំ.) ដែលឥតឧបមេយ្យ (ប្រើជា អនូបមេយ្យ ក៏បាន)។

**ឧបមេយ្យ** *គុ.* (បា.សំ.) ដែលគួរប្រៀបផ្ទៀបគ្នាបាន, ដែលអាចប្រៀបផ្ទៀបគ្នាបាន។

📖 **អនុបវាទ ពាក្យផ្ទុយ ឧបវាទ**

**អនុបវាទ** *ន.* (បា.សំ.) អ្នកដែលមិនពោលតិះដៀល; អ្នកដែលឥតដំណៀល; អ្នកនៅស្ងៀមជាកណ្ដាល; ការមិនពោលតិះដៀល; ការអត់ធ្មត់នៅស្ងៀម។

**ឧបវាទ** *ន.* (បា.សំ.) ការពោលតិះដៀល, ការពោលទោស; ពាក្យតិះដៀល, ពាក្យពោលទោស។

📖 **អនុបវាទិន ពាក្យផ្ទុយ ឧបវាទិន**

**អនុបវាទិន** *ន.* (សំ.) អ្នកដែលមិនពេញចិត្តនឹងការពោលតិះដៀល, អ្នកដែលមិនចេះនិយាយតិះដៀលគេ; អ្នកដែលសុខចិត្តនៅស្ងៀមមិនស្ដីថាទៅលើអ្នកណា។

**ឧបវាទិន** *ន.* (សំ.) អ្នកដែលហៃខាងការនិយាយតិះដៀលគេ; អ្នកនិយាយពាក្យឧបវាទ។

📖 **អនុបវាទិនី ពាក្យផ្ទុយ ឧបវាទិនី**

**អនុបវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលមិនពេញចិត្តនឹងការពោលតិះដៀល, ស្ត្រីអ្នកដែលមិនចេះនិយាយតិះដៀលគេ; ស្ត្រីអ្នកដែលសុខចិត្តនៅស្ងៀមមិនស្ដីថាទៅលើអ្នកណា។

**ឧបវាទិនី** *ន.* (បា.) ស្ត្រីអ្នកដែលហៃខាងការនិយាយតិះដៀលគេ; ស្ត្រីអ្នកនិយាយពាក្យឧបវាទ។

📖 **អនុបវាទី ពាក្យផ្ទុយ ឧបវាទី**

**អនុបវាទី** *ន.* (បា.) អ្នកដែលមិនពេញចិត្តនឹងការពោលតិះដៀល, អ្នកដែលមិនចេះនិយាយតិះដៀលគេ; អ្នកដែលសុខចិត្តនៅស្ងៀមមិនស្ដីថាទៅលើអ្នកណា។

**ឧបវាទី** *ន.* (បា.) អ្នកដែលហៃខាងការនិយាយតិះដៀលគេ; អ្នកនិយាយពាក្យឧបវាទ។

📖 **អនុបសគ្គ ពាក្យផ្ទុយ ឧបសគ្គ**

**អនុបសគ្គ** *គុ.* (បា.) ដែលមិនមានឧបសគ្គ គឺដែលមិនមានហេតុទើសទាក់។

**ឧបសគ្គ** *ន.* (បា.) ឧបទ្រព, ចង្រៃ; គ្រឿងទើសទាក់, គ្រឿងជំទាស់, គ្រឿងរារាំងដំណើរ។

📖 **អនុបសម្បន្ន ពាក្យផ្ទុយ ឧបសម្បន្ន**

**អនុបសម្បន្ន** *គុ.* ឬ *ន.* (បា.សំ.) ដែលមិនទាន់បានដល់ថ្នាក់ខ្ពស់; អ្នកដែលមិនមែនជាឧបសម្បន្ន គឺសាមណេរនិងបុរសជាគ្រហស្ថ។

**ឧបសម្បន្ន** *គុ.* ឬ *ន.* (បា.សំ.) ដែលបានឧបសម្បទាហើយ; សាមណេរដែលបានឧបសម្បទាហើយ (ភិក្ខុ)។

📖 **អនុបាទិន្នក ពាក្យផ្ទុយ ឧបាទិន្នក**

**អនុបាទិន្នក** *គុ.* (បា.) ដែលមិនមានវិញ្ញាណចូលអាស្រ័យនៅ។

**ឧបាទិន្នក** *គុ.* (បា.) ដែលមានវិញ្ញាណចូលអាស្រ័យនៅ។

📖 **អនុបាទិសេសនិព្វាន ពាក្យផ្ទុយ ឧបាទិសេសនិព្វាន**

**អនុបាទិសេសនិព្វាន** *ន.* (បា.) និព្វានឥតសេសសល់រូបរាង, ខន្ធនិព្វាន។

**ឧបាទិសេសនិព្វាន** *ន.* (បា.) ការរលត់កិលេសនៅសល់ខន្ធ គឺការបានសម្រេចអរហត្តផល (ហៅ *សឧបាទិសេសនិព្វាន* ឬ *កិលេសនិព្វាន* ក៏បាន)។

📖 **អនុបាទិសេសបរិនិព្វាន ពាក្យផ្ទុយ ឧបាទិសេសបរិនិព្វាន**

**អនុបាទិសេសបរិនិព្វាន** *ន.* (បា.) បរិនិព្វានឥតសេសសល់រូបរាង, ខន្ធនិព្វាន។

**ឧបាទិសេសបរិនិព្វាន** *ន.* (បា.) ការរលត់កិលេសនៅសល់ខន្ធ គឺការបានសម្រេចអរហត្តផល។

📖 **អនេក ពាក្យផ្ទុយ ឯក**

**អនេក** *គុ.* (បា.សំ.) មិនមែនតែមួយ គឺច្រើនដែលរាប់ពុំបាន, ប្រមាណពុំអស់។

**ឯក** *សំខ្យា* (បា.សំ.) មួយ; ម្នាក់។

📖 **អនេសនៈ ពាក្យផ្ទុយ ឯសនៈ**

**អនេសនៈ** *ន.* (បា.ក្ល.) ការស្វែងរកពុំត្រូវតាមធម៌, ការស្វែងរកពុំត្រូវតាមបែបបទ។

**ឯសនៈ** *ន.* (បា.ក្ល.) ការស្វែងរក។

📖 **អនេសនា ពាក្យផ្ទុយ ឯសនា**

**អនេសនា** *ន.* (បា.ក្ល.) ការស្វែងរកពុំត្រូវតាមធម៌, ការស្វែងរកពុំត្រូវតាមបែបបទ។

**ឯសនា** *ន.* (បា.) ការស្វែងរក។

📖 **អនោកាស ពាក្យផ្ទុយ ឱកាស**

**អនោកាស** *គុ.* (បា.) ដែលមិនមានឱកាស :

❖ ពេលអនោកាស។

**ឱកាស** *ន.* (បា.) ហេតុ, ការណ៍; ស្ថាន, ទី, ទីទំនេរ, ចន្លោះ; វេលា, វេលាទំនេរ, ពេលស្រួល; ផ្លូវ, ទំនង; សិទ្ធិជោគ; ការនិយម, ការអនុលោម;

សេចក្ដីអនុញ្ញាតឱ្យ; ការយល់ព្រមតាម។

📖 **អនោតត្ត ពាក្យផ្ទុយ ឱតត្ត**

**អនោតត្ត** *ន.* (បា.) ឈ្មោះស្រះធំឬបឹងធំមួយក្នុងពួកស្រះធំឬបឹងធំដែលហៅមហាស្រះទាំង៧ក្នុងទីប្រជុំភ្នំហិមពាន្ត :

❖ ស្រះអនោតត្តមានទឹកថ្លាឆ្ងាញ់គួរឱ្យនឹកចង់ផឹកចង់ងូត។

**ឱតត្ត** *ន.* (បា.) ស្រះធំមានទឹកត្រូវកម្ដៅថ្ងៃ។

📖 **អនោម ពាក្យផ្ទុយ ឱម**

**អនោម** *គុ.* (បា.សំ.) ដែលមិនថោកទាប, ដែលមិនទន់ទាប, ដែលមិនថយថោក, ដែលមិនមែនល្មោកល្មម (លើសលែង, ប្រសើរ, ថ្លៃថ្លា, ខ្ពង់ខ្ពស់)។

**ឱម!** *ន.* ឬ *ឧ.* (សំ.) ពាក្យសង្ខេបជាបទសន្ធិនៃអក្សរ៣តួ គឺ អ.ឧ.ម., អ + ឧ > ឱ + ម > ឱម ឬ ឱំ; អ. គឺ ១ស្ណុ, ឧ. គឺ សិវៈ, ម. គឺ ព្រហ្ម; ជាត្រៃសរណៈរបស់ពួកព្រាហ្មណិកសម្រាប់បញ្ចេញវចីភេទ គោរពចំពោះទេវតាសក្ដិសិទ្ធិ៣អង្គ គឺ ព្រះ១ស្ណុ, ព្រះឥសូរ, ព្រះព្រហ្ម; ប្រើរៀងក្នុងខាងដើមបទវេទ, មន្តនិងសេចក្ដីសូត្រផ្សេងៗ, ប្រើជាពាក្យបន្ទឹសូមពរសូមជ័យស្រីសួស្ដីឬប្រកាសជ័យជម្នះ (ត្រូវគ្នានឹងពាក្យ ជយោ!) ក៏មាន, ប្រើជាពាក្យបន្ទឹទទួលអំណរ (ត្រូវគ្នានឹងពាក្យ សាធុ!) ក៏មាន។ ខ្មែរសម័យបុរាណ

ប្រើជា ឱម! ឬ ឱ្ម! តាមបែបដើម, លុះចំណេរកាលតមកច្រើនប្រើក្លាយជា ឲ្យម (អូម), សម្រាប់រៀងក្នុងខាងដើមមន្តអាគម។ ឱម > អោម ក៏មាន; ខ្មែរក្នុងអបរសម័យច្រើនប្រើ អោម ជាបរិវារសព្ទរបស់ ឲ្យម, និយាយថា ឲ្យមអោម។ ពួកពុទ្ធសាសនិកក្នុងអបរសម័យរៀងមកដល់បច្ចុប្បន្ននេះយកពាក្យ ឱម! មកប្រើជា រត្នត្រ័យសង្ខេប គឺ អ.ឧ.ម. ដូចបែបដើមដែរ ប៉ុន្តែសំដៅសេចក្តីថា អ. គឺអរហំសម្មាសម្ពុទ្ធ, ឧ. គឺឧត្តមធម៌, ម. គឺមហាសង្ឃ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ); នមស្ការថា នមោ ឱមស្ស! សូមនមស្ការចំពោះ អ.ឧ.ម. គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ! ឬថា នមោ ឱមរតនត្តយស្ស! សូមនមស្ការចំពោះ អ.ឧ.ម. រត្នត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ!។

📖 **អនោមសត្ត ពាក្យផ្ទុយ ឱមសត្ត**

**អនោមសត្ត** *ន.* (បា.) សត្តប្រសើរ។

**ឱមសត្ត** *ន.* (បា.) សត្តថោកទាប។

📖 **អនោមកសត្ត ពាក្យផ្ទុយ ឱមកសត្ត**

**អនោមកសត្ត** *ន.* (បា.) សត្តប្រសើរ។

**ឱមកសត្ត** *ន.* (បា.) សត្តថោកទាប។

📖 **អនោមសត្វ ពាក្យផ្ទុយ ឱមសត្វ**

**អនោមសត្វ** *ន.* (បា.) សត្វប្រសើរ។

**ឱមសត្វ** *ន.* (បា.) សត្វថោកទាប។

📖 **អនោមកសត្វ ពាក្យផ្ទុយ ឱមកសត្វ**

**អនោមកសត្វ** *ន.* (បា.) សត្វប្រសើរ។

**ឱមកសត្វ** *ន.* (បា.) សត្វថោកទាប។

📖 **អន្លូញប៉័ក ពាក្យផ្ទុយ អន្លូញមក្លាំ, អន្លូញស្មើ**

**អន្លូញប៉័ក** *ន.* អន្លូញត្បាញដោយអំបោះអន្ទងសចាក់ខ្មៅសាច់គ្រើមៗ។

**អន្លូញមក្លាំ** *ន.* អន្លូញត្បាញចាក់ជាក្រឡាប្អូនជ្រុងល្អិតៗលាយពណ៌ក្រហម និងខ្មៅឆ្លាស់គ្នាស្រដៀងនឹងសម្បុរគ្រាប់អង្រ្កែមអង្ក្រមទុំ។

**អន្លូញស្មើ** *ន.* អន្លូញត្បាញចម្រុះពណ៌អំបោះឬសូត្រចាក់និងអន្ទងខុសគ្នា ប៉ុន្តែស្មើភាគគ្នាឬត្បាញចាក់និងអន្ទងលាយសូត្រនិងអំបោះឆ្លាស់ពីរសរសៃៗ ស្មើគ្នា។

📖 **អលសភាព ពាក្យផ្ទុយ វិរិយភាព, ឧស្សាហភាព**

**អលសភាព** *ន.* (បា.សំ.ភ្ល.) ភាពនៃបុគ្គលខ្ជិលច្រអូស, អំពើច្រអូស, ការទម្រន់ មិនចង់អើពើនឹងកិច្ចការទាំងពួង, ការកៀចមិនចង់អើពើនឹងកិច្ចការទាំងពួង។

**វិរិយភាព** *ន.* (បា.សំ.ភ្ល.) ភាពនៃសេចក្ដីព្យាយាម, ភាពនៃសេចក្ដីខំប្រឹង,

ឧយ្យាមភាព។

**ឧយ្យាមភាព** *ន.* (បា.សំ.ក្ល.) ភាពនៃសេចក្ដីព្យាយាម, ភាពនៃសេចក្ដីខំប្រឹង, វីរិយភាព។

📖 **អាគន្តុកវត្ត ពាក្យផ្ទុយ អាវាសិកវត្ត**

**អាគន្តុកវត្ត** *ន.* (បា.) វត្តដែលភិក្ខុសាមណេរអ្នកនៅក្នុងអាវាសត្រូវធ្វើចំពោះភិក្ខុសាមណេរជា អាគន្តុកៈ។

**អាវាសិកវត្ត** *ន.* (បា.) កិច្ចវត្តដែលអាគន្តុកភិក្ខុត្រូវធ្វើចំពោះ អាវាសិកភិក្ខុ។

📖 **អាគន្តុកភិក្ខុ, អារញ្ញកភិក្ខុ ពាក្យផ្ទុយ អាវាសិកភិក្ខុ**

**អាគន្តុកភិក្ខុ** *ន.* (បា.) ភិក្ខុអ្នកមករក។

**អារញ្ញកភិក្ខុ** *ន.* (បា.) ភិក្ខុអ្នកនៅក្នុងព្រៃ។

**អាវាសិកភិក្ខុ** *ន.* (បា.) ភិក្ខុអ្នកនៅក្នុងវត្ត។

📖 **ឧបច្ឆេទកកម្ម ពាក្យផ្ទុយ ឧបត្ថម្ភកកម្ម**

**ឧបច្ឆេទកកម្ម** *ន.* (បា.) អកុសលកម្មពីព្រេងនាយដែលអន្ទោលជាប់តាមមកចេញមុខឱ្យផលផ្ដាច់ជីវិត។

**ឧបត្ថម្ភកកម្ម** *ន.* (បា.) កុសលកម្មពីព្រេងនាយដែលចេញមុខទំនុកបម្រុងឱ្យបានសេចក្ដីសុខចម្រើន។

📖 **ឧបជ្ឈាយ៍មាន់ ពាក្យផ្ទុយ ឧបជ្ឈាយ៍អណ្ដើក**

**ឧបជ្ឈាយ៍មាន់** *ន.* ឧបជ្ឈាយ៍ដូចជាមេមាន់។

**ឧបជ្ឈាយ៍អណ្ដើក** *ន.* ឧបជ្ឈាយ៍ណាដែលគ្រាន់តែបំបួសកុលបុត្រមក ហើយក៏បោះបង់ចោលមិនបីបាច់រក្សា, អ្នកប្រាជ្ញលោកពោលដោយឧបមាថា ឧបជ្ឈាយ៍នោះឯងដូចជាមេអណ្ដើកដែលគ្រាន់តែបញ្ចេញស៊ុត ហើយក៏កកាយដីលុបកប់ស៊ុតហើយបោះបង់ចោលឥតនឹកនាដូច្នោះដែរ; លទ្ធិពុទ្ធពោលថា ទោះបីយ៉ាងនេះក៏ដោយឧបជ្ឈាយ៍នោះក៏ឈ្មោះថាជា ឧបជ្ឈាយ៍នៃកុលបុត្រនោះហើយ, កាលបើកុលបុត្រនោះបានស្គាល់ថាជាឧបជ្ឈាយ៍របស់ខ្លួនក៏ត្រូវតែកុលបុត្រនោះជា កតវេទី ឬ កតវេទិនី ចំពោះឧបជ្ឈាយ៍នោះដែរ។

📖 **ឧបត្ថម្ភកកម្ម ពាក្យផ្ទុយ ឧបឃាតកកម្ម, ឧបបីឡកកម្ម**

**ឧបត្ថម្ភកកម្ម** *ន.* (បា.) កុសលកម្មពីព្រេងនាយដែលចេញមុខទំនុកបម្រុងឱ្យបានសេចក្ដីសុខចម្រើន។

**ឧបឃាតកកម្ម** *ន.* (បា.) អំពើប្រហារជីវិតគេ។

**ឧបបីឡកកម្ម** *ន.* (បា.) អកុសលកម្មពីព្រេងនាយដែលជាប់តាមមកផ្ដល់បៀតបៀនឱ្យបាននូវសេចក្ដីទុក្ខលំបាកវិនាសទ្រព្យធនជាដើម។

📖 **ឧភតោ** **ពាក្យផ្ទុយ** **ឯកតោ**

**ឧភតោ** *និ.* (បា.) ទាំងពីរ, ខាងទាំងពីរ, ទាំងពីរខាង, អំពីខាងទាំងពីរ, តាមខាងទាំងពីរ។

**ឯកតោ** *និ.* (បា.) ខាងម្ខាង, តែម្ខាង, ខាងម្នាក់; ជាមួយ, ជាមួយគ្នា, ដំណាលគ្នា។

📖 **ឧភតោធារ** **ពាក្យផ្ទុយ** **ឯកតោធារ**

**ឧភតោធារ** *គុ.* (បា.) ដែលមានមុខមុតទាំងពីរខាង :

❖ សស្ត្រាឧភតោធារ។

**ឯកតោធារ** *គុ.* (បា.) ដែលមានមុខតែម្ខាង :

❖ សស្ត្រាឯកតោធារ។

📖 **ឧភតោសុទ្ធិ** **ពាក្យផ្ទុយ** **ឯកតោសុទ្ធិ**

**ឧភតោសុទ្ធិ** *ន.* (បា.) បរិសុទ្ធិទាំងពីរខាង។

**ឯកតោសុទ្ធិ** *ន.* (បា.) បរិសុទ្ធិតែខាងម្ខាង, បរិសុទ្ធិតែអ្នកម្ខាង។

📖 **អ្នកក្រ** **ពាក្យផ្ទុយ** **អ្នកមាន**

**អ្នកក្រ** *ន.* ជនដែលក្រទ្រព្យ។

**អ្នកមាន** *ន.* អ្នកដែលមានទ្រព្យច្រើន។

**សូមគោរពប្រគេនជូនដំណឹងចំពោះ**

ព្រះតេជព្រះគុណ សម្តេច ទ្រង់ ឯកឧត្តម ឧកញ៉ា លោកជំទាវ បញ្ញវន្ត លោកគ្រូ អ្នកគ្រូ និស្សិតទាំងអស់គោរពមេត្តាជួយកែតម្រូវអត្ថន័យ អត្ថរូប អត្ថរស អក្ខរាវិរុទ្ធ ខ្លឹមសារក្នុងគំនិតស្ថាបនាបសាទសទ្ធាជ្រះថ្លា តាមការគួរដោយក្តីអនុគ្រោះ!

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពថ្លែងអំណរព្រះគុណ អរគុណ និងកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត!

ចំពោះទឹកព្រះទ័យនិងទឹកចិត្តប្រកបដោយកុសលចេតនាជ្រះថ្លា!

**ទូរសព្ទលេខ** : **០១២ ៦២ ៧០ ៧០**

: **០៩២ ៤៧ ៦៦ ២២**

# គន្ថនិទ្ទេស

១- អៀវ-កើស ភាសាខ្មែរ

២- ហ៊ីង-ធីឫទ្ធិ អត្ថាធិប្បាយវចនានុក្រមច្បាប់

៣- បាលីវេយ្យាករណ៍ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤៤

៤- សព្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

៥- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ការផ្សាយនៃវិទ្យាស្ថានភាសាជាតិ

៦- វចនានុក្រមខ្មែរ KHMER DICTIONARY ការផ្សាយបណ្ណាគារអង្គរធំ ព.ស.២៥៥៥ គ.ស.២០១១

៧- ជួន-ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ព.ស.២៥១១- ២៥១២ គ.ស.១៩៦៧-១៩៦៨។

៨- ច័ន្ទ សំណព្វ (១៩៩៩) វជ្ជមានន័យ អវជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៩- ច័ន្ទ សំណព្វ (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១០- ច័ន្ទ សំណព្វ (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១១- ច័ន្ទ សំណព្វ (២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ ការ និងផ្នត់ដែក [-អ់ម/ណា-] / [-អ៊់ម/ន-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

សៀវភៅដែលរៀបរៀងនិងចេញផ្សាយដោយទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ

**នួច-គីមស្រ៊ាង**

**សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**១- ពុទ្ធភាសិត**

**២- សទ្ទានុក្រមសទិសន័យ**

**៣- សទ្ទានុក្រមពាក្យទំនឹមបុរាណ**

**៤- សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ**

**៥- សទ្ទានុក្រមរបៀបប្រើពាក្យ**

**៦- សទ្ទានុក្រមសទិសសូរ**

**៧- សទ្ទានុក្រមពាក្យថ្មី**

**៨- សទ្ទានុក្រម រ**

**៩- សទ្ទានុក្រមពាក្យផ្ទុយ**

## ជីវប្រវត្តិ

ខ្ញុំ **ទូច-តីមស្រ៊ាង** កើតនៅឆ្នាំ១៩៧៤ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី

ស្រុកក្រចេះ ខេត្តក្រចេះ ជាកូនទី៥ ក្នុងចំណោមបងប្អូនប្រុសស្រី៦នាក់ ស្រី៤ ប្រុស២

ឪពុកឈ្មោះ **ទ៊ី-យេន** ស្លាប់

ម្តាយឈ្មោះ **អ៊ី-មាស** ស្លាប់

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្តេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ទណ្ឌាលោម

ISBN-13 : 978-99963-705-8-8